**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: សហមេធាវីការពារក្តីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 06-Dec-2011, 08:21
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ: **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**

---

ដាក់ដោយ៖

**សហមេធាវីការពារក្តី៖**

អាង ឧត្តម

Michael G. KARNAVAS

ផ្ញើជូន៖

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល៖**

**ចៅក្រម គង់ ស្រឹម ជាប្រធាន**

**ចៅក្រម សោម សិរីវឌ្ឍ**

**ចៅក្រម ម៉ុង មុន្នីចរិយា**

**ចៅក្រម យ៉ា ណារិន**

**ចៅក្រម Motoo Noguchi**

**ចៅក្រម Agniezska KLONOWIECKA-MILART**

**ចៅក្រម Chandra Nihal N. Jayasinghe**

**ចៅក្រមបម្រុង ស៊ិន រិទ្ធិ**

**ចៅក្រមបម្រុង** Florence MUMBA

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew T. CAYLEY

**ក្រុមមេធាវីជនជាប់ចោទទាំងអស់**

**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីការពារក្ដីរបស់គាត់ (“មេធាវីការពារក្ដី”) អនុលោមតាមវិធាន ១០៤(១) វិធាន ១០៤(៤)(ក) វិធាន ១០៥(២) និង វិធាន ២១ នៃវិធានផ្ទៃក្នុង អ.វ.ត.ក (“វិធាន”) សូមដាក់បណ្ដឹងសាទុក្ខនេះប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (“សេចក្ដីសម្រេចដែលត្រូវបានជំទាស់”)[1]។ បណ្ដឹងសាទុក្ខនេះត្រូវបានដាក់ជាការចាំបាច់ ដោយសារអង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ ដែលបណ្ដាលឲ្យមានមោឃភាពដល់សេចក្ដីសម្រេចដែលត្រូវបានជំទាស់នេះ។ សេចក្ដីសម្រេចដែលត្រូវបានជំទាស់ជាកម្មវត្ថុនៃបណ្ដឹងសាទុក្ខ ភ្លាមៗ ដោយអនុលោមតាមវិធាន ១០៤(៤)(ក) ដោយសារវាមានអានុភាពក្នុងការបញ្ចប់កិច្ចដំណើរការនីតិវិធីនៃ “សវនាការដំណាក់កាលដំបូង” នៃសំណុំរឿង ០០២។

## I. មូលដ្ឋាននៃបណ្ដឹងសាទុក្ខ

*នៅ អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងអាចអនុវត្តបានតែនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលស្របជាមួយគោលការណ៍នីត្យានុកូលភាព ដោយនិយមន័យនេះត្រូវតែបានកំណត់នៅក្នុងច្បាប់អន្តរជាតិនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ប៉ុណ្ណោះ (ប្រសិនបើច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវយកមកអនុវត្តនៅ អ.វ.ត.ក នោះ) ហើយ លោក អៀង សារី អាចប្រមើលមើលឃើញថាជាបទឧក្រិដ្ឋ និងដឹងថាមានច្បាប់ចែង។ និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោយសង្គ្រាមលោកលើកទី២នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ តម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ។ ការអនុវត្តរបស់រដ្ឋ និងសច្ចាធារណ៍ធម្មនុរូប* (opinio juris) *មិនបានបង្ហាញឲ្យច្បាស់ថា នៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លែងតម្រូវឲ្យមានទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធនោះទៀតហើយ។ តើអង្គជំនុំជម្រះសាលាដំបូងមានកំហុសដែរឬទេ ក្នុងការដកចេញទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធជាធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ?*

## II. សេចក្ដីសង្ខេបនៃនត្ថិករណ៍

---

[1] សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១, ឯកសារលេខ E95/8។

**អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់នៅពេលអង្គជំនុំជម្រះសន្និដ្ឋាន និងប្រកាសថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ពុំតម្រូវឱ្យបង្ហាញភស្តុតាងអំពីទំនាក់ទំនងមួយរវាងអំពើឧក្រិដ្ឋកម្មជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធទេ**

១. អង្គជំនុំជម្រះសាលាដំបូងបានរំលោភទៅលើគោលការណ៍នីត្យានុកូលភាព នៅពេលអង្គជំនុំជម្រះនេះកែប្រែនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយដកទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធចេញ។ តាមរយៈការកែប្រែនិយមន័យនេះ អង្គជំនុំជម្រះសាលាដំបូងបានធ្វើឱ្យលោក អៀង សារី ក្លាយជាកម្មវត្ថុនៃការកាត់សេចក្ដីពីបទឧក្រិដ្ឋមួយដែលខ្វះធាតុផ្សំមួយដែលមានអត្ថិភាពក្នុងអំឡុងពេលនៃយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវបានកំណត់ដោយ ការអនុវត្តរបស់រដ្ឋ និង *សទ្ធាធារណ៍ធម្មានុរូប (opinio juris)* "យ៉ាងទូលំទូលាយ និងមានឯកភាពគ្នាជាក់ស្ដែង"។ លិខិតុបករណ៍អន្តរជាតិ និងឯកសារផ្សេងៗទៀតដែលអង្គជំនុំជម្រះសាលាដំបូងបានដកស្រង់ មិនមែនជាការអនុវត្តរបស់រដ្ឋ និង *សទ្ធាធារណ៍ធម្មានុរូប (opinio juris)* នៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ។

២. ក្រោយសង្គ្រាមលោកលើកទី២ ធម្មនុញ្ញនៃតុលាការ Nuremberg និងសាលក្រមនៃតុលាការ Nuremberg គឺជាសេចក្ដីថ្លែងការណ៍អន្តរជាតិដែលត្រូវបានទទួលយកច្រើនជាងគេបំផុត។ រឿងក្ដីនានាដែលទាក់ទិននឹងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ ("CCL 10") ដែលមាននៅប្រទេសអាល្លឺម៉ង់ ពុំមានភាពស៊ីសង្វាក់គ្នាក្នុងការបកស្រាយពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធនៅក្នុងរឿងក្ដីទាំងនោះទេ ហើយដោយសារតែវាជារឿងក្ដីនៅក្នុងប្រទេសផងនោះ រឿងក្ដីទាំងនោះមិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។ គោលការណ៍តុលាការ Nuremberg ដែលត្រូវបានអនុម័តនៅឆ្នាំ ១៩៥០ បានបញ្ចូលលក្ខខណ្ឌតម្រូវទំនាក់ទំនងនេះនៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ គោលការណ៍ទាំងនេះត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ("អ.ស.ប") ជាគោលការណ៍ច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលទទួលស្គាល់ដោយធម្មនុញ្ញនៃតុលាការ Nuremberg និងសាលក្រមនៃតុលាការ Nuremberg។

៣. សេចក្ដីព្រាងក្រមស្ដីពីអំពើល្មើសឆ្នាំ ១៩៥៤ របស់គណៈកម្មការច្បាប់អន្តរជាតិនៃអង្គការសហប្រជាជាតិ (ILC) មិនមែនជាការអនុវត្តរបស់រដ្ឋ និង *សទ្ធាធារណ៍ធម្មានុរូប (opinio juris)* ទេ។

មានការពិភាក្សាដេញដោលគ្នាច្រើនក្នុងអំឡុងពេលរៀបរៀងសេចក្តីព្រាងនេះ ថាតើគួរដាក់បញ្ចូលលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធនៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬទេ។ ជាភស្តុតាង សេចក្តីព្រាងក្រមស្តីពីអំពើល្មើសឆ្នាំ ១៩៥៤ នេះមិនត្រូវបានអនុម័តដោយមហាសន្និបាត អ.ស.ប ទេ។

៤. អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨ ដែលបានលុបចោលលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃអំពើប្រល័យពូជសាសន៍នោះ មិនបង្ហាញអំពីឋានៈនៃនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងឆ្នាំ ១៩៤៨ ទេ។ អំពើប្រល័យពូជសាសន៍ជាឧក្រិដ្ឋកម្មមួយដាច់ដោយឡែកពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយវាមានធាតុផ្សំខុសគ្នា។ ការលុបចោលលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ មិនបានផ្លាស់ប្តូរអត្ថិភាពនៃលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ។

៥. ទាំងអនុសញ្ញាស្តីពីអាជ្ញាយុកាលឆ្នាំ ១៩៦៨ ទាំងអនុសញ្ញាស្តីពីការរើសអើង (Apartheid) ឆ្នាំ ១៩៧៣ សុទ្ធតែមិនបានផ្តល់នូវភស្តុតាងច្បាស់លាស់អំពីការអនុវត្តរបស់រដ្ឋ និង*សច្ចាធារណ៍ធម្មានុរូប* (opinio juris) នៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនេះទេ។ អនុសញ្ញាទាំងពីរនេះជាឯកសារនយោបាយ ដែលមិនបានទទួលការគាំទ្រយ៉ាងខ្លាំងក្លាពីបណ្តារដ្ឋជាសមាជិក អ.ស.ប ក្នុងអំឡុងពេលនៃយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក ទេ។

៦. *ឯកសារត្រៀមនានា* (travaux préparaoires) នៃឯកសារក្រោយឆ្នាំ ១៩៧៩ ដែលអង្គជំនុំជម្រះសាលាដំបូងបានដកស្រង់ បង្ហាញថា បញ្ហាស្តីពីលក្ខខណ្ឌតម្រូវនៃទំនាក់ទំនង មិនត្រូវបានដោះស្រាយដោយការពង្រាងលក្ខន្តិកៈនៃតុលាការ *មិនអចិន្ត្រៃយ៍* (ad hoc) ឡើយ ហើយនៅតែត្រូវបានពិភាក្សាគ្នារហូតដល់ពេលអនុម័តលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) នៅឆ្នាំ ១៩៩៨។ ដូច្នេះ ការខ្វែងគំនិតគ្នាអំពីអត្ថិភាពនៃលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធនៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅបន្តរយៈពេល ២០ ឆ្នាំ បន្ទាប់ពីយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក។

៧. លិខិតុបករណ៍ និងឯកសារនានាដែលអង្គជំនុំជម្រះសាលាដំបូងបានដកស្រង់មកធ្វើជាសំអាង មិនបានបង្ហាញពី ការអនុវត្តរបស់រដ្ឋ និង *សទ្ធាធារណ៍ធម្មានុរូប* (*opinio juris*) "យ៉ាងទូលំទូលាយ និងមានឯកភាពគ្នាជាក់ស្តែង" ដែលបង្ហាញថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បានលុបចោលទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធទេ។ សេចក្តីសម្រេចដែលត្រូវបានជំទាស់នេះ រំលោភដល់គោលការណ៍នីត្យានុកូលភាព។ ទោះបី អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ពុំតម្រូវឲ្យមានទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធក៏ដោយ ក៏លោក អៀង សារី មិនអាចប្រមើលមើលឃើញថាជាបទឧក្រិដ្ឋ និងមិនអាចដឹងថាមានច្បាប់ចែងទេនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ អំពីការទទួលខុសត្រូវផ្នែក ព្រហ្មទណ្ឌដោយគ្មានលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងនេះឡើយ។ លោក អៀង សារី មិនអាចដឹងបានជាទូទៅនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទេថា គាត់អាចនឹងមានការទទួលខុសត្រូវចំពោះបទចោទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមិនពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធណាមួយនោះហើយគាត់។ ការសន្និដ្ឋានណាមួយផ្សេងក្រៅពីនេះនឹងរំលោភដល់គោលការណ៍នីត្យានុកូលភាពហើយ។ ក្នុងករណីមានមន្ទិលសង្ស័យ បញ្ហានេះត្រូវតែដោះស្រាយដោយអនុលោមទៅតាមគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* (*in dubio pro reo*) ដោយបានជាប្រយោជន៍ដល់លោក អៀង សារី។ អង្គជំនុំជម្រះតុលាការកំពូលគួរតែទទួលយកតាមបណ្តឹងសាទុក្ខនេះ និងបដិសេធចោលសេចក្តីសម្រេចដែលត្រូវបានជំទាស់នេះ។

## III. ភាពអាចទទួលយកបាន

### ក. ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ

៨. **មូលដ្ឋាននៃបណ្តឹងសាទុក្ខ**ពាក់ព័ន្ធនឹងកំហុសលើអង្គច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងដែលសន្និដ្ឋាន និងប្រកាសថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ពុំតម្រូវឲ្យបង្ហាញភស្តុតាងពីទំនាក់ទំនងមួយរវាងអំពើឧក្រិដ្ឋជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធណាមួយទេ។ កំហុសឆ្គងនេះមិនមានសំអាងហេតុមិនត្រឹមត្រូវ ឬការអនុវត្តវិធាននៃច្បាប់ដែលបានលើកឡើងយ៉ាងសមរម្យដោយមិនត្រឹមត្រូវនោះទេ។ ផ្ទុយទៅវិញ កំហុសឆ្គងនេះពាក់ព័ន្ធទៅនឹងបញ្ហាផ្នែកអង្គច្បាប់ដែលទាក់ទិនទៅនឹងធាតុផ្សំនៃ

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ដោយសារវាប៉ះពាល់ដល់ការទទួលយកភ័ស្តុតាងនោះ នោះគេត្រូវដោះស្រាយបញ្ហានេះឲ្យបានមុនពេលចាប់ផ្តើមសវនាការ។ សេចក្តីសម្រេចដែលត្រូវបានជំទាស់នេះរំលោភដល់គោលការណ៍នីត្យានុកូលភាព ហេតុនេះសេចក្តីសម្រេចនេះមានមោឃភាព។ ទទ្ធីករណ៍នៃបណ្តឹងសាទុក្ខនេះអាចទទួលយកបានអនុលោមតាមវិធាន ១០៤(១)(ក)[2]។

## ខ. ភាពទទួលយកបាននៃបណ្តឹងសាទុក្ខ ថាជាបណ្តឹងសាទុក្ខភ្លាមៗ

### ១. ភាពទទួលយកបាននៃបណ្តឹងសាទុក្ខភ្លាមៗ

៩. អនុលោមតាមវិធាន ១០៤(១)(ក) បណ្តឹងសាទុក្ខភ្លាមៗមួយអាចត្រូវបានដាក់ ដោយផ្អែកលើ "កំហុសលើអង្គច្បាប់ ដែលនាំឲ្យមោឃៈសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះ"។ អនុលោមតាមវិធាន ១០៤(៤)(ក) សេចក្តីសម្រេចដែលអង្គជំនុំជម្រះសាលាដំបូងបានចេញ "ដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី" ជាកម្មវត្ថុដែលអាចប្តឹងសាទុក្ខភ្លាមៗបាន។ អនុលោមតាមវិធាន ១០៥ ភាគីណាមួយដែលដាក់បណ្តឹងសាទុក្ខភ្លាមៗចំពោះសេចក្តីសម្រេចណាមួយរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវ "បញ្ជាក់អំពីកំហុសអង្គច្បាប់ និងត្រូវបង្ហាញថា កំហុសនោះបណ្តាលឲ្យសេចក្តីសម្រេចមានមោឃភាព"។ អង្គបុរេជំនុំជម្រះបានសម្រេចថា វិធាន ២១ "តម្រូវថា អង្គបុរេជំនុំជម្រះត្រូវបកស្រាយឲ្យបានទូលំទូលាយនូវសិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹង ដើម្បីធានាថា សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ ត្រូវបានគំពារក្នុងកាលៈទេសៈនេះ"[3]។ សេចក្តីសម្រេចដែលត្រូវបានជំទាស់នេះមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីនៃ "សវនាការដំណាក់កាលដំបូង" នៃសំណុំរឿង ០០២ ហេតុនេះវាជាកម្មវត្ថុនៃបណ្តឹងសាទុក្ខភ្លាមៗ អនុលោមតាមវិធាន ១០៤(៤)(ក)។

### ២. សេចក្តីសម្រេចដែលត្រូវបានជំទាស់បានបញ្ចប់កិច្ចដំណើរការនីតិវិធី "សវនាការ

---

[2] *សូមមើល* ឧបសម្ព័ន្ធ ១៖ ប្រវត្តិនីតិវិធីដែលនាំឲ្យមានបណ្តឹងសាទុក្ខ។

[3] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និង សេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ D390/1/2/4, កថាខណ្ឌ ១៣។

**ដំណាក់កាលដំបូង" ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសទេ**

១០. អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញពីវិសាលភាពនៃ "សវនាការដំណាក់កាលដំបូង" ក្នុងសំណុំរឿង ០០២ តាមរយៈដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួន[4] ដែលអង្គជំនុំជម្រះបានសម្រេច "បំបែកកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២ ទៅជាផ្នែកតូចៗ ដោយដាក់បញ្ចូលការចោទប្រកាន់លើអង្គហេតុ និងបញ្ហាអង្គច្បាប់ជាក់លាក់ដែលពាក់ព័ន្ធ"[5]។ នៅក្នុងកថាខណ្ឌ ៦ នៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានអះអាងយ៉ាងច្បាស់ថា "នៅក្នុងដំណាក់កាលណាមួយក៏បាន អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចដាក់បញ្ចូលបន្ថែមនូវផ្នែកផ្សេងទៀតនៃដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ ប្រសិនបើសិទ្ធិដែលត្រូវទទួលបានការការពារខ្លួន ត្រូវបានផ្ដល់ជូននូវឱកាសក្នុងការរៀបចំការការពារបានប្រសិទ្ធភាព ហើយនិងភាគីនានាត្រូវបានជូនដំណឹងក្នុងរយៈពេលសមស្រប។ នៅពេលបញ្ចប់ការជំនុំជម្រះលើកដំបូងនេះ អង្គជំនុំជម្រះនឹងចេញសាលក្រមពាក់ព័ន្ធនឹងការចោទប្រកាន់ទាំងនេះដោយផ្ដន្ទាទោសសមស្រប

[4] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១, ឯកសារលេខ E124 ("ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី")។ *សូមមើលផងដែរ* សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១, ឯកសារលេខ E124/7 ("សេចក្ដីសម្រេចលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី"); ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២, ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១, ឯកសារលេខ E131 ("ដីកាកំណត់កាលបរិច្ឆេទ")។

[5] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ២។ អង្គជំនុំជម្រះសាលាដំបូង "សវនាការដំណាក់កាលដំបូង" ត្រូវមានបទចោទប្រកាន់លើអង្គហេតុ និងបញ្ហាអង្គច្បាប់ដូចជា៖ ក.រចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ ខ.តួនាទីរបស់ជនជាប់ចោទម្នាក់ៗក្នុងអំឡុងពេលមុនការបង្កើតកម្ពុជាប្រជាធិបតេយ្យ រួមទាំងពេលរៀបចំបង្កើតតួនាទីទាំងនោះផង គ.តួនាទីរបស់ជនជាប់ចោទម្នាក់ៗនៅក្នុងរដ្ឋាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យ ការចាត់តាំងការទទួលខុសត្រូវរបស់ពួកគេ វិសាលភាពនៃអំណាចរបស់ពួកគេ និងខ្សែសង្វាក់ទំនាក់ទំនងក្នុងរយៈកាលនោះទាំងមូលដែលពាក់ព័ន្ធនឹង អ.វ.ត.ក ឃ.គោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យទៅលើបញ្ហានានាដែលបានលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ង.ការចោទប្រកាន់ក្នុងអង្គហេតុដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ដូចជាការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី១ និងទី២ និង ច.ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរួមមាន មនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ (លើកលែងដោយសារមូលហេតុសាសនា) ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ (ដែលកន្លងមកបានបញ្ចូលនៅក្នុង ការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី១ និងទី២)។ *ដូចខាងលើ,* កថាខណ្ឌ ១, ៥។

ប្រសិនបើរកឃើញថា មានពិរុទ្ធភាព"[6]។

១១. "សវនាការដំណាក់កាលដំបូង" នឹងសម្រេចថាតើ លោក អៀង សារី មានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានចោទប្រកាន់ ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី១ និង ទី២ ឬទេ[7]។ ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីមិនរំពឹងថានឹងពិចារណាទៅលើបទចោទផ្សេងៗទៀតនៅក្នុងសវនាការដំណាក់កាលដំបូងទេ[8] ហើយក៏មិនគិតថា ភ័ស្តុតាងនឹងត្រូវទទួលយកក្នុងអំឡុងពេល "សវនាការដំណាក់កាលដំបូង" ដែលទាក់ទិននឹងអត្ថិភាពនៃជម្លោះប្រដាប់អាវុធ ក្នុងអំឡុងពេលដែលមានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ឬអំពើដែលត្រូវបានចោទប្រកាន់ណាមួយដែលពាក់ព័ន្ធនៅក្នុងដីកានោះដែរ[9]។

---

[6] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ៦ (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* សេចក្តីសម្រេចលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ១៥៖ "នៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងមិនបានបដិសេធចោលនូវលទ្ធភាពនៃការដាក់បញ្ចូលការចោទប្រកាន់ ឬបទចោទបន្ថែម នៅក្នុងការជំនុំជម្រះដំណាក់ដំបូងក្នុងសំណុំរឿង ០០២ ឡើយ នៅពេលដែលកាលៈទេសៈអនុញ្ញាត"។

[7] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៥។

[8] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ៧៖ "បទចោទទាំងអស់ *ដូចជា* បទប្រល័យពូជសាសន៍ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ត្រូវទុកដើម្បីលើកយកទៅដេញដោលនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីក្រោយៗទៀត នៅក្នុងសំណុំរឿង ០០២"។

[9] *សូមមើល* សេចក្តីសម្រេចលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ១៣ និង ឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។ *សូមមើលផងដែរ* អនុស្សរណៈពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ការឆ្លើយតបទៅនឹងបញ្ហានានាដែលបានលើកឡើងដោយភាគីមុនពេលសវនាការ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំក្រៅផ្លូវការជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១, ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ២៖ "បញ្ហាភ័ស្តុតាងដែលត្រូវយកមកពិនិត្យនៅក្នុងសវនាការដំណាក់កាលដំបូងត្រូវបានកំណត់ត្រឹមការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២)។ បន្ទាប់មក ពុំមានការពិនិត្យទៅលើការអនុវត្តនូវគោលនយោបាយណាក្រៅពីការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ (ដំណាក់កាលទី១ និងទី២) ទេ ...។ ពុំមានការអនុញ្ញាតឲ្យពិនិត្យទៅលើប្រធានផ្សេងដែលនឹងត្រូវលើកមកក្នុងសវនាការដំណាក់កាលក្រោយៗមកទៀតទេ"។ *ប្រៀបធៀប* ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ D427, កថាខណ្ឌ ១៩០ និងកថាខណ្ឌបន្តបន្ទាប់ទៀតដែលបានលើកឡើងថា "ជម្លោះប្រដាប់អាវុធជាអន្តរជាតិមួយដែលជាការប្រឈមមុខដាក់គ្នារវាងសាធារណរដ្ឋសង្គមនិយមវៀតណាម និងកម្ពុជាប្រជាធិបតេយ្យ បានផ្ទុះឡើងសឹងតែភ្លាមៗ បន្ទាប់ពីកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ("CPNLAF") បានចូលកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ ជម្លោះប្រដាប់អាវុធនេះបានអូសបន្លាយ

១២. ប្រសិនបើសំណើរបស់ ក.ស.ព[10] ដែលស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនង ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបដិសេធនោះ (ទោះ ដោយសារមូលហេតុនៃការអាចទទួលយកបានក្ដី ឬដោយសារបញ្ហាអង្គសេចក្ដី) "សវនាការដំណាក់កាលដំបូង" នឹងបញ្ចប់ដោយស្វ័យប្រវត្តិ ព្រោះថាធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ពោលគឺ ទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ) មិនអាចត្រូវបានបញ្ជាក់ដោយផ្អែកលើភ័ស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានអះអាងថា ខ្លួនមានបំណងនឹងបើកសវនាការក្នុងកិច្ចដំណើរការនីតិវិធី "សវនាការដំណាក់កាលដំបូង"[11]។ សេណារីយ៉ូនេះនឹងមិនអាចត្រូវដោះស្រាយបាន តាមរយៈការកែប្រែដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីទេ ដែលនៅដំណាក់កាលនេះ នឹងធ្វើឲ្យប៉ះពាល់ដល់ការការពារសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានឱកាសក្នុងការរៀបចំការការពារខ្លួនប្រកបដោយប្រសិទ្ធភាពមិនខាន។

### ៣. សិទ្ធិទទួលបានការកាត់សេចក្ដីត្រឹមត្រូវ

១៣. ដោយអនុម័តយកការបកស្រាយតាមន័យទូលាយនូវវិធាន ១០៤(៤)(ក) ទៅតាមអត្ថន័យនៃវិធាន ២១ និង មាត្រា ៣៣ថ្មី មាត្រា ៣៥ថ្មី និង មាត្រា ៣៧ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក អង្គជំនុំជម្រះតុលាការកំពូលមានយុត្តាធិការក្នុងការសន្និដ្ឋានថា "សវនាការដំណាក់កាលដំបូង" នឹងបានបញ្ចប់កិច្ចដំណើរការនីតិវិធី ប៉ុន្តែវាមិនដូច្នេះទេដោយសារតែសេចក្ដីសម្រេចដែលត្រូវបានជំទាស់នេះ។ អង្គជំនុំជម្រះតុលាការកំពូលអាចទទួលយកយុត្តាធិការលើបណ្ដឹងសាទុក្ខភ្លាមៗនេះបាន ដោយអនុលោមតាមវិធាន ១០៤(៤)(ក) ដោយផ្អែកលើមូលដ្ឋាននេះ។

១៤. មាត្រា ៣៣ថ្មី មាត្រា ៣៥ថ្មី និង មាត្រា ៣៧ថ្មី[12] នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងវិធាន ២១

---

យ៉ាងហោចណាស់រហូតដល់ពេលដែលកងទ័ពវៀតណាមបានវាយចូលដល់ទីក្រុងភ្នំពេញនាថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៧៩ និងនៅពេលក្រោយៗមកទៀត"។

[10] សំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារលេខ E95 ("សំណើ")។

[11] *សូមមើល* សេចក្ដីសម្រេចលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, ឧបសម្ព័ន្ធ។

[12] មាត្រា ៣៧ថ្មី ចែងថា៖ "ប្រការដែលបានចែងនៅក្នុងមាត្រា ៣៤ និង៣៥ ត្រូវអនុវត្តដូចគ្នា *(mutatis mutandi)* ចំពោះការជំនុំជម្រះក្ដីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូល"។

រួមគ្នា ធានាថាសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានសវនាការត្រឹមត្រូវ ត្រូវបានគោរព យ៉ាងពេញលេញនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ មាត្រា ៣៣ថ្មី តម្រូវថា កិច្ចដំណើរការនីតិវិធីត្រូវ "ប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ និងឆាប់រហ័ស ... ដោយមានការគោរពយ៉ាងពេញលេញដល់សិទ្ធិរបស់ជនជាប់ចោទ"។ អង្គជំនុំជម្រះតុលាការកំពូលត្រូវអនុវត្ត "យុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ដូចដែលមានចែងក្នុងមាត្រា ១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ ១៩៦៦ [("ICCPR")]"។ មាត្រា ១៤(៥) នៃ ICCPR បានធានាថា "ជនគ្រប់រូបដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឲ្យសាលាក្តីជាន់ខ្ពស់ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសឡើងវិញស្របតាមច្បាប់"[13]។ នេះមានន័យថា ប្រសិនបើច្បាប់ចែងពីដំណោះស្រាយតាមរយៈធ្វើបណ្តឹងឧទ្ធរណ៍ លទ្ធភាពប្រើប្រាស់ដំណោះស្រាយនេះមិនមែនកំហិតត្រឹមតែខ្លឹមសាររបស់វា ឬក្នុងវិធីមួយគ្មានសមាមាត្រទេ។ មាត្រា ១៤(៣) បានផ្តល់សិទ្ធិដល់ លោក អៀង សារី ក្នុងការទទួលបានការធានាកម្រិតអប្បបរមាឲ្យមានសវនាការត្រឹមត្រូវ ដោយរួមមានសិទ្ធិ៖ **ក**.ទទួលបានព័ត៌មានឲ្យបានលឿន និងមានលក្ខណៈពិស្តារ អំពីលក្ខណៈ និងមូលហេតុនៃការចោទប្រកាន់ប្រឆាំងនឹងរូបគាត់ផងដែរ និង **ខ**. ទទួលការកាត់ទោសដោយគ្មានការពន្យារពេល[14]។ សិទ្ធិក្នុងការទទួលបានព័ត៌មានឲ្យបានលឿន និងមានលក្ខណៈពិស្តារ អំពីលក្ខណៈ និង

---

[13] *សូមមើល រឿងក្តី Poitrimol តទល់នឹង ប្រទេសបារាំង,* សំណុំរឿងលេខ Eur Ct. H.R. 14032/88, សាលដីកាចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣, កថាខណ្ឌ ៣៥-៣៨ *រឿងក្តី Bogdanka Dimova តទល់នឹង ប្រទេសប៊ុលហ្គារី,* សំណុំរឿងលេខ Eur. Comm. H. R. App. No. 31806/96, របាយការណ៍របស់គណៈកម្មការ, ចុះថ្ងៃទី ២១ ខែ វិច្ឆិកា, កថាខណ្ឌ ៥២-៥៩ (ដោយសម្រេចថាប្រសិនបើច្រានចោលបណ្តឹងណាមួយដែលសុំឲ្យពិនិត្យឡើងវិញ ឬបដិសេធចោល គឺជាលទ្ធផលនៃការលុបចោលផ្នែកណាមួយនៃតុលាការ ការលុបចោលនេះនឹងរំលោភដល់សិទ្ធិក្នុងការចូលរួមនេះហើយ)។

[14] *សូមមើល* U.N. CCPR, សេចក្តីអធិប្បាយជាទូទៅលេខ ៣២, មាត្រា ១៤៖ "សិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី និង សិទ្ធិទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌, ឯកសារ អ.ស.ប លេខ CCPR/C/GC/32, ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧, កថាខណ្ឌ៖ "សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការកាត់សេចក្តីដោយពុំមានពន្យារពេល ដែលមានចែងក្នុងមាត្រា ១៤, កថាខណ្ឌ ៣(គ) គឺមិនត្រឹមតែបង្កើតឡើងដើម្បីបញ្ចៀសមិនឲ្យទុកឲ្យជនជាប់ចោទស្ថិតក្នុងភាពមិនច្បាស់លាស់ចំពោះជោគវាសនារបស់ខ្លួនក្នុងរយៈពេលយូរពេកទេ ប្រសិនបើជនជាប់ចោទត្រូវបានឃុំឃាំងក្នុងអំឡុងពេលសវនាការនោះ ដើម្បីធានាថា នៅក្នុងករណីជាក់លាក់ ការដកហូតសិទ្ធិបែបនេះមិនត្រូវមានរយៈពេលយូរជាងការចាំបាច់នោះទេ តែក៏សម្រាប់បម្រើឲ្យប្រយោជន៍នៃយុត្តិធម៌ដែរ។ អ្វីដែលជាការសមហេតុសមផលសម្រាប់យកទៅវាយតម្លៃនៅក្នុងកាលៈទេសៈនៃករណីនីមួយៗ ដោយរាប់បញ្ចូលយ៉ាងសំខាន់នូវភាពស្មុគស្មាញនៃករណីនោះផង ការប្រព្រឹត្តរបស់ជនជាប់ចោទ និងលក្ខណៈ

មូលហេតុនៃការចោទប្រកាន់ប្រឆាំងនឹងរូបគាត់ មានន័យថា មិនត្រូវរំពឹងថា មេធាវីការពារក្តីត្រូវធ្វើការប៉ាន់ស្មានអំពីវិធី និងថាតើភាគីនឹងត្រូវទទួលយកដើម្បីផ្តល់ភស្តុតាងទាក់ទងនឹងអត្ថិភាពនៃជម្លោះប្រដាប់អាវុធនៅក្នុងសវនាការដំណាក់កាលដំបូងទេ[15]។ មាត្រា ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក៏បានបញ្ជាក់យ៉ាងច្បាស់អំពីសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបាននូវការធានាកម្រិតអប្បបរមាឲ្យមានការកាត់សេចក្តីដោយត្រឹមត្រូវនេះផងដែរ។

១៥. មាត្រា ២១ ចែងថា លិខិតុបករណ៍សំខាន់របស់ អ.វ.ត.ក រួមទាំងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុងផងដែរ "ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍ ... ជនជាប់ចោទ ... ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀង"។ ដើម្បីសម្រេចគោលដៅនេះ "កិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ត្រូវតែមានភាពយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"។

---

ដែលបញ្ហានោះត្រូវបានឆ្លើយតបដោយអាជ្ញាធរខាងផ្នែករដ្ឋបាល និងតុលាការនោះ ...។ <u>ការធានានេះមិនត្រឹមតែពាក់ព័ន្ធជាមួយពេលវេលារវាងការចោទប្រកាន់ទោសជាផ្លូវការចំពោះជនជាប់ចោទ និងរយៈពេលដែលការកាត់សេចក្តីគួរតែចាប់ផ្តើមដំណើរការនោះប៉ុណ្ណោះទេ តែក៏ពាក់ព័ន្ធផងដែរទៅនឹងពេលវេលារហូតដល់ពេលសាលដីកាស្ថាពរលើបណ្តឹងសាទុក្ខ។ គ្រប់ដំណាក់កាលទាំងអស់ ទោះបីស្ថិតនៅក្នុងតុលាការថ្នាក់ទី១ ឬទៅលើបណ្តឹងសាទុក្ខក៏ដោយ ក៏ត្រូវដំណើរការ "ដោយពុំមានការពន្យារពេលឡើយ"</u>"។ (គូសបញ្ជាក់បន្ថែម អត្ថបទដកស្រង់ខាងក្នុងត្រូវបានលុបចោល), *អាចរកបាននៅគេហទំព័រ៖* http://daccess-dds-ny.un.org/doc/UNDOC/GEN/G07/437/71/PDF/G0743771.pdf?OpenElement។

[15] *សូមមើល* STEFAN TRECHSEL, HUMAN RIGHTS IN CRIMINAL PROCEEDINGS 203 (Oxford University Press, 2005)៖ "សូម្បីតែមានការសន្និដ្ឋានថា មានកំហុសបច្ចេកទេសបានកើតឡើងក្នុងពេលរៀបចំសេចក្តីព្រាងនៃដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះនោះ ការបកស្រាយសមហេតុសមផលនូវមាត្រា ៦(៣)(ក) [នៃ ECHR ពោលគឺសិទ្ធិរបស់ជនជាប់ចោទ "ក្នុងការទទួលបានព័ត៌មានសមរម្យ តាមភាសាមួយដែលជនជាប់ចោទអាចយល់បាន និងមានលក្ខណៈពិស្តារ អំពីលក្ខណៈ និងសំអាងហេតុនូវការចោទប្រកាន់ប្រឆាំងជនជាប់ចោទនោះ"] តម្រូវថា សិទ្ធិនេះត្រូវបានយកទៅអនុវត្តយ៉ាងតឹងរ៉ឹង ហើយថា គេមិនគួររំពឹងឲ្យចុងចោទធ្វើការទស្សន៍ទាយដោយប្រាជ្ញានោះទេ។ អ្នកដែលប្រព្រឹត្តកំហុសត្រូវយកចិត្តទុកដាក់ចំពោះ ផលវិបាកនៃកំហុសឆ្គងទាំងនោះ គេមិនអាចទទួលយកបានទេថា ចុងចោទជាអ្នកទទួលរងនូវកំហុសដែលប្រព្រឹត្តឡើងដោយភាគីរដ្ឋអាជ្ញា" នោះ។ មេធាវីការពារក្តីសូមលើកឡើងថា ក្នុងការជំនុំជម្រះទោស អង្គជំនុំជម្រះសាលាដំបូងគួរអនុវត្តគោលការណ៍នេះឲ្យបានដូចគ្នា *(mutatis mutandi)* ទាំងនៅក្នុងកាលៈទេសៈទាំងនេះ និងទាំងក្នុងកាលៈទេសៈដទៃទៀតដែរ។

## ៤. ការបកស្រាយតាមន័យទូលាយចំពោះវិធាន ១០៤(៤)(ក) តាមអត្ថន័យនៃវិធាន ២១ និង មាត្រា ៣៣ ថ្មី មាត្រា ៣៥ ថ្មី និង មាត្រា ៣៧ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺជាការចាំបាច់

១៦. អង្គជំនុំជម្រះតុលាការកំពូលគួរតែអនុម័តយកនូវការបកស្រាយតាមន័យទូលាយចំពោះសិទ្ធិក្នុងការប្តឹងសាទុក្ខភ្លាមៗនៅក្នុងកាលៈទេសៈពិសេសនេះ ដើម្បីការពារសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការកាត់សេចក្តីត្រឹមត្រូវ ដើម្បី៖ ក.ឲ្យការវិនិច្ឆ័យទោស និងផ្តន្ទាទោសដែលអាចនឹងកើតមាន ត្រូវបានពិនិត្យសាជាថ្មីដោយស្ថាប័នតុលាការជាន់ខ្ពស់អនុលោមទៅតាមច្បាប់[16] ខ.ទទួលបានព័ត៌មានឲ្យបានលឿន និងមានលក្ខណៈពិស្តារ អំពីលក្ខណៈ និងមូលហេតុនៃការចោទប្រកាន់ប្រឆាំងនឹងរូបគាត់[17] និង គ.ទទួលការកាត់ទោសដោយពុំពន្យារពេល[18]។

១៧. ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលសម្រេចជាស្ថាពរថា លក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ <u>ពិតជា</u>បង្កើតបានជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បន្ទាប់ពីមានបណ្តឹងសាទុក្ខទៅលើសាលក្រមដំបូងនៅក្នុង "សវនាការដំណាក់កាលដំបូង" (ដូចមានចែងក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី)[19] អង្គជំនុំជម្រះតុលាការកំពូលចាំបាច់ត្រូវសម្រេចទៅលើបញ្ហាអង្គហេតុនានាដូចតទៅ៖ ក. តើជម្លោះប្រដាប់អាវុធបែបនេះមានអត្ថិភាពក្នុងអំឡុងពេលដែលបានលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះឬទេ និង ខ. តើអំពើនានាដែលត្រូវបានចោទប្រកាន់ថាបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានទំនាក់ទំនងគ្រប់គ្រាន់ជាមួយជម្លោះប្រដាប់អាវុធនេះឬទេ។ ប៉ុន្តែ ប្រសិនបើភាគីមិនត្រូវបានអនុញ្ញាតឲ្យផ្តល់ភស្តុតាងស្តីពីបញ្ហាទាំងនេះក្នុងអំឡុងពេល "សវនាការដំណាក់កាលដំបូង" ទេ

---

[16] ICCPR, មាត្រា ១៤(៣)។

[17] *ដូចជើងទំព័រខាងលើ*, មាត្រា ១៤(៣)(ក)។

[18] *ដូចជើងទំព័រខាងលើ*, មាត្រា ១៤(៣)(គ)។

[19] អង្គជំនុំជម្រះសាលាដំបូងបានអះអាងពីចេតនារបស់ខ្លួន "ចេញសាលក្រមដំបូងដែលកំណត់ត្រឹមបទចោទ និងការចោទប្រកាន់លើអង្គហេតុមួយចំនួននៅដំណាក់កាលដំបូង ដោយមិនចាំបាច់រង់ចាំការបញ្ចប់ការជំនុំជម្រះទាំងមូល ទាក់ទិននឹងគ្រប់ផ្នែកទាំងអស់នៃដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះឡើយ", សេចក្តីសម្រេចលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៨។

នោះ (ករណីនេះអាចនឹងកើតឡើង ប្រសិនបើសេចក្តីសម្រេចដែលត្រូវបានជំទាស់នេះមិនត្រូវបានផ្អាក ឬត្រូវកំណត់ថាជាមោឃៈភ្លាមៗនោះទេ) អង្គជំនុំជម្រះតុលាការកំពូល "មិនទទួលបាន" ភស្តុតាងនេះទេ ហើយកំណត់ហេតុនៃសវនាការនឹងពុំមានភស្តុតាងគ្រប់គ្រាន់ ដែលអាចឱ្យអង្គជំនុំជម្រះនេះសម្រេច "យ៉ាងច្បាស់លាស់" ទៅលើអង្គហេតុឱ្យបានសមរម្យនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវមានសវនាការពិនិត្យភស្តុតាងបន្ថែមលើបញ្ហានេះដោយអនុលោមតាមវិធាន ១០៨(៧)[20]។ នឹងគ្មានការផ្តល់ភស្តុតាងអំពីបញ្ហាស្តីពីទំនាក់ទំនងនេះទេនៅពេលសវនាការ។ ដូច្នេះ ភាគីដាក់សំណើនឹងមិនអាចបំពេញតាមលក្ខខណ្ឌតម្រូវក្នុងវិធាន ១០៨ (៧) ដែលថា គាត់ "កំណត់យ៉ាងច្បាស់អំពីសំអាងហេតុជាក់លាក់ដែលអង្គជំនុំជម្រះសាលាដំបូងមាន ដែលត្រូវបានបង្គាប់ឱ្យមានភស្តុតាងបន្ថែម"។

១៨. សេណារីយ៉ូនេះ ដែល៖ **ក**. កម្រិតសិទ្ធិរបស់លោក អៀង សារី ក្នុងការប្តឹងសាទុក្ខ "ទៅតាមខ្លឹមសាររបស់វា" **ខ**. តម្រូវឱ្យមេធាវីការពារក្តីចូលរួមក្នុង "ការទស្សន៍ទាយដោយប្រើប្រាជ្ញា" ដោយសារដីកា និងសេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះសាលាដំបូង និង **គ**. ពន្យារពេលមិនចាំបាច់ក្នុងការចេញសេចក្តីសម្រេចទៅលើបញ្ហាសត្យានុម័ត នឹងរំលោភសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបាន៖ **ក**.ការប្តឹងសាទុក្ខទៅកាន់តុលាការជាន់ខ្ពស់តាមផ្លូវច្បាប់ **ខ**.ទទួលបានព័ត៌មានឱ្យបានលឿន និងមានលក្ខណៈពិស្តារ អំពីលក្ខណៈ និងមូលហេតុនៃការចោទប្រកាន់ប្រឆាំងនឹងរូបគាត់ និង **គ**. ទទួលការកាត់ទោសដោយពុំពន្យារពេល។ ការរំលោភបំពានទាំងនេះអាចនឹងដោះស្រាយបានតាមរយៈការសម្រេចលើបណ្តឹងសាទុក្ខនេះដោយភ្លាមៗ។ លោក អៀង សារី មានសិទ្ធិជាសារវន្តក្នុងការទទួលបានព័ត៌មានអំពីធាតុផ្សំនៃអំពើឧក្រិដ្ឋទាំងអស់ដែលគាត់ត្រូវបានចោទប្រកាន់មកលើគាត់ មុននឹងចាប់ផ្តើមដំណើរការសវនាការ។

## គ. សំណើសុំឱ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈ

[20] វិធាន ១០៨(៧) ចែងថា៖ "ភាគីអាចស្នើសុំបន្ថែមភស្តុតាងចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល យោងតាមវិធាន ៨៧(៣) បើសិនជាភស្តុតាងនោះ មិនអាចរកបានក្នុងពេលសវនាការ ហើយដែលអាចជាកត្តាកំណត់នាំឱ្យឈានដល់ការធ្វើសេចក្តីសម្រេចនៅក្នុងសវនាការ។ សេចក្តីស្នើសុំបន្ថែមភស្តុតាងត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីទំនាក់ទំនង ដោយផ្ទាល់រវាងភស្តុតាងបន្ថែមថ្មីនោះ ជាមួយនឹងសម្អាងហេតុជាក់លាក់ ដែលអង្គជំនុំជម្រះសាលាដំបូងបានលើក។ ភាគីផ្សេងទៀតដែលរងការប៉ះពាល់ដោយសេចក្តីស្នើសុំនេះ អាចធ្វើការឆ្លើយតបក្នុងរយៈពេល១៥ថ្ងៃ ចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីសេចក្តីស្នើសុំនោះ"។

១៩. មេធាវីការពារក្តីសូមស្នើឲ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈមួយ ដើម្បីដោះស្រាយបញ្ហាផ្សេងៗដែលលើកឡើងនៅក្នុងបណ្តឹងសាទុក្ខនេះ។ វិធាន ១០៩ (១) ចែងថា ជាទូទៅ សវនាការនឹងត្រូវរៀបចំធ្វើជាសាធារណៈ[21]។ បណ្តឹងសាទុក្ខនេះប៉ះពាល់ដល់សិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការកាត់សេចក្តីដោយត្រឹមត្រូវ និងប៉ះពាល់ដល់ដំណើរការនីតិវិធីនាពេលអនាគតផង ដូច្នេះ វាជាប្រយោជន៍របស់សាធារណជនកម្ពុជា។ គ្មានបញ្ហាណាមួយដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខនេះ ជាបញ្ហាសម្ងាត់ឡើយ។

## IV. ច្បាប់ជាធរមាន

### ក. គោលការណ៍នីត្យានុកូលភាព

២០. គោលការណ៍នីត្យានុកូលភាពចែងថា ជនជាប់ចោទមិនអាចត្រូវបានផ្តន្ទាទោសចំពោះបទឧក្រិដ្ឋដែលមិនមានចែងក្នុងច្បាប់នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តនោះទេ[22]។ គោលការណ៍នេះមានចែងនៅក្នុងមាត្រា ៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ យ៉ាងដូច្នេះថា[23]៖

> ច្បាប់ព្រហ្មទណ្ឌគ្មានអានុភាពជាប្រតិសកម្មទេ គឺថា បទល្មើសណាបានប្រព្រឹត្តិមុនបទប្បញ្ញត្តិរបស់ច្បាប់ បទល្មើសនោះមិនអាចត្រូវនិគ្រោះដោយទោសរបស់ច្បាប់ ដែលទើបនឹងបញ្ញត្តិថ្មីនេះបានទេ។
>
> ប៉ុន្តែ បើច្បាប់ថ្មីលុបចោលបទល្មើសណាមួយ ឬសម្រាលទោសរបស់បទល្មើសណាមួយវិញ បទល្មើសដែលបានប្រព្រឹត្តិមុនច្បាប់ថ្មីនេះត្រូវបានរួចផុតពីទោស ឬក៏ទោសនោះត្រូវបានស្រាលតាមច្បាប់ថ្មីនេះដែរ កុំឲ្យតែបទល្មើសនោះបានទទួលផ្តន្ទាជាស្ថាពររួចអស់ទៅហើយ។

---

[21] វិធាន ១០៩(១) ចែងថា៖ "សវនាការនៃអង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើឡើងជាសាធារណៈ។ អង្គជំនុំជម្រះតុលាការកំពូលអាច ធ្វើសេចក្តីសម្រេចពិចារណាលើបណ្តឹងសាទុក្ខភ្លាមៗ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍ដែលដាក់ដោយភាគីតែប៉ុណ្ណោះ"។

[22] *សូមមើល* មាត្រា ៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦; ICCPR, មាត្រា ១៥។

[23] បកប្រែក្រៅផ្លូវការពីភាសាបារាំង។

២១. គោលការណ៍នេះក៏មានចែងផងដែរនៅក្នុងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និង ICCPR ដែលត្រូវតែគោរពដោយអនុលោមតាមរដ្ឋធម្មនុញ្ញ កិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[24]។ មាត្រា ១៥ នៃ ICCPR ចែងអំពីគោលការណ៍នេះយ៉ាងដូច្នេះថា៖

> ១.គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានណាមួយ ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នានេះ មិនត្រូវដាក់ទោសឲ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ។ ប្រសិនបើក្រោយពីការប្រព្រឹត្តបទល្មើសហើយ ច្បាប់បានបញ្ញត្តិឲ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ។
>
> ២.គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះប្រឆាំងនឹងការជំនុំជម្រះក្តី ឬការផ្តន្ទាទោស

[24] បើតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ១៩៩៩ (“រដ្ឋធម្មនុញ្ញ”) ចែងថា៖ “ព្រះរាជាណាចក្រកម្ពុជា *ទទួលស្គាល់និងគោរព*សិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ” (គូសបញ្ជាក់បន្ថែម)។ បើតាមមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា៖ “អង្គជំនុំជម្រះវិសាមញ្ញរបស់សាលា ដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្រប តាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ”។ បើតាមមាត្រា ១៣(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យចែងថា៖ “សិទ្ធិរបស់ជនជាប់ចោទដែលមានចែងនៅក្នុងមាត្រា ១៤ និ ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី។ គោលការណ៍នីត្យានុកូលភាពក៏ត្រូវបានគាំទ្រស្រដៀងគ្នាដែរនៅក្នុងលិខិតុបករណ៍ដទៃទៀតស្តីពីសិទ្ធិមនុស្សដែរ។ *សូមមើល* ECHR, មាត្រា ៧; អនុសញ្ញាអន្តរអាមេរិកាំងស្តីពីសិទ្ធិមនុស្ស, មាត្រា ៩; ធម្មនុញ្ញស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជននៅទ្វីបអាហ្វ្រិក, មាត្រា ៧(២); លក្ខន្តិកៈតុលាការ ICC, មាត្រា ២២, ២៤; អនុសញ្ញាទីក្រុងហ្សឺណែវទីបីឆ្នាំ ១៩៤៩, មាត្រា ៩៩; អនុសញ្ញាទីក្រុងហ្សឺណែវទីបួនឆ្នាំ ១៩៤៩, មាត្រា ៦៧។ គោលការណ៍នេះក៏ត្រូវបានទទួលស្គាល់ដោយតុលាការ ICTY ដែរ។ *សូមមើលជាឧទាហរណ៍ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Vasiljević,* សំណុំរឿងលេខ IT-98-32-T, សាលក្រម, ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២, កថាខណ្ឌ ១៩៣; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Galić,* សំណុំរឿង IT-98-29-T, សាលក្រម, ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៣, កថាខណ្ឌ ៩២។

ដល់ជនណាម្នាក់ចំពោះអំពើ ឬការខកខានណាមួយ ដែលនៅពេលដែលប្រព្រឹត្តបទល្មើសនោះ អំពើនោះជាអំពើឧក្រិដ្ឋ យោងតាមគោលការណ៍ច្បាប់ដែលត្រូវបានទទួលស្គាល់ដោយសហគមន៍ប្រជាជាតិ។

២២. ដើម្បីបំពេញតាមគោលការណ៍នីត្យានុកូលភាពនៅ អ.វ.ត.ក ដូចដែលបញ្ជាក់យ៉ាងច្បាស់ដោយអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងនោះ[25] ត្រូវបំពេញលក្ខខណ្ឌនានាដូចតទៅនេះ៖ **ក.** អំពើឧក្រិដ្ឋចាំបាច់ត្រូវមានចែងក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និង **ខ.**អំពើឧក្រិដ្ឋត្រូវមានចែងក្នុងច្បាប់ជាតិ អន្តរជាតិ ឬនៅក្នុងគោលការណ៍ទូទៅនៃច្បាប់ ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ ក្នុងខណៈពេលដែលប្រព្រឹត្តអំពើឧក្រិដ្ឋនោះ[26]។

២៣. នៅពេលដែលលក្ខខណ្ឌខាងលើត្រូវបានបំពេញរួចហើយ គេត្រូវបង្ហាញថា ជនត្រូវចោទ/ជនជាប់ចោទ អាចប្រមើលមើលដឹងថាជាបទល្មើស និងដឹងថាមានច្បាប់ចែងផងដែរ[27]។ ពាក់ព័ន្ធនឹងការដែលអាចប្រមើលមើលដឹងថាអំពើនោះជាបទល្មើសបាន ជនជាប់ចោទត្រូវតែអាចវាយតម្លៃដឹងបានថា អំពើនោះជាបទល្មើសព្រហ្មទណ្ឌក្នុងន័យដែលអាចដឹងបានជាទូទៅ ដោយមិនយោងទៅ

---

[25] *សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១, ឯកសារលេខ D427/1/30 ("សាលដីការបស់អង្គបុរេជំនុំជម្រះ"), កថាខណ្ឌ ២២៦; *រឿងក្តី កាំង ហ្កេកអ៊ាវ ហៅ "ឌុច"*, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសង, សាលក្រម, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, ឯកសារលេខ E188 ("*សាលក្រម ឌុច*"), កថាខណ្ឌ ២៧-២៨។

[26] មេធាវីការពារក្តីលោក អៀង សារី បានជំទាស់ទៅនឹងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាទម្រង់លាតសន្ធឹងនេះ ទោះបីអង្គជំនុំជម្រះសាលាដំបូងមិនទាន់បានចេញសេចក្តីសម្រេចលើបញ្ហានេះក៏ដោយ។ មាត្រា ៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ តម្រូវថា ច្បាប់ត្រូវតែមានចែងនៅក្នុងច្បាប់ជាតិជាធរមាននៅពេលដែលអំពើឧក្រិដ្ឋនោះត្រូវបានប្រព្រឹត្ត។ ហេតុនេះ មេធាវីការពារក្តីជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះដែលថា គោលការណ៍នីត្យានុកូលភាពអាចបំពេញបាន ប្រសិនបើច្បាប់មួយមាននៅក្នុងច្បាប់អន្តរជាតិ ឬនៅក្នុងគោលការណ៍ទូទៅនៃច្បាប់។ *សូមមើល* សេចក្តីសង្ខេបអញ្ញត្រកម្មតាមវិធាន ៨៩ របស់លោក អៀង សារី និងការជូនដំណឹងនៃការមិនគោរពតាមអនុស្សរណៈក្រៅផ្លូវការនានានាពេលអនាគត ដែលត្រូវបានចេញជំនួសឲ្យសេចក្តីសម្រេចមានសំអាងហេតុរបស់តុលាការ ដែលជាកម្មវត្ថុបណ្តឹងឧទ្ធរណ៍, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារលេខ E51/4, ដោយយោងទៅដល់អញ្ញត្រកម្មរបស់លោក អៀង សារី ដែលថា អ.វ.ត.ក ពុំមានយុត្តាធិការដើម្បីអនុវត្តអំពើឧក្រិដ្ឋអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវដែលប្រឆាំងនឹងរូបគាត់ទេ។

[27] សាលដីការបស់អង្គបុរេជំនុំជម្រះ, កថាខណ្ឌ ២២៩; សាលក្រមលើសំណុំរឿង *ឌុច*, កថាខណ្ឌ ២៨, ៣១។

ដល់បទប្បញ្ញត្តិជាក់លាក់ណាមួយឡើយ[28]។ ពាក់ព័ន្ធនឹងការដែលអាចដឹងថាអំពើនោះមានចែងក្នុងច្បាប់ គេអាចពឹងផ្អែកលើច្បាប់ដែលមានមូលដ្ឋានពីទំនៀមទម្លាប់បាន[29]។

២៤.

## ខ. ច្បាប់ទំនៀមទម្លាប់អន្តរជាតិ

២៥. ច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវបានកំណត់ឡើងដោយធាតុផ្សំចំនួនពីរគឺ៖ ការអនុវត្តរបស់រដ្ឋ និង *សច្ចាធារណ៍ធម្មានុរូប* (opinio juris)[30]។ តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICJ") បានថ្លែងថា៖ "ចំពោះច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទស្សនៈដែលបានចែករំលែករវាងភាគីចំពោះខ្លឹមសារនៃអ្វីដែលគេចាត់ទុកថាជាវិធាន [ទំនៀមទម្លាប់] មិនទាន់គ្រប់គ្រាន់ទេ។ តុលាការត្រូវទទួលស្គាល់ថាអត្ថិភាពនៃវិធាននោះនៅក្នុង*សច្ចាធារណ៍ធម្មានុរូប* (opinio juris) របស់រដ្ឋ ត្រូវបានបញ្ជាក់ដោយការអនុវត្ត"[31]។ ទោះបីការអនុវត្តរបស់រដ្ឋគួរតែ "ទូលំទូលាយ និងមានឯកភាពគ្នាជាក់ស្តែងដើម្បីយកបទប្បញ្ញត្តិនោះមកប្រើប្រាស់"[32] ក៏ដោយ ក៏ការអនុវត្តរបស់រដ្ឋមិនគួរ "ត្រូវតែស្របដាច់ខាត

---

[28] សាលដីការបស់អង្គបុរេជំនុំជម្រះ, កថាខណ្ឌ ២៣៥; សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE), ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០, ឯកសារលេខ D97/14/15 ("សាលដីការបស់អង្គបុរេជំនុំជម្រះលើ JCE"), កថាខណ្ឌ ៤៥។

[29] សាលដីការបស់អង្គបុរេជំនុំជម្រះ, កថាខណ្ឌ ២៣៥; សាលដីការបស់អង្គបុរេជំនុំជម្រះលើ JCE, កថាខណ្ឌ ២៤៥។

[30] *សូមមើល រឿងក្តី North Sea Continental Shelf Cases (Libyan Arab Jamahirya/Malta), សាលក្រម, របាយការណ៍របស់តុលាការ I.C.J ឆ្នាំ ១៩៨៥,* ទំព័រ ២៩-៣០, កថាខណ្ឌ ២៧៖ "វាជាការពិតដែលថា ធាតុសម្ភារៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិគឺត្រូវមើលជាបឋមទៅក្នុងការអនុវត្តជាក់ស្តែង និង*សច្ចាធារណ៍ធម្មានុរូប (opinio juris)* របស់រដ្ឋ"។

[31] *រឿងក្តីពាក់ពាក់ព័ន្ធនឹងសកម្មភាពយោធា និងជីវពលនៅក្នុង និង ប្រឆាំងនឹងប្រទេសនីការ៉ាហ្គា (រឿងក្តី ប្រទេសនីការ៉ាហ្គា តទល់នឹង សហរដ្ឋអាមេរិក), សាលក្រម, របាយការណ៍របស់តុលាការ I.C.J ឆ្នាំ ១៩៨៦,* ទំព័រ ៩៨, កថាខណ្ឌ ១៨៤ *("រឿងក្តី ប្រទេសនីការ៉ាហ្គា")*។

[32] *រឿងក្តី North Sea Continental Shelf Cases (ប្រទេសអាល្លឺម៉ង់ តទល់នឹងប្រទេសដាណឺម៉ាក, ប្រទេសអាល្លឺម៉ង់ តទល់នឹង ប្រទេសហូឡង់), សាលក្រម, របាយការណ៍របស់តុលាការ I.C.J ឆ្នាំ ១៩៦៩,* ទំព័រ ៤៣, កថាខណ្ឌ ៧៤; ទំព័រ ៤៤, កថាខណ្ឌ ៧៧ *("រឿងក្តី North Sea Continental Shelf Cases")*។ *សូមមើលផងដែរ រឿងក្តីសុំសិទ្ធិជ្រកកោន (ប្រទេសកូឡុំប៊ី/ប៉េរូ), សាលក្រម, របាយការណ៍របស់តុលាការ I.C.J ឆ្នាំ ១៩៥០,* ទំព័រ ២៧៦; MALCOLM N. SHAW, INTERNATIONAL LAW 76 (Cambridge University Press, 6th ed., 2008) ("SHAW")។

ទៅតាមវិធាននោះទេ”[33]។

២៦. *សច្ចាធារណ៍ធម្មានុរូប* (opinio juris) ឆ្លុះបញ្ចាំងនូវទិដ្ឋភាពអត្តនោម័តរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ អំពើដែលពាក់ព័ន្ធទាំងនេះមិនមិនត្រឹមតែត្រូវតែជាការអនុវត្តរបស់រដ្ឋដែលបានសម្រេចប៉ុណ្ណោះទេ “តែអំពើទាំងនោះត្រូវតែជា ឬត្រូវបានអនុវត្តទៅតាមវិធីបែបនេះ ដែលជាភ័ស្តុតាងនៃជំនឿមួយដែលថា ការអនុវត្តនេះត្រូវបានចងជាកាតព្វកិច្ចនៅក្នុងវិធាននៃច្បាប់ដែលតម្រូវឱ្យមាន ...។ ហេតុនេះ រដ្ឋសាមីត្រូវតែយល់ថា ខ្លួនត្រូវអនុវត្តឱ្យស្របទៅតាមអ្វីដែលជាកាតព្វកិច្ចក្នុងច្បាប់ដែរ”[34]។ ប្រភពដែលពាក់ព័ន្ធនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិរួមមាន សន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីថ្លែងការណ៍របស់ប្រតិភូតំណាងរដ្ឋក្នុងអំឡុងពេលចរចា និងសេចក្តីសម្រេចរបស់ស្ថាប័នតុលាការអន្តរជាតិ[35]។

## V. **ឧទ្ធរណ៍**

២៧. អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅពេលខ្លួនសន្និដ្ឋានថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ពុំបានតម្រូវឱ្យបង្ហាញភស្តុតាងអំពីទំនាក់ទំនងរវាងអំពើឧក្រិដ្ឋនានាជាមូលដ្ឋាន ទៅនឹងជម្លោះប្រដាប់អាវុធឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើគោលការណ៍នីត្យានុកូលភាព នៅពេលដែលខ្លួនផ្លាស់ប្តូរនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយបានដកចេញនូវធាតុផ្សំមួយដែលមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ កំហុសលើអង្គច្បាប់នេះ បណ្តាលឱ្យសេចក្តីសម្រេចដែលត្រូវបានជំទាស់នេះមានមោឃភាព។ ផ្ទុយពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចំពោះបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិចារណាឱ្យទូលំទូលាយនូវរាល់ប្រភពឯកសារទាំងអស់ដែលចាំបាច់ និងដែលអាចមាន និងមិនបានបកស្រាយនូវរាល់ប្រភពឯកសារដែលខ្លួនបានដកស្រង់យកមកសំអាង ដើម្បីសម្រេចបានលទ្ធផលដែលចង់បាននោះ។ ប្រភពឯកសារនានាដែលអង្គជំនុំជម្រះសាលាដំបូងដកស្រង់យកមកសំអាង

---

33 *រឿងក្តីប្រទេសនីការ៉ាហ្គា,* ទំព័រ ៩៨, កថាខណ្ឌ ១៨៦។

34 *រឿងក្តី North Sea Continental Shelf Cases*, ទំព័រ ៤៤, កថាខណ្ឌ ៧៧។

35 *រឿងក្តីប្រទេសនីការ៉ាហ្គា,* ទំព័រ ៩៨, កថាខណ្ឌ ១៨៨-៩១។ *សូមមើលផងដែរ* SHAW, ត្រង់ទំព័រ ៨២។

មិនបានបង្ហាញពីការអនុវត្តរបស់រដ្ឋ "យ៉ាងទូលំទូលាយ និងមានឯកភាពគ្នាជាក់ស្តែង" ដែលបង្ហាញពីការពុំមានថែងនូវលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ[36]។ ប្រសិនបើមានវិញ ប្រភពឯកសារទាំងនោះនឹងគាំទ្រដល់ការធ្វើសេចក្តីសន្និដ្ឋានផ្ទុយពីនេះមិនខាន។ អង្គជំនុំជម្រះសាលាដំបូងមិនបានយកចិត្តទុកដាក់ចំពោះធាតុផ្សំសត្យានុម័តរបស់ធម្មនុញ្ញតុលាការ Nuremberg និងគោលការណ៍តុលាការ Nuremberg ចំពោះនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលបានបង្កើតឡើងក្រោយពេលបញ្ចប់សង្គ្រាមលោកលើកទី២ ភ្លាមនោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានយកចិត្តទុកដាក់តិចតួច ឬពុំបានអើពើ ដល់ការពិភាក្សាដេញដោលយោបល់នានាអំពីលក្ខខណ្ឌតម្រូវស្តីអំពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធដែលបានធ្វើឡើងរវាងបណ្តាគណៈប្រតិភូនៃរដ្ឋនានា ក្នុងអំឡុងពេលរៀបរៀងសេចក្តីព្រាងនៃលិខិតុបករណ៍អន្តរជាតិជាច្រើន ដូចជា សេចក្តីព្រាងក្រមស្តីពីអំពើល្មើសរបស់ ILC ឆ្នាំ ១៩៥៤, អនុសញ្ញាស្តីពីអាជ្ញាយុកាលឆ្នាំ ១៩៦៨ និងលក្ខន្តិកៈតុលាការ ICC នោះទេ។ អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើចំពោះភស្តុតាងដែលថា យ៉ាងហោចណាស់ក៏មានលិខិតុបករណ៍ចំនួនពីរដែរ ក្នុងចំណោមលិខិតុបករណ៍ដែលខ្លួនបានដកស្រង់យកមកធ្វើជាសំអាង រួមមានអនុសញ្ញាស្តីពីអាជ្ញាយុកាលឆ្នាំ ១៩៦៨ និងអនុសញ្ញាស្តីពីការរើសអើង (Apartheid) ឆ្នាំ ១៩៧៣ ដែលបានទទួលការគាំទ្រតិចតួចបំផុតពីបណ្តារដ្ឋជាសមាជិក អ.ស.ប ក្នុងអំឡុងអាជ្ញាយុកាលលើពេលវេលារបស់ អ.វ.ត.ក។ ប្រភពឯកសារជាច្រើនដែលដកស្រង់ដោយអង្គជំនុំជម្រះសាលាដំបូងមិនមែនជាប្រភពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលកំណត់និយមន័យដោយតុលាការ ICJ នោះទេ[37]។ ជាងនេះទៀត ទោះបីអង្គជំនុំជម្រះសាលាដំបូងមិនជាប់កាតព្វកិច្ចទៅនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះក៏ដោយ[38] ក៏អង្គជំនុំជម្រះនេះមិនបានពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយ និង

---

[36] *សូមមើល* ផ្នែក ក-ឆ *ខាងក្រោម* សម្រាប់ការវិភាគពីប្រភពឯកសារដែលបានដកស្រង់ដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសេចក្តីសម្រេចដែលត្រូវបានជំទាស់របស់ខ្លួន, កថាខណ្ឌ ១៣-៣២។

[37] អង្គជំនុំជម្រះសាលាដំបូងដកស្រង់នូវសេចក្តីប្រកាសព័ត៌មានជាច្រើនមកធ្វើជាភ័ស្តុតាងពីការគាំទ្រជាឯកច្ឆ័ន្ទក្នុងចំណោមប្រតិភូនៅឯសន្និសីទស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងចេញ។ *សូមមើល* សេចក្តីសម្រេចដែលត្រូវបានជំទាស់, លេខ ៧២-៧៤។

[38] ដូចដែលអង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា "វាជាមូលដ្ឋានសម្រាប់តុលាការ ចំពោះកិច្ចដំណើរការនីតិវិធីមួយចំនួនដែលកំពុងរង់ចាំដំណោះស្រាយ ដែលថា សេចក្តីសម្រេចលើអង្គច្បាប់នៅក្នុងរឿងក្តីមួយ នឹងជាសេចក្តីណែនាំដល់តុលាការចំពោះរឿងក្តីស្រដៀងគ្នាលើកក្រោយ នៅពេលដែលមិនមានអំណះអំណាង ឬកាលៈទេសៈថ្មីត្រូវបានលើកឡើង", *រឿងក្តី កាំង ហ្កេក*

មិនបានគោរពដល់សំអាងហេតុមុនៗរបស់អង្គបុរេជំនុំជម្រះលើបញ្ហានេះដែរ[39]។ ការវិភាគទៅលើសេចក្តីសម្រេចដែលត្រូវបានជំទាស់ខាងក្រោមនេះ ឆ្លុះបញ្ចាំងដីកាដែលអង្គជំនុំជម្រះសាលាដំបូងបានដោះស្រាយចំពោះលិខិតុបករណ៍អន្តរជាតិ និងឯកសារដទៃទៀត។

**ក. អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបកស្រាយធម្មនុញ្ញតុលាការ Nuremberg និងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង [សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១៣-២០]**

**១. ធម្មនុញ្ញតុលាការ Nuremberg**

២៨. អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា ពាក្យពេចន៍ដែលបានប្រើប្រាស់នៅក្នុងសាលក្រមនៃតុលាការ Nuremberg ពុំមានភាពច្បាស់លាស់ថាតើលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងដែលមានចែងនៅក្នុងធម្មនុញ្ញតុលាការ Nuremberg គឺជាការកំណត់ដែនសមត្ថកិច្ចយុត្តាធិការជាក់លាក់ផ្សេងពីគេ

---

*អ៊ាវ ហៅ "ឌុច",* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/កសចស (អបជ ០២) សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី សុំដោះស្រាយស្តីពីការអនុវត្តទ្រឹស្តីសហឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ជំទាស់ទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច", ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨, ឯកសារលេខ D99/3/19, កថាខណ្ឌ ១៤។ ក.ស.ព មិនបានលើកឡើងនូវទឡ្ហីករណ៍ថ្មីៗដែលទាក់ទិននឹងអត្ថិភាពរបស់ទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធនៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទេ។ ប្រៀបធៀបសំណើនេះ ទៅនឹងសារណាពីមុនរបស់ ក.ស.ព ដែលបានលើកឡើងនូវទឡ្ហីករណ៍ដូចៗគ្នាដែរគឺ៖ ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០, ឯកសារលេខ D427/1/17, កថាខណ្ឌ ១៧៤, ១៧៦-១៨៣។

[39] *សូមមើល* សាលដីការបស់អង្គបុរេជំនុំជម្រះ, កថាខណ្ឌ ៣០៧-១១; សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារលេខ D427/3/15 ("សាលដីការបស់អង្គបុរេជំនុំជម្រះលើករណី នួន ជា"), កថាខណ្ឌ ១៣៧-៤៤។ នៅក្នុងករណី *ឌុច* ដោយពុំបានស្នើឲ្យមានការដាក់សារណាពីភាគី ឬអ្នកដែលពុំមែនជាភាគីក្នុងរឿងក្តីទេនោះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេច*ដោយឯកឯង (sua sponte)* ថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ មិនបានតម្រូវឲ្យមានទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធទេ។ សាលក្រមលើសំណុំរឿង *ឌុច,* កថាខណ្ឌ ២៨៣, ២៩១-៩២។ ក្រៅពីនៅក្នុងកថាខណ្ឌដំបូងនៃសេចក្តីសម្រេចដែលត្រូវបានជំទាស់ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងនូវសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តែនៅពេលអង្គជំនុំជម្រះនេះសង្ខេបពីទឡ្ហីករណ៍របស់ ក.ស.ព តែប៉ុណ្ណោះ។ *សូមមើល* សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៥-៦។

ចំពោះធម្មនុញ្ញនេះឬទេ ឬតើលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនង បានឆ្លុះបញ្ចាំងនូវការអនុវត្តច្បាប់ដែលមានលក្ខណៈទូទៅឬទេ[40]។ មេធាវីការពារក្ដីសូមលើកឡើងថា ពាក្យពេចន៍នៅក្នុងធម្មនុញ្ញតុលាការ Nuremberg ឆ្លុះបញ្ចាំងពី "ដើមកំណើត" នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានកើតឡើងពីច្បាប់ និងទំនៀមទម្លាប់សង្គ្រាម នៅចុងសតវត្សរ៍ទី១៩ និងដើមសតវត្សរ៍ទី២០[41]។ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា ទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធត្រូវបានបញ្ចូល ដើម្បីបញ្ចៀសនូវការចោទប្រកាន់ដែលថា គោលការណ៍នីត្យានុកូលភាពត្រូវបានរំលោភបំពាន ប្រសិនបើធម្មនុញ្ញតុលាការ Nuremberg មិនបានបញ្ចូលទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធទេនោះ គេមានការសង្ស័យថា អាចនឹងពុំមានមូលដ្ឋានច្បាប់ពេញលេញក្នុងការជំនុំជម្រះនូវបទឧក្រិដ្ឋទាំងនោះ ក្រោយសង្គ្រាមលោកលើកទី២[42]។

---

40 សេចក្ដីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១៣។

41 *សូមមើល* សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១០, ឯកសារលេខ D427/1/23 ("សារណាឆ្លើយតបរបស់ អៀង សារី"), កថាខណ្ឌ ៨៧; បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០, ឯកសារលេខ D427/1/6, កថាខណ្ឌ ១៨៩។ *សូមមើលផងដែរ* M. CHERIF BASSIOUNI, CRIMES AGAINST HUMANITY IN INTERNATIONAL CRIMINAL LAW 77 (Kluwer International, 1999) ("BASSIOUNI")៖ "ជាការសេចក្ដីសន្និដ្ឋានយ៉ាងច្បាស់ថា "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ជាការប្រៀបធៀបទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម និងជាការលាតសន្ធឹងនៃឧក្រិដ្ឋកម្មសង្គ្រាម និងថាឧក្រិដ្ឋកម្មទាំងនេះផ្អែកទៅលើគោលការណ៍សីលធម៌ និងច្បាប់ដូចគ្នាដែលមានតាំងពីយូរណាស់មកហើយ និងដែលជាទ្រទាប់នៃគោលការណ៍ បទដ្ឋាន និងវិធានស្ដីពីការធ្វើឲ្យមានភាពមនុស្សធម៌ និង បទបញ្ញានៅក្នុងជម្លោះប្រដាប់អាវុធ"; Egon Schwelb, *Crimes Against Humanity*, 23 B. Y.B. INT'L L. 178, 206 (1946) ("Schwelb")៖ "[ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ]គឺជា ... អនុផលនៃសង្គ្រាម ដែលអាចអនុវត្តបានតែនៅក្នុងពេលសង្គ្រាម ឬទាក់ទិនជាមួយសង្គ្រាមតែប៉ុណ្ណោះ និង ប្រសិនបើដាច់ខាតទេនោះវាមានទិសដៅជាបឋម ដើម្បីការពារប្រជាជននៃប្រទេសដទៃប្រឆាំងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ដោយអាជ្ញាធរ ឬស្ថាប័នរបស់ប្រទេសឈ្លានពាន ពាក់ព័ន្ធនឹងសង្គ្រាមឈ្លានពាន ...។ ដូចដែលមានកំណត់និយមន័យនៅក្នុងសាលក្រមនៃតុលាការ Nuremberg រួចមកហើយគឺថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជាឧក្រិដ្ឋកម្ម "ដែលអម" ឬ "បន្ទាប់បន្សំ" របស់ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាពផង ឬការរំលោភដល់ច្បាប់ និងទំនៀមទម្លាប់សង្គ្រាមផង"។

42 សាលដីការបស់អង្គបុរេជំនុំជម្រះ, កថាខណ្ឌ ៣០៨។ *សូមមើល* BASSIOUNI, ត្រង់ទំព័រ ២៥៥-៥៦៖ ឧក្រិដ្ឋកម្មអន្តរជាតិដាច់ចេញពីឧក្រិដ្ឋកម្មជាតិ ដោយសារមានធាតុផ្សំបន្ថែមតាមច្បាប់អន្តរជាតិដែលមានលក្ខណៈពិសេសចំពោះឧក្រិដ្ឋកម្មជាក់លាក់។ ធាតុផ្សំមួយតាមច្បាប់អន្តរជាតិដែលមាននៅក្នុងនិយមន័យនៃ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" នៅក្នុងធម្មនុញ្ញតុលាការ

២៩. អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវិភាគទៅលើធម្មនុញ្ញតុលាការ Nuremberg។ ធម្មនុញ្ញតុលាការ Nuremberg បានផ្តល់យុត្តាធិការដល់តុលាការយោធាអន្តរជាតិ ("IMT") ទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានប្រព្រឹត្តឡើង "ក្នុងការប្រតិបត្តិ ឬមានទំនាក់ទំនងទៅនឹង" បទឧក្រិដ្ឋនានាដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការនេះ ពោលគឺ ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងឧក្រិដ្ឋកម្មសង្គ្រាម[43]។ ចៅក្រមនៅតុលាការ IMT បានអះអាងយ៉ាងច្បាស់ថា ធម្មនុញ្ញតុលាការ Nuremberg តំណាងឲ្យ "យោបល់របស់ច្បាប់អន្តរជាតិដែលមានក្នុងពេលដែលតុលាការនេះត្រូវបានបង្កើតឡើង"[44]។ នៅក្រោយសង្គ្រាមលោកលើកទី២ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងធម្មនុញ្ញតុលាការ Nuremberg រួមទាំងលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធផងនោះ គឺជាសេចក្តីប្រកាសពីច្បាប់អន្តរជាតិដែលត្រូវបានទទួលយកដោយប្រទេសភាគច្រើន[45]។

## ២. រឿងក្តីនានាដែលពាក់ព័ន្ធនឹងច្បាប់CCL 10

---

Nuremberg គឺទំនាក់ទំនងទៅនឹងសង្គ្រាម។ *សូមមើលផងដែរដូចខាងលើ*, ទំព័រ ២៦៥៖ "នៅពេលបង្កើតធម្មនុញ្ញតុលាការ Nuremberg សង្គ្រាមដែលមានភ្ជាប់ជាមួយនោះមិនអាចផ្តាច់ចេញពីទំនាក់ទំនងរវាង "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ទៅនឹងច្បាប់អនុសញ្ញាអន្តជាតិ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមានជាមុន ដែលបានមិនឲ្យមានការប្រព្រឹត្តបែបនោះនៅក្នុងពេលមានសង្គ្រាមបានទេ។ ប្រសិនបើមិនមានធាតុផ្សំនេះទេ ធម្មនុញ្ញតុលាការ Nuremberg នឹងពិតជាបានរំលោភបំពានដល់ "គោលការណ៍នីត្យានុកូលភាព" មិនខានឡើយ"។

[43] ធម្មនុញ្ញតុលាការយោធាអន្តរជាតិ, ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥ ("ធម្មនុញ្ញតុលាការ Nuremberg"), មាត្រា ៦(គ)។

[44] សាលក្រម, *ការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធាអន្តរជាតិ*, ក្បាលទី១ (ឆ្នាំ ១៩៤៧) ("សាលក្រមតុលាការ Nuremberg", ទំព័រ ២១៨។ ការប្រកាសនេះកើតឡើងពីរឿងក្តីរបស់ Julius Streicher ដែលត្រូវបានផ្តន្ទាទោសពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនូវការធ្វើទុក្ខបុកម្នេញ។ ទោះបីសាលក្រមតុលាការ Nuremberg បានយោងទៅដល់ " ការនិយាយ ការសរសេរ និងបែរបន់ពីការគុំគួនចំពោះជនជាតិជ្វីហ្វអស់រយៈពេល ២៥ ឆ្នាំ" ក៏ដោយ ក៏គាត់ត្រូវបានផ្តន្ទាទោសត្រឹមតែពី ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលមានសង្គ្រាមដែរ។ *ដូចខាងលើ*, ទំព័រ ៣០២, ៣០៤។

[45] *សូមមើល* សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 95(I), ការអះអាងបញ្ជាក់ពីគោលការណ៍របស់ច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ដោយធម្មនុញ្ញនៃតុលាការ Nurernberg, ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៤៦; គោលការណ៍របស់ច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ដោយធម្មនុញ្ញនៃតុលាការ Nurernberg និងនៅក្នុងសាលក្រមរបស់តុលាការនេះ, ឯកសារលេខ ("គោលការណ៍តុលាការ Nuremberg")។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ២៖ អំណាចទៅលើការអនុវត្តរបស់រដ្ឋទាក់ទិននឹងទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ឆ្នាំ ១៩៦៨ រហូតដល់បច្ចុប្បន្ន) ដែលបានលើកឡើងពីប្រវត្តិនៃលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ។

៣០. អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា យុត្តិសាស្ត្ររបស់តុលាការដែលអនុវត្តច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង មានសារសំខាន់ចំពោះនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិចន្លោះនៅពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ អង្គជំនុំជម្រះនេះក៏បានសន្និដ្ឋានផងដែរថា ពុំមានភាពស៊ីសង្វាក់គ្នាទេក្នុងចំណោមរឿងក្តីនានាពាក់ព័ន្ធនឹងច្បាប់ CCL 10 ចំពោះថាតើទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធជាលក្ខណៈដោយឡែករបស់ធម្មនុញ្ញតុលាការ Nuremberg ឬទេ ឬតើវាមានជាទូទៅតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិឬទេ[46]។ មេធាវីការពារក្តីសូមលើកឡើងថា សាលក្រមនានាដែលសម្រេចតាមច្បាប់ CCL 10 មិនគួរត្រូវបានចាត់ទុកថាជាសេចក្តីប្រកាសបែបអាជ្ញាបញ្ហាអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាងធម្មនុញ្ញតុលាការ Nuremberg ឬសាលក្រមរបស់តុលាការ Nuremberg នោះឡើយ។ អង្គជំនុំជម្រះសាលាដំបូងទំនងជាទទួលស្គាល់បញ្ហានេះដោយធ្វើការសន្និដ្ឋានថា ក្រោយសង្គ្រាមលោកលើកទី២ភ្លាម មាននិយមន័យលើសពីមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានគេទទួលយក[47]។ អង្គបុរេជំនុំជម្រះយល់ស្រប ដោយសន្និដ្ឋានថា យុត្តិសាស្ត្ររបស់តុលាការដែលអនុវត្តច្បាប់ CCL 10 ពុំស៊ីសង្វាក់គ្នាទៅលើបញ្ហាទំនាក់ទំនងនេះទេ និងថានៅគ្រប់កាលៈទេសៈទាំងអស់ ច្បាប់ CCL 10 ជា "ច្បាប់ជាតិសុទ្ធសាធ"[48]។

៣១. អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅពេលធ្វើសេចក្តីសន្និដ្ឋានលើអង្គសេចក្តីពីយុត្តិសាស្ត្ររបស់តុលាការដែលអនុវត្តច្បាប់ CCL 10 ដែលពុំស៊ីសង្វាក់គ្នា។ ទោះបីច្បាប់ CCL 10 ដែលត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាគ្រប់គ្រងប្រទេសអាល្លឺម៉ង់[49] បានលុបនូវលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់នេះក៏ដោយ[50] ក៏ច្បាប់នេះបានបញ្ចូលច្បាប់អន្តរជាតិទៅក្នុងបញ្ញត្តិនានារបស់ខ្លួនដែរ។ បុព្វកថាបានថ្លែងថា ច្បាប់ CCL 10 ត្រូវបានបង្កើតឡើង "ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពនូវលក្ខខណ្ឌនានាដែល

---

[46] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ២០។

[47] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ១៨។

[48] សាលដីការបស់អង្គបុរេជំនុំជម្រះ, កថាខណ្ឌ ៣០៩។

[49] សន្និសីទទីក្រុងប៉ៃរឡាំង (Potsdam), ពិធីសារស្តីពីកិច្ចដំណើរការនីតិវិធី, ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ១៩៤៥, ផ្នែក II(A)(1)។

[50] ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ស្តីពីការផ្តន្ទាទោសចំពោះបុគ្គលដែលមានពិរុទ្ធភាពពីឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៤៥ ("CCL 10"), មាត្រា II(1)(c)។

មានចែងក្នុងសេចក្តីប្រកាសទីក្រុងម៉ូស្គូថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៤៣ និង កិច្ចព្រមព្រៀងទីក្រុងឡុងថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥ ហើយធម្មនុញ្ញតុលាការ [Nuremberg] ត្រូវបានបង្កើតឡើងដើម្បីសម្រេចនូវគោលដៅនេះ"។ ទោះបីច្បាប់ CCL 10 បានបញ្ចូលច្បាប់អន្តរជាតិក៏ដោយ តែបុព្វកថាក៏បានបង្ហាញថា ច្បាប់ CCL 10 មានលក្ខណៈជាច្បាប់ជាតិ ដែលត្រូវបានបង្កើតឡើងដើម្បីជំនុំជម្រះទោសពួកឧក្រិដ្ឋជនសង្គ្រាម "នៅប្រទេសអាល្លឺម៉ង់"[51] ដោយមានតុលាការជាតិអនុវត្តច្បាប់ជាតិតែប៉ុណ្ណោះ[52]។ ថ្វីត្បិតតែមានការលុបចោលទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏តុលាការជាច្រើនដែលអនុវត្តច្បាប់ CCL 10 នេះ គោរពយុត្តិសាស្ត្ររបស់តុលាការ Nuremberg ដែរ និងបានតម្រូវឲ្យមានទំនាក់ទំនងរវាងអំពើនានាជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធដែរ[53]។ ជាងនេះទៅទៀត តុលាការខ្លះត្រូវបានកំហិតដែនសមត្ថកិច្ចលើពេលវេលា ដោយបើកសវនាការស្តាប់តែបទចោទនានាដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានចោទប្រកាន់ថាបានកើតឡើងក្នុងអំឡុងពេលមាន

---

[51] ច្បាប់ CCL 10, បុព្វកថា។ មាត្រា IV ចែងថា នៅពេលជនណាម្នាក់ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មមួយនៅក្នុងប្រទេសមួយក្រៅពីប្រទេសអាល្លឺម៉ង់ ប្រសិនបើមានសំណើ ជននោះអាចត្រូវផ្ទេរទៅប្រទេសនោះដើម្បីជំនុំជម្រះទោស។ ហេតុនេះ ពាក្យពេចន៍នៅក្នុងច្បាប់ CCL 10 មានន័យថា តុលាការដែលបង្កើតដោយច្បាប់ CCL 10 ពុំមានយុត្តាធិការទៅលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្រៅទឹកដីអាល្លឺម៉ង់ទេ ។ *សូមមើលផងដែរ* BASSIOUNI, ត្រង់ទំព័រ ៣៣; Sydney L. Goldenberg, *Crimes Against Humanity é 1945-1970*, 10 W. ONT. L. REV. 1, 10 (1971) ("Goldenberg")។

[52] គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាម អ.ស.ប, *ប្រវត្តិរបស់គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមនៃសហប្រជាជាតិ និងការវិវត្តនៃច្បាប់សង្គ្រាម (History of the United Nations War Crimes Commission and the Development of the Laws of War)* (ឆ្នាំ ១៩៤៨) ("របាយការណ៍គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាម អ.ស.ប"), ទំព័រ ២១៣។

[53] *សូមមើលជាឧទាហរណ៍ រឿងក្តី Flick និងអ្នកដទៃទៀត*, សាលក្រមថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៤៧, ត្រូវបានបោះពុម្ពជាថ្មីនៅក្នុង *ការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuremberg តាមច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង*, ក្បាលទី ៦ *("រឿងក្តី Flick និងអ្នកដទៃទៀត")*; *រឿងក្តី Alstoetter និងអ្នកទៃទៀត*, សាលក្រមថ្ងៃទី ៣-៤ ខែ ធ្នូ ឆ្នាំ ១៩៤៧, ត្រូវបានបោះពុម្ពជាថ្មីនៅក្នុង *ការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuremberg តាមច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង*, ក្បាលទី ៣ *("រឿងក្តីចៅក្រម")*; *រឿងក្តី Ernst von Weizsaecker និងអ្នកដទៃទៀត*, ដីកាសម្រេចរបស់តុលាការដែលបដិសេធបទចោទទី ៤ និងអនុស្សរណៈដែលភ្ជាប់នឹងបទចោទនោះ, ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៤៨, ត្រូវបានបោះពុម្ពជាថ្មីនៅក្នុង *ការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuremberg តាមច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង*, ក្បាលទី ១៣ *("រឿងក្តីរដ្ឋមន្ត្រី")*។

ជម្លោះប្រដាប់អាវុធតែប៉ុណ្ណោះ[54]។ អាស្រ័យហេតុនេះ គេពុំគួរស្មានខុសពីសារៈសំខាន់នៃការលុបលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីច្បាប់ CCL 10 ឡើយ[55]។

៣២. អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការពឹងផ្អែករបស់ខ្លួនទៅលើយុត្តិសាស្ត្រនៃច្បាប់លេខ១០ នៃក្រុមប្រឹក្សាគ្រប់គ្រង។ តុលាការពីរនៃតុលាការនានាពុំបានដោះស្រាយដោយផ្ទាល់នឹងសំណួរថាតើទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ជាលក្ខខណ្ឌតម្រូវមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិឬទេ។ តុលាការទាំងពីរ ដែលបានដោះស្រាយដោយផ្ទាល់នឹងសំណួរនេះ បានសម្រេចថា ទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ គឺជាលក្ខខណ្ឌតម្រូវក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា តុលាការនៃតុលាការនានាដែលត្រូវបានបង្កើត អនុលោមតាមច្បាប់លេខ១០នៃក្រុមប្រឹក្សាគ្រប់គ្រង ពោលគឺ តុលាការ *Flick* និង តុលាការ *Einsatzgruppen* បានបកស្រាយទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធក្នុងធម្មនុញ្ញតុលាការ Nuremberg ថាជាការកំណត់ផ្នែកយុត្តាធិការជាក់លាក់មួយ[56]។ ក្នុងរឿងក្តី *Flick* តុលាការគ្រាន់តែបានដោះស្រាយថាតើភស្តុតាងដែលបានបង្ហាញបង្កើតបានជាឧក្រិដ្ឋកម្មក្នុងយុត្តាធិការរបស់ខ្លួនដែរឬទេ ហើយតុលាការនេះពុំបានវាយតម្លៃស្ថានភាពច្បាប់ទំនៀមទម្លាប់អន្តរជាតិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ[57]។ ទោះយ៉ាង

---

[54] *សូមមើលជាឧទាហរណ៍, រឿងក្តី Ohlendorf និងអ្នកដទៃទៀត*, សាលក្រមថ្ងៃទី ៨៩ ខែ មេសា ឆ្នាំ ១៩៤៨, ត្រូវបានបោះពុម្ពជាថ្មីនៅក្នុង *ការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuremberg តាមច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង*, ក្បាលទី ៤ *("រឿងក្តី Einsatzgruppen")*, ទំព័រ ១៥; *រឿងក្តី Greifelt និងអ្នកដទៃទៀត*, សាលក្រមថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៤៨, *ការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuremberg តាមច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង*, ក្បាលទី ៥ *("រឿងក្តី RuSHA")*, ទំព័រ ៨៨; *រឿងក្តី Brandt និងអ្នកដទៃទៀត*, សាលក្រមថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៤៧, *ការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuremberg តាមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង*, ក្បាលទី ២ *("រឿងក្តីគ្រូពេទ្យ")*, ទំព័រ ១៧១។

[55] *សូមមើល* Goldenberg, ត្រង់ទំព័រ ១០។

[56] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ១៥៖ "តុលាការមួយចំនួន ដែលត្រូវបានបង្កើតឡើង អនុលោមតាមច្បាប់លេខ ១០ នៃក្រុមប្រឹក្សាត្រួតពិនិត្យ បានបកស្រាយលក្ខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនៅក្នុងធម្មនុញ្ញ Nuremberg ថាជាលក្ខខណ្ឌយុត្តាធិការ" លើកឡើង រឿងក្តី *Flick និង អ្នកផ្សេងទៀត* ទំព័រ ១២១២-១៣ និង*រឿងក្តី Einsatzgruppen* ទំព័រ៤៩៩។

[57] *រឿងក្តី Flick និងអ្នកផ្សេងទៀត* ទំព័រ១២១៣។

នេះក្តី តុលាការ *Flick* បានបដិសេធយ៉ាងច្បាស់លាស់ចំពោះការអះអាងថា ការគ្មានលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងនេះនៅក្នុងច្បាប់លេខ១០ នៃក្រុមប្រឹក្សាគ្រប់គ្រងបានពង្រីកវិសាលភាពនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយរាប់បញ្ចូលទាំងឧក្រិដ្ឋកម្មដែលពុំបានប្រព្រឹត្តនៅក្នុងជម្លោះប្រដាប់អាវុធ ហើយបានសម្រេចថា ការបកស្រាយបែបនេះនឹងបំពានដល់បុព្វកថានៃច្បាប់លេខ១០នៃក្រុមប្រឹក្សាគ្រប់គ្រង[58]។ ចំណែករឿងក្តី *Einsatzgruppen* វិញ ការលើកឡើងរបស់តុលាការដែលថា ច្បាប់លេខ១០នៃក្រុមប្រឹក្សាគ្រប់គ្រងបានផ្តល់ឱ្យខ្លួននូវយុត្តាធិការក្នុងការជំនុំជម្រះ "រាល់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាំងអស់ ឲ្យតែគេបានដឹងឮ និងយល់បាន ក្រោមគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ"[59] *មិនមែនជាខ្លឹមសារសំខាន់* (*obiter dictum*) ទេ។ តាមការសង្កេតរបស់គណៈកម្មការទទួលបន្ទុកផ្នែកឧក្រិដ្ឋកម្មសង្គ្រាម របស់អង្គការសហប្រជាជាតិ ដោយសារតែយុត្តិធិការរបស់តុលាការ *Einsatzgruppen* ត្រូវបានកំណត់ជាបណ្តោះអាសន្នចំពោះតែឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានប្រព្រឹត្តនៅចន្លោះខែ ឧសភា ឆ្នាំ ១៩៤១ និង ខែ ឧសភា ឆ្នាំ ១៩៤៣ តុលាការនេះអាចត្រឹមតែជំនុំជម្រះបទចោទពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលជាប់ ពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធប៉ុណ្ណោះ។ ដូច្នេះ ការសង្កេតរបស់តុលាការនេះចំពោះលក្ខខណ្ឌតម្រូវនៃទំនាក់ទំនង ពុំមានសារសំខាន់ចំពោះ*សំអាងហេតុនៃសេចក្តីសម្រេច* (*ratio decidendi*) ឡើយ[60]។ ការសង្កេតទាំងនោះមិនអាចត្រូវបានចាត់ទុកថាមានសារសំខាន់ ចំពោះការកំណត់ស្ថានភាពនៃលក្ខខណ្ឌនៃទំនាក់ទំនងក្នុងច្បាប់ទំនៀមទម្លាប់

---

[58] *ដូចជើងទំព័រខាងលើ* ទំព័រ១២១២-១២១៤។

[59] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ១៦ *ដោយលើកឡើងរឿងក្តី Einsatzgruppen* ទំព័រ៤៩៩។

[60] *សូមមើល របាយការណ៍ស្តីពីច្បាប់នៃការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម* គណៈកម្មការទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ វ៉ុលយ៉ូម XV (ឆ្នាំ ១៩៤៩) ("របាយការណ៍របស់គណៈកម្មការទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ") ទំព័រ ១៣៧។ *សូមមើលផងដែរ* ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងសំណើសុំឱ្យមានសវនាការផ្ទាល់មាត់ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារលេខ E95/4 ("ចម្លើយតបរបស់ អៀង សារី") កថាខណ្ឌ២៤។ Beth Van Schaack *និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ៖ ដោះស្រាយភាពមិនប្រទាក់ក្រឡាគ្នា* ៣៧ COL. J. TRANSNAT'L L. ៧៨៧, ៨១០ (ឆ្នាំ ១៩៩៩) ("Van Schaack")។

អន្តរជាតិនាពេលនោះទេ[61]។

៣៣. មិនដូចតុលាការ *Einsatzgruppen* ទេ តុលាការ *Flick* មានយុត្តាធិការពេលវេលាក្នុងការជំនុំជម្រះរឿងក្ដីនានាដែលបានកើតឡើងមុនពេលសង្គ្រាម *ប៉ុន្តែ* តុលាការនេះបានចោទប្រកាន់បទចោទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានកើតឡើងតែក្នុងអំឡុងសង្គ្រាមប៉ុណ្ណោះ[62]។ ដោយពិចារណាទៅលើភាពខុសគ្នានៃយុត្តាធិការពេលវេលា គណៈកម្មការទទួលបន្ទុកផ្នែកឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ បានយល់ឃើញថា តុលាការ *Flick* មានឥទ្ធិពលជាងតុលាការ *Einsatzgruppen* លើបញ្ហាថាតើទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ ដូចត្រូវបានអនុវត្តដោយតុលាការទាំងពីរដែរឬទេ[63]។

៣៤. រឿងក្ដីពីរបន្ថែមនៃច្បាប់លេខ១០ នៃក្រុមប្រឹក្សាគ្រប់គ្រង ដែលបានលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូង ពោលគឺ ក្នុងរឿងក្ដី *Justice* និងរឿងក្ដី *Ministries* បានបកស្រាយថា ទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធជាធាតុផ្សំមួយ នៃនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[64]។ ក្នុងរឿងក្ដី *Justice* តុលាការនេះបានយល់ឃើញថា បើទោះជាច្បាប់លេខ១០នៃក្រុមប្រឹក្សាគ្រប់គ្រង បានលុបចោលលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងជាមួយជម្លោះ

---

[61] វចនានុក្រមច្បាប់ Black"s Law Dictionary ឲ្យនិយមន័យពាក្យ *obiter dictum* ថាជា "មតិយោបល់ចៅក្រមធ្វើឡើងក្នុងអំឡុងពេលនៃការផ្ដល់មតិយោបល់ពីសំណាក់ចៅក្រម ប៉ុន្តែពុំសំខាន់ចំពោះសេចក្ដីសម្រេចក្នុងរឿងក្ដីឡើយ ដូច្នេះហើយ ពុំមែនជាអ្វីដែលកើតមានមុនឡើង (បើទោះជាវាអាចមានលក្ខណៈជាការបញ្ចុះបញ្ចូលក្ដី)" វចនានុក្រម BLACK"S LAW DICTIONARY 1100 (បោះពុម្ពលើកទី៨ ឆ្នាំ ២០០៤)។

[62] *រឿងក្ដី Flick និងអ្នកផ្សេងទៀត* ទំព័រ៤៣៧។ របាយការណ៍គណៈកម្មការទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ ទំព័រ១៣៧។

[63] របាយការណ៍គណៈកម្មការទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ ទំព័រ១៣៧៖ "ក្នុងការប្រមាណអំពីអាជ្ញាព្រឹត្តពាក់ព័ន្ធនៃសេចក្ដីសម្រេចស្ដីពី [ទំនាក់ទំនង] សំណួរដែលត្រូវបានសម្រេចក្នុងការជំនុំជម្រះនៅតុលាការ *Flick* និងតុលាការ *Einsatzgruppen* គួរចងចាំដែរថា ដោយសារតែដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានចោទក្រោយមកទៀត ត្រូវបានប្រព្រឹត្ត 'ចន្លោះខែ ឧសភា ឆ្នាំ ១៩៤១ និង ខែ កក្កដា ឆ្នាំ ១៩៤៣" ឃ្លាខ្លីមួយដែលបានដកស្រង់ពីសាលក្រមក្នុងការជំនុំជំម្រះនេះពុំមានសារៈសំខាន់ដល់សេចក្ដីសម្រេចដែលបានធ្វើឡើងទេ។ ម្យ៉ាងវិញទៀត ក្នុងការជំនុំជម្រះនៅតុលាការ *Flick* បទចោទ៣ ធ្វើការចោទប្រកាន់អំពីការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅចន្លោះខែមករា ឆ្នាំ ១៩៣៦ និង ខែ មេសា ឆ្នាំ ១៩៤៥"។

[64] សេចក្ដីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ១៧។

ប្រដាប់អាវុធ "សកម្មភាពអមនុស្សធម៌ជាក់លាក់...ត្រូវបានប្រព្រឹត្តឡើងនៅក្នុងការអនុវត្ត និង ពាក់ព័ន្ធជាមួយសង្គ្រាមឈ្លានពាន ដូច្នេះហើយជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បើទោះជានៅក្រោមបទប្បញ្ញត្តិនៃធម្មនុញ្ញ IMT ក៏ដោយ"[65]។ តុលាការនេះបានទទួលស្គាល់លក្ខខណ្ឌតម្រូវដែលថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវតែមានទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ[66]។

៣៥. ក្នុងរឿងក្តី *Ministries* តុលាការនេះបានយល់ឃើញថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពុំបានបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ ព្រោះ "ពុំមានអំណះអំណាងថា ឧក្រិដ្ឋកម្មបែបនេះត្រូវបានអនុវត្តជាមួយឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឬឧក្រិដ្ឋកម្មសង្គ្រាមឡើយ"[67]។ ក្នុងការសម្រេចដូចនេះ តុលាការបានលើកពីតុលាការ Nuremberg ដែលគេសង្កេតឃើញថា តុលាការនេះបានអនុវត្តច្បាប់ជាធរមាន[68] និងយល់ឃើញថា ដើម្បីពង្រីកយុត្តាធិការរបស់ខ្លួនឲ្យកាន់តែទូលំទូលាយ នឹងត្រូវមិនគិតគូរដល់ "គោលការណ៍យុត្តិធម៌ដែលមានមូលដ្ឋានច្បាស់លាស់ ដែលថា គ្មានអំពើណាមួយត្រូវបានប្រកាសថាជាអំពើឧក្រិដ្ឋឡើយ បើសិនអំពើនោះពុំមែនជាឧក្រិដ្ឋកម្មក្រោមច្បាប់ដែលមានអត្ថិភាពនាពេលនោះ នៅពេលដែលអំពើនោះត្រូវបានប្រព្រឹត្តឡើង"[69]។

---

[65] *រឿងក្តី Justice* ទំព័រ៩៧៤។

[66] Van Schaack នៅទំព័រ៨១១៖ "ក្នុងការពិភាក្សាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិកាន់តែមានលក្ខណៈទូទៅ តុលាការ [*Justice*] ទទួលស្គាល់ថា ទំនាក់ទំនងសង្គ្រាម ដែលត្រូវបានដំណើរការ ដើម្បីបែងចែកឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិពីឧក្រិដ្ឋកម្មសាមញ្ញៗ"។

[67] *រឿងក្តី Ministries* ទំព័រ ១១៦ *ដោយលើកឡើងពី* សេចក្តីថ្លែងការណ៍នានារបស់សម្តេចប្រធានចៅក្រម Wright ក្នុងការត្រួតពិនិត្យវាយតម្លៃប្រចាំត្រីមាសស្តីពីច្បាប់ វ៉ុលយ៉ូម៦២ (ចុះខែ មករា ឆ្នាំ ១៩៤៦)៖ "[ឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់នៅតុលាការ Nuremberg] ពុំមែនជាឧក្រិដ្ឋកម្មនោះទេ ព្រោះតែកិច្ចព្រមព្រៀងរបស់រដ្ឋាភិបាលចំនួនបួន ប៉ុន្តែថា រដ្ឋាភិបាលទាំងនោះ បានចាត់ទុកឧក្រិដ្ឋកម្មទាំងនោះថាស្ថិតនៅក្រោមយុត្តាធិការនៃតុលាការ ព្រោះពួកវាជាឧក្រិដ្ឋកម្មរួចជាស្រេចទៅហើយក្នុងច្បាប់ជាធរមាន"។

[68] *ដូចឯកសារខាងលើ ដោយលើកឡើងពី* សម្តេចប្រធានចៅក្រម Wright ក្នុងការពិនិត្យវាយតម្លៃប្រចាំត្រីមាសស្តីពីបញ្ហាច្បាប់ វ៉ុលយ៉ូម ៦២ (មករា ឆ្នាំ ១៩៤៦)។

[69] *ដូចឯកសារខាងលើ*។

ខ. **អង្គជំនុំជម្រះសាលាដំបូងបានដកស្រង់*ដោយមិនត្រឹមត្រូវ និងដោយធ្វើការជ្រើសរើស* នូវមូលដ្ឋាន សំអាងផ្លូវច្បាប់មួយចំនួន ក្នុងការបកស្រាយលក្ខខណ្ឌតម្រូវទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធក្នុងធម្មនុញ្ញតុលាការ Nuremberg [សេចក្តីសម្រេចដែលត្រូវបានជំទាស់ ជើងទំព័រ ៥៤]**

៣៦. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ឯកសារសំអាងផ្លូវមួយចំនួនក្រោយពីច្បាប់លេខ១០នៃក្រុមប្រឹក្សាគ្រប់គ្រង បានបកស្រាយថា លក្ខខណ្ឌតម្រូវទំនាក់ទំនងនៅក្នុងធម្មនុញ្ញ Nuremberg សម្រាប់តែធម្មនុញ្ញនេះប៉ុណ្ណោះ ឬថាលក្ខខណ្ឌតម្រូវទំនាក់ទំនងជាមួយឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ លែងមានអត្ថិភាពបន្ទាប់ពីក្រុមប្រឹក្សា ឬបើមានអត្ថិភាពក៏មុនឆ្នាំ ១៩៧៥ ដែរ[70]។ មេធាវីការពារក្តីសូមសន្និដ្ឋានថា មូលដ្ឋានសំអាងផ្លូវច្បាប់មួយចំនួនដែលត្រូវបានលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូង មិនត្រឹមត្រូវ មិនពាក់ព័ន្ធ ឬមានការដកស្រង់សម្រាំង (ខុសបរិបទ) ចេញពីឯកសារ។ អង្គបុរេជំនុំជម្រះបានឯកភាពទៅនឹងការលើកឡើងរបស់មេធាវីការពារក្តីអំពីការពិនិត្យ ទៅលើសំអាងផ្លូវច្បាប់ដែលខ្លួនបានពិនិត្យមើល[71]។

៣៧. អង្គជំនុំជម្រះសាលាដំបូងមានកំហុសដូចខាងក្រោម៖

---

[70] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ២០ ជើងទំព័រ៥៤។

[71] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ៣០៧៖ "តាមន័យទូទៅ អង្គបុរេជំនុំជម្រះសង្កេតឃើញថា គេត្រូវមានការប្រុងប្រយ័ត្នក្នុងការពឹងផ្អែកលើសំអាងហេតុរបស់តុលាការ ICTY នៅពេលពិភាក្សាពីសភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយសាររឿងក្តីនានា ដែលតុលាការ ICTY ដោះស្រាយ ទាក់ទិននឹងពេលវេលាមួយ ដែលខុសពីពេលវេលានៃយុត្តាធិការរបស់ អ.វ.ត.ក។ អង្គបុរេជំនុំជម្រះក៏ត្រូវតែសង្កេតផងដែរពីភាពខុសគ្នារវាងការពិភាក្សារបស់តុលាការ ICTY ទៅលើសភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងគោលបំណងរកឲ្យឃើញពីនិយមន័យសុក្រឹត្យមួយនៃបទល្មើសមួយ ដែលផ្ទុយពីការពិភាក្សារបស់តុលាការ ICTY ទៅលើសភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងគោលចំណងសម្រេចថាតើឧក្រិដ្ឋកម្មមួយ ដែលកើតមានក្នុងពេលជាក់លាក់មួយ"។

<u>ទីមួយ</u>៖ សាលាក្រមលើបណ្តឹងបន្ទាន់បង្ខំក្នុងរឿងក្តី *Tadić* នៅតុលាការ ICTY ពុំបង្ហាញឲ្យច្បាស់ៗថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅមុន ឬនៅក្នុងចន្លោះឆ្នាំ១៩៧៥-៧៩ បានផាត់ចោលទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ[72]។

<u>ទីពីរ</u> ៖ របាយការណ៍ឆ្នាំ ១៩៤៨ របស់ គណៈកម្មការទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ ពុំបង្ហាញថា លក្ខខណ្ឌតម្រូវនៃទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធលែងមានអត្ថិភាពទៀតដែរ បន្ទាប់ពីធម្មនុញ្ញតុលាការ Nuremberg[73]។

---

[72] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ២០ ជើងទំព័រ៥៤ *ដោយលើកឡើងពីរឿងក្តីរដ្ឋអាជ្ញា តទល់នឹង Tadi□*, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីចំពោះបណ្តឹងសាទុក្ខបន្ទាន់បង្ខំស្តីពីយុត្តាធិការ IT-94-1-A ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៩៥ ("បណ្តឹងសាទុក្ខបន្ទាន់បង្ខំរបស់ *Tadi□*") កថាខណ្ឌ១៤០៖ "ទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឬឧក្រិដ្ឋកម្មសង្គ្រាម ដែលជាលក្ខខណ្ឌនៅក្នុងធម្មនុញ្ញ Nuremberg មានលក្ខណៈពិសេសចំពោះយុត្តាធិការនៃតុលាការ Nuremberg"។ *សូមមើល* កថាខណ្ឌ៥២-៥៣ខាងក្រោម សម្រាប់ការវិភាគបន្ថែមលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍លើរឿងក្តី *Tadi□*។

[73] *សូមមើល* សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ២០ ជើងទំព័រ៥៤ *ដោយលើកឡើងពី* របាយការណ៍ឆ្នាំ១៩៤៨ របស់គណៈកម្មការទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ ទំព័រ១៩២-៩៣។ ឯកសារដែលត្រូវបានប្រើប្រាស់ជាឯកសារយោងក្នុងរបាយការណ៍នេះ បានឆ្លុះបញ្ចាំងពីភាសានៃធម្មនុញ្ញតុលាការ Nuremberg ឬពុំបានដោះស្រាយឲ្យបានច្បាស់លាស់នូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទេ។ ឯកសារនានាមុនធម្មនុញ្ញតុលាការ Nuremberg បានលើកមកធ្វើជាឯកសារយោងនូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ថាជាទស្សនទានដែលមានអត្ថិភាព ស្របគ្នានឹងជម្លោះប្រដាប់អាវុធ។ *សូមមើល* របាយការណ៍របស់គណៈកម្មការទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ ឆ្នាំ១៩៤៨ ទំព័រ១៨៨-៩១ *ដោយលើកឡើងពី* អនុសញ្ញាក្រុងឡាអេ លើកទីបួនក្នុងឆ្នាំ ១៩០៧។ សេចក្តីប្រកាស ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩១៥។ សន្ធិសញ្ញាសន្តិភាព ប្រទេសអេត្យូពី - ប្រទេសអ៊ីតាលី ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៤៧ (សន្ធិសញ្ញាសន្តិភាព អ៊ីតាលី ចុះថ្ងសទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៤៧ ដែលមានឫសគល់ចេញពីការឈ្លានពានវាតទីក្នុងឆ្នាំ ១៩៣៦ មកលើប្រទេសអេត្យូពី របស់ប្រទេសអ៊ីតាលី)។ កិច្ចព្រមព្រៀងអន្តរជាតិសម្រាប់វិធានការរួមប្រឆាំងនឹងការវាយប្រហារប្លន់នៅតំបន់សមុទ្រម៉េឌីតែរ៉ាណេដោយនាវាមុជទឹក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៣៧។ សេចក្តីសម្រេច *សេចក្តីព្រាងអនុសញ្ញាសម្រាប់បង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ* សន្និបាតអន្តរជាតិនៅទីក្រុងឡុងដ៍ (ឆ្នាំ ១៩៤៣)។ ឯកសារក្រោយធម្មនុញ្ញតុលាការ Nuremberg ឆ្លុះបញ្ចាំងយ៉ាងច្បាស់លាស់និងទាំងស្រុងនូវភាសារបស់ធម្មនុញ្ញតុលាការ Nuremberg។ *សូមមើល* របាយការណ៍ឆ្នាំ ១៩៤៨ របស់គណៈកម្មការទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ ទំព័រ ២០៤-១២ *ដោយលើកឡើងពី* ធម្មនុញ្ញតុលាការយោធាអន្តរជាតិ

ទីបី ៖ សេចក្តីប្រកាសរបស់ប្រតិភូមកពីចក្រភពអង់គ្លេសទៅកាន់សន្និសីទស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ពុំបង្ហាញថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បានផាត់ចោលទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធចេញពីចន្លោះឆ្នាំ១៩៧៥-៧៩ ឡើយ[74]។

---

សម្រាប់ចុងបូព៌ា និងសាលដីកា។ សន្ធិសញ្ញាសន្តិភាពជាមួយប្រទេសអ៊ីតាលី រូម៉ានី ប៊ុលហ្គារី ហុងគ្រី និងហ្វាំងឡង់ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ១៩៤៧។ មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ៣3(I) បត្យាប័ន និងទណ្ឌកម្មនៃឧក្រិដ្ឋជនសង្គ្រាម ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៤៦។ មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ ៩៥(I) ការតម្កល់គោលការណ៍ច្បាប់ដោយធម្មនុញ្ញនៃតុលាការ N%ornberg (ថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៤៦)។ ចុងក្រោយ គណៈកម្មការយោធា និងច្បាប់ជាតិបានលើកឡើងការឆ្លុះបញ្ចាំងអំពីភាសានៃធម្មនុញ្ញតុលាការ Nuremberg ពុំហាមប្រាមច្បាស់លាស់នូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬបានដាក់បញ្ចូលពាក្យពេចន៍របស់ធម្មនុញ្ញតុលាការ Nuremberg និង/ឬបានអនុវត្តជាចម្បងនូវច្បាប់ទីក្រុងឡើយ។ *សូមមើល* របាយការណ៍ឆ្នាំ ១៩៤៨ របស់គណៈកម្មការទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ ទំព័រ២០៤-១៩ *ដោយលើកឡើងពី* ច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង។ បទបញ្ជាសម្រាប់គណៈកម្មការយោធាសហរដ្ឋអាមេរិកក្នុងសមរភូមិនៅប្រទេសចិន និងចុងបូព៌ា (ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៤៥)។ ព្រះរាជដីកា ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៤៥ (បទបញ្ជាសម្រាប់តុលាការយោធាចក្រភពអង់គ្លេស)។ បទបញ្ជាស្តីពីឧក្រិដ្ឋកម្មសង្គ្រាមរបស់ប្រទេសកាណាដា (ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៤៥)។ សហធននៃច្បាប់ស្តីពីឧក្រិដ្ឋកម្មសង្គ្រាមរបស់ប្រទេសអូស្ត្រាលី (ឆ្នាំ ១៩៤៥)។ បទបញ្ជាបារាំង ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៤៤។ ព្រះរាជក្រឹត្យនៃប្រទេសហូឡង់ បង្កើតគណៈកម្មការមួយសម្រាប់ការស៊ើបអង្កេតអំពីឧក្រិដ្ឋកម្មសង្គ្រាម (ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ១៩៤៦)។ ក្រឹត្យបែលហ្ស៊ិក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៤៥។ ក្រឹត្យ Grand Ducal ចុះថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ១៩៤៥ (ប្រទេសលុចសំបួ)។ ក្រឹត្យច្បាប់រូម៉ានី ចុះខែ មេសា ឆ្នាំ ១៩៤៥។ ច្បាប់រដ្ឋធម្មនុញ្ញអូទ្រីស ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៤៥។ ច្បាប់ប្រទេសដាណឺម៉ាក ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៤៦។

[74] *សូមមើល* សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ២០ ជើងទំព័រ៥៤ *ដោយលើកឡើងពី* របាយការណ៍សង្ខេបនៃកិច្ចប្រជុំលើកទី៣ សន្និសីទអង្គទូតវិសាមញ្ញនៃអង្គការសហប្រជាជាតិស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ឯកសារលេខ A/CONF.183/C.1/SR.3 ចុះថ្ងៃទី២០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ទំព័រ ៩ កថាខណ្ឌ៨៩ ៖ “ទោះបី ធម្មនុញ្ញតុលាការ Nuremberg និង លក្ខន្តិកៈតុលាការសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានយោងទៅរកជម្លោះប្រដាប់អាវុធ នៅក្នុងរឿងក្តីទាំងពីរក៏ដោយ លិខិតុបករណ៍ទាំងនេះបានបង្កើតឡើងក្រោយហេតុការណ៍ ហើយពុំបានបង្ហាញថា ទំនាក់ទំនងមានអត្ថិភាពនៅក្នុងច្បាប់អន្តរជាតិ”។ អង្គជំនុំជម្រះខកខានមិនបានចង្អុលបង្ហាញថា នៅសន្និសីទនេះ ប្រតិភូមួយចំនួនផ្សេងទៀត ដែលមានទស្សនៈថា ទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ *ពិតជា* មានអត្ថិភាពមែន ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ *សូមមើល* កថាខណ្ឌ៥៥ខាងក្រោម សម្រាប់ការពិភាក្សាបន្ថែមលើសន្និសីទស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ។

<u>ទីបួន</u> ៖ ផ្ទុយនឹងការអះអាងរបស់អង្គជំនុំជម្រះសាលាដំបូង គោលជំហររបស់ Theodor Meron (បច្ចុប្បន្នជាប្រធានតុលាការ ICTY) ក្នុងឆ្នាំ ១៩៩៤ ពាក់ព័ន្ធនឹងទំនាក់ទំនងជម្លោះប្រដាប់អាវុធ គឺថា ស្ថានភាពនៃលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានភាព មិនច្បាស់លាស់ទេ[75]។

<u>ទីប្រាំ</u> ៖ របាយការណ៍ឆ្នាំ ១៩៩៩ របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ពុំបង្ហាញនូវភស្តុតាងច្បាស់លាស់នៃស្ថានភាពក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពីចន្លោះឆ្នាំ១៩៧៥-៧៩ នៃលក្ខខណ្ឌទំនាក់ទំនងជម្លោះប្រដាប់អាវុធឡើយ[76]។

---

[75] *សូមមើល* សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ២០ ជើងទំព័រ៥៤។ គោលជំហររបស់ចៅក្រម Meron បង្ហាញតាមរយៈសេចក្តីថ្លែងការណ៍របស់គាត់ ក្នុងអត្ថបទដដែលនេះ ដូចបានលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូងថា "មិនថាក្នុងអត្ថបទ ឬក្នុងការងាររបស់ [គណៈកម្មការនីតិកម្មអន្តរជាតិ] ឡើង ដែលមនុស្សម្នាក់អាចមើលឃើញនូវគោលជំហរស្របស៊ីគ្នាទៅលើលក្ខខណ្ឌទំនាក់ទំនង"។ Theodor Meron *ឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងប្រទេសយូហ្គោស្លាវី និងការវិវឌ្ឍនៃច្បាប់អន្តរជាតិ* ៨៨ AM. J. INT'L L. ៧៨, ៨៥ (ឆ្នាំ ១៩៩៤)។ អត្ថបទនេះនិពន្ធនៅឆ្នាំ ១៩៩៤ *គឺមុនពេល* សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍លើរឿងក្តី *Tadi□* នៅតុលាការ ICTY ដែលតម្កល់ថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិពុំតម្រូវឱ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធឡើយ។ អត្ថបទនេះចង្អុលបង្ហាញនូវមតិយោបល់ដ៏ល្អិតល្អន់នាពេលនោះ។ សូមមើល ឧ. Diane F. Orentlicher, *Settling Accounts ៖ ភារកិច្ចក្នុងការចោទប្រកាន់បទបំពារបំពានលើសិទ្ធិមនុស្សនៃរបបមុន* 100 YALE L. J. ២៥៣៧, ២៥៨៩ (ឆ្នាំ ១៩៩១) ("Orentlicher"): "ស្ថានភាពផ្នែកច្បាប់នៃលក្ខខណ្ឌទំនាក់ទំនងពោលគឺ ម្តងម្កាល មានលក្ខណៈស្រពិចស្រពិល"។

[76] *សូមមើល* សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ២០ ជើងទំព័រ៥៤ *ដោយលើកឡើងពី* របាយការណ៍ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ដែលបានបង្កើតឡើងយោងតាមសេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៥២/១៣៥ ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៧១ ("ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា")។ ក្រុមអ្នកជំនាញត្រូវបានតែងតាំងឡើងដោយ កាលនោះ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ដែលមានសមាជិកបីនាក់ ពោលគឺ Rajsoomer Lallah, Ninian Stephen និង Steven Ratner។ របាយការណ៍អះអាងថា "ទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងជម្លោះប្រដាប់អាវុធហាក់ដូចជាត្រូវបានគេបែងចែកដាច់ស្រឡះពីគ្នាហើយនៅឆ្នាំ១៩៧៥"។ *សូមមើល* របាយការណ៍របស់ក្រុមអ្នកជំនាញស្តីពីប្រទេសកម្ពុជា កថាខណ្ឌ៧១។ ជាការគាំទ្រ ក្រុមនេះបានលើកឡើងនូវសេចក្តីសម្រង់ពីរទំព័រចេញពីសៀវភៅមួយ និពន្ធដោយសមាជិកម្នាក់នៃក្រុមនេះ ដែលពិចារណាអនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីការពុំអាចយកមកអនុវត្តបាននូវអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ("អនុសញ្ញាស្តីពីអាជ្ញាយុកាលឆ្នាំ

## គ. អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយខកខានពុំបានចាត់ទុកគោលការណ៍តុលាការ Nuremberg ថាជាសេចក្ដីថ្លែងការណ៍សំខាន់នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងមានកំហុស ក្នុងការយល់ឃើញថា សេចក្ដីព្រាងក្រមឆ្នាំ ១៩៥៤ ស្ដីពីបទល្មើសរបស់គណៈកម្មការនីតិកម្មអន្តរជាតិ ជាភស្តុតាងជាក់ស្ដែងនៃការអនុវត្តរបស់រដ្ឋ និងសច្ចធារណ៍ធម្មានុរូប (*opinio juris*) [សេចក្ដីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ២១-២៣]

### 1. គោលការណ៍តុលាការ Nuremberg

៣៨. អង្គជំនុំជម្រះសាលាដំបូងបានយោងដោយខ្លី (ដោយមិនយកចិត្តទុកដាក់) ទៅគោលការណ៍តុលាការ Nuremberg នៅក្នុងប្រយោគមួយនៃផ្នែកមួយ ដែលមានចំណងជើងថា "សេចក្ដីព្រាងក្រមឆ្នាំ១៩៥៤របស់គណៈកម្មការនីតិកម្មអន្តរជាតិ"[77]។ ការពិចារណាចំពោះគោលការណ៍

---

១៩៦៨")។ *សូមមើល* របាយការណ៍របស់ក្រុមអ្នកជំនាញស្ដីពីប្រទេសកម្ពុជា កថាខណ្ឌ៧១ លើកឡើងពី STEVEN R. RATNER និង JASON S. ABRAMS ការទទួលខុសត្រូវចំពោះអំពើព្រៃផ្សៃប្រឆាំងនឹងសិទ្ធិមនុស្ស ក្នុងច្បាប់អន្តរជាតិ៖ លើសពីកេរដំណែលរបស់តុលាការ NUREMBERG ៥៣-៥៤ (Oxford ១៩៩៧)។ ក្រុមនេះលើកឡើងតែប្រភពផ្សេងមួយទៀតប៉ុណ្ណោះ នោះគឺសេចក្ដីព្រាងក្រមឆ្នាំ ១៩៥៤ ស្ដីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិរបស់ គណៈកម្មការនីតិកម្មអន្តរជាតិ ("សេចក្ដីព្រាងក្រមឆ្នាំ ១៩៥៤ ស្ដីពីបទល្មើសរបស់គណៈកម្មការនីតិកម្មអន្តរជាតិ") ដើម្បីគាំទ្រការអះអាងរបស់ខ្លួន។ របាយការណ៍របស់ក្រុមអ្នកជំនាញស្ដីពីប្រទេសកម្ពុជា កថាខណ្ឌ ៧១។ ខណៈដែលកត់សម្គាល់ឃើញនូវការលំបាកនានា តុលាការនឹងមានក្នុងការផ្ដន្ទាទោសមន្ត្រីខ្មែរក្រហម ប្រសិនបើ "ទំនាក់ទំនង នៅតែ [ជា] លក្ខខណ្ឌតម្រូវ ក្នុងឆ្នាំ ១៩៧៥ [ព្រោះថា] ភាគច្រើនធំធេងនៃអំពើព្រៃផ្សៃរបស់ពួកខ្មែរក្រហមនឹងពុំមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ" (*ដូចឯកសារខាងលើ*) ក្រុមអ្នកជំនាញទាំងនេះខកខានពុំបានកត់សម្គាល់ កង្វះខាតនៃការគាំទ្រគ្រប់គ្រាន់ បង្ហាញដោយរដ្ឋសមាជិកនៃអង្គការសហប្រជាជាតិចំពោះអនុសញ្ញាស្ដីពីអាជ្ញាយុកាល ឆ្នាំ ១៩៦៨ ឬការពិតដែលថា សេចក្ដីព្រាងក្រមឆ្នាំ១៩៥៤ ស្ដីពីបទល្មើសមិនដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ។ *សូមមើល* កថាខណ្ឌ៤៤-៤៧ *ខាងក្រោម* សម្រាប់ការពិភាក្សាបន្ថែមទៀតលើ អនុសញ្ញាស្ដីពីអាជ្ញាយុកាល ឆ្នាំ ១៩៦៨។ *សូមមើលផងដែរ* សេចក្ដីសម្រេចលេខ៨៩៧ (IX) របស់មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្ដីព្រាងក្រមស្ដីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិ ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ១៩៥៤។ ការប្រើប្រាស់ធនធានរបស់ក្រុមនេះ និងតាមពិត បើពិនិត្យមើលទៅលើរបាយការណ៍សំដៅរកលទ្ធផលធ្វើជាសូចនាករនៃការអនុវត្តរបស់រដ្ឋ និង *opinio juris* ពាក់ព័ន្ធនឹងលក្ខខណ្ឌទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ ពីឆ្នាំ ១៩៧៥-៧៩ នៅមានកម្រិត។

[77] សេចក្ដីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ២២។

តុលាការ Nuremberg នេះគឺមានលក្ខណៈផ្ទុយទាំងស្រុងទៅនឹងរបៀបដែលអង្គបុរេជំនុំជម្រះបានពិចារណាទៅលើគោលការណ៍ នេះ[78]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា នៅក្នុង "ឆ្នាំ១៩៥០ គណៈកម្មការនីតិកម្មអន្តរជាតិបានកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានអនុវត្តនៅក្នុងធម្មនុញ្ញតុលាការ Nuremberg ដោយបញ្ចូលលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ"[79] ដោយបានសង្កេត ឃើញថា "អាណត្តិការងាររបស់គណៈកម្មការនីតិកម្មអន្តរជាតិកម្រិតលើការបង្កើតគោលការណ៍ច្បាប់សម្រាប់អនុវត្តដោយតុលាការ Nuremberg និងមិនមានអំណាចនៅក្នុងការវាយតម្លៃឡើងវិញលើស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ"[80]។ មេធាវីការពារក្តីសូមសន្និដ្ឋានថា គោលការណ៍តុលាការ Nuremberg បានរៀបចំចងក្រងគោលការណ៍នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលមានអត្ថិភាពនៅពេលនោះ។ អង្គបុរេជំនុំជម្រះឯកភាព ដោយយល់ឃើញថា "គោលការណ៍តុលាការ Nuremberg ឆ្នាំ ១៩៥០ ...បានឆ្លុះបញ្ចាំងពីគោលការណ៍នៃច្បាប់អន្តរជាតិនាពេលនោះ"[81]។

៣៩. អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយខកខានមិនទទួលស្គាល់ថា ក្នុងឆ្នាំ ១៩៤៦ នៅពេលដែលនាំគណៈកម្មាធិការស្តីពីការអភិវឌ្ឍច្បាប់អន្តរជាតិ និងការចងក្រងច្បាប់របស់ខ្លួនក្នុងការបង្កើតនូវគោលការណ៍តុលាការ[82] មហាសន្និបាតអង្គការសហប្រជាជាតិបាន *បញ្ជាក់គាំទ្រ* "គោលការណ៍នៃច្បាប់អន្តរជាតិ ដែលទទួលស្គាល់ដោយធម្មនុញ្ញតុលាការ Nürnberg និងសាលក្រមតុលាការនេះ"[83]។ យើងមិនអាចធ្វើការអះអាងបានទេថា ក្នុងឆ្នាំ ១៩៤៦ រដ្ឋជាសមាជិក

---

[78] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ៣០៩។

[79] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ២២។

[80] *ដូចជើងទំព័រខាងលើ*។

[81] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ៣០៩។

[82] គណៈកម្មការនីតិកម្មអន្តរជាតិគ្រាន់តែមានអាណត្តិការងារចងក្រងជាក្រមតែគោលការណ៍តុលាការ Nuremberg ក្នុងខែវិច្ឆិកា ឆ្នាំ ១៩៤៧ ប៉ុណ្ណោះ។ *សូមមើល* សេចក្តីសម្រេចលេខ ១៧៧ (II) របស់អង្គការសហប្រជាជាតិ (ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៤៧) (ប្រគិតភូកម្មការងារក្នុងការបង្កើតគោលការណ៍តុលាការ Nuremberg ទៅឱ្យគណៈកម្មការនីតិកម្មអន្តរជាតិ)។

[83] សេចក្តីសម្រេចលេខ ៩៥ (I) របស់អង្គការសហប្រជាជាតិ ការតម្កល់យកគោលការណ៍នៃច្បាប់អន្តរជាតិ ទទួលស្គាល់ដោយធម្មនុញ្ញនៃតុលាការ N‰ornberg ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៤៦ ៖ "*ការតម្កល់* គោលការណ៍នៃច្បាប់អន្តរជាតិ ដែលត្រូវបានទទួលស្គាល់ដោយធម្មនុញ្ញ [តុលាការ Nuremberg] និងសាលក្រមតុលាការនេះ" និងការដឹកនាំគណៈកម្មការនីតិកម្មអន្តរជាតិ

អង្គការ សហប្រជាជាតិគ្រាន់តែបានចាត់ទុកលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងក្នុងធម្មនុញ្ញតុលាការ Nuremberg ថាជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការមួយនោះទេ។

៤០. អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយបានថ្លែងពាក់ព័ន្ធនឹងគោលការណ៍តុលាការ Nuremberg ថា "អាណត្តិការងាររបស់គណៈកម្មការនីតិកម្មអន្តរជាតិកម្រិតត្រឹមតែលើការបង្កើតគោលការណ៍ច្បាប់សម្រាប់អនុវត្តដោយតុលាការ Nuremberg និងមិនមែនវាយតម្លៃឡើងវិញលើស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ"[84]។ ដោយសារមហាសន្និបាតអង្គការសហប្រជាជាតិបានបញ្ជាក់គាំទ្រគោលការណ៍ទាំងនេះ[85] គួរមានការសន្និដ្ឋានថា គោលការណ៍តុលាការ Nuremberg បានឆ្លុះបញ្ចាំងពីគោលការណ៍ពាក់ព័ន្ធនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនាពេលនោះ[86]។

---

ដើម្បីបង្កើតគោលការណ៍ទាំងនោះ ក្នុងបរិបទនៃការកំណត់ជាក្រមច្បាប់ទូទៅនៃបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិ ឬក្រមព្រហ្មទណ្ឌអន្តរជាតិ។

[84] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ២២។

[85] មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ ៩៥ (I) ការតម្កល់គោលការណ៍នៃច្បាប់អន្តរជាតិ ទទួលស្គាល់ដោយធម្មនុញ្ញនៃតុលាការ N%ornberg ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៤៦។

[86] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ៣០៩។ *សូមមើលផងដែរ* គោលការណ៍តុលាការ Nuremberg គោលការណ៍ VI(គ)។ ក្នុងអំឡុងពេលពិភាក្សាអំពីគោលការណ៍តុលាការ Nuremberg ប្រតិភូរដ្ឋមួយចំនួន ក្នុងនោះរួមមានប្រតិភូមកពីប្រទេសប្រេស៊ីល ម៉ិកស៊ិក ប៉ាណាម៉ា និងសហរដ្ឋអាមេរិក បានអះអាងថា ទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធជាធាតុផ្សំនៃលក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ក្នុងចំណោមប្រតិភូទាំងដប់បួនរូបក្នុងកិច្ចប្រជុំនោះ ប្រាំមួយនាក់គាំទ្រដល់លក្ខខណ្ឌទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ ក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ *សូមមើល* កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី៤៨នៃគណៈកម្មការនីតិកម្មអន្តរជាតិ A/CN.4/SR.48 ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៥០ ទំព័រ ៥៥-៥៨។ កថាខណ្ឌ៨១, ៨៤-៨៦, ១០៣, ១១២-១៣។ ប្រតិភូម្នាក់ជំទាស់ទៅនឹងការដាក់បញ្ចូលទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ (កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី៤៨នៃគណៈកម្មការនីតិកម្មអន្តរជាតិ A/CN.4/SR.48 ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៥០ ទំព័រ ៥៧ កថាខណ្ឌ១១៧)។ ចុងក្រោយ ប្រតិភូបានបោះឆ្នោតរក្សាទុកលក្ខខណ្ឌទំនាក់ទំនងក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី៤៨នៃគណៈកម្មការនីតិកម្មអន្តរជាតិ A/CN.4/SR.48 ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ១៩៥០ ទំព័រ៥៨)។ *សូមមើលផងដែរ* របាយការណ៍នៃគណៈកម្មការនីតិកម្មអន្តរជាតិស្តីពីកិច្ចប្រជុំលើកទីពីររបស់ខ្លួន ចុះថ្ងៃទី៥ ខែ មិថុនា - ថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ ១៩៥០ A/CN.4/34, Supp. លេខ ១២ ទំព័រ ៣៧៧ កថាខណ្ឌ ១២៣។ គួរកត់សម្គាល់ដែរថា អង្គជំនុំជម្រះសាលាដំបូងលើកឡើងពីរបាយការណ៍របស់អ្នករាយការណ៍ពិសេសថ្លែងទៅកាន់មហា-សន្និបាត ពាក់ព័ន្ធនឹងគោលការណ៍តុលាការ Nuremberg ដែលក្នុងនោះ អ្នករាយការណ៍ពិសេសបានថ្លែងថា គណៈកម្មការនីតិកម្មអន្តរជាតិ មានទស្សនៈថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិអាចកើតឡើងនៅមុនពេលសង្គ្រាម "ពាក់ព័ន្ធនឹង

## 2. សេចក្តីព្រាងក្រមឆ្នាំ១៩៥៤ស្តីពីបទល្មើសរបស់គណៈកម្មការនីតិកម្មអន្តរជាតិ

៤១. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា សញ្ញាណដែលថា លក្ខខណ្ឌតម្រូវទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ សម្រាប់តែចំពោះធម្មនុញ្ញ Nuremberg តែប៉ុណ្ណោះ និងមិនមែនជាលក្ខខណ្ឌចំបង ចំពោះទស្សនទាននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះ មានភាពស៊ីសង្វាក់គ្នាទៅនឹងការងារនៃគណៈកម្មការនីតិកម្មអន្តរជាតិក្នុងទសវត្សរ៍ឆ្នាំ១៩៥០[87]។ មេធាវីការពារក្តីសន្និដ្ឋានថា ការត្រួតពិនិត្យដ៏ល្អិតល្អន់ទៅលើឯកសារពាក់ព័ន្ធពុំគាំទ្រសំអាងហេតុនេះឡើយ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញ ថា "សេចក្តីព្រាងក្រមឆ្នាំ១៩៥៤ ស្តីពីបទល្មើស [របស់គណៈកម្មការនីតិកម្មអន្តរជាតិ] ប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ មិនត្រូវបានទទួលយកដោយមហាសន្និបាតអង្គការសហប្រជាជាតិឡើយ"[88]។

៤២. អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយធ្វើសេចក្តីសន្និដ្ឋានចេញពីសេចក្តីព្រាងក្រមឆ្នាំ ១៩៥៤ ស្តីពីបទល្មើសរបស់គណៈកម្មការនីតិកម្មអន្តរជាតិ ពាក់ព័ន្ធនឹងការអនុវត្តរដ្ឋ និងសច្ចាធារណ៍ធម្មានុរូប (*opinio juris*)[89]។ កំណត់ហេតុនៃការចរចាបង្ហាញថា ក្នុងឆ្នាំ ១៩៥៤ នៅតែមានការគាំទ្រយ៉ាងច្រើន នៅក្នុងគណៈកម្មការនីតិកម្មអន្តរជាតិ ដល់ការតម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ[90]។ គណៈកម្មការនីតិកម្មអន្តរជាតិមានតួនាទីពីរ គឺ **ក.** ការចងក្រង

---

ឧក្រិដ្ឋកម្មនៃ [sic]សន្តិភាព" (ជាក់ស្តែង អ្នករាយការណ៍ពិសេសបានថ្លែងថា គណៈកម្មការនីតិកម្មអន្តរជាតិមានទស្សនៈថា ឧក្រិដ្ឋកម្មប្រឆាំង នឹងមនុស្សជាតិអាចកើតឡើងនៅមុនពេលសង្គ្រាម "ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម*ប្រឆាំងនឹង*សន្តិភាព")។ សេចក្តីថ្លែងការណ៍នេះគ្រាន់ តែផ្តល់នូវការគាំទ្របន្ថែមថា ទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធជាលក្ខខណ្ឌតម្រូវមួយនៃនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងចន្លោះឆ្នាំ១៩៧៥-៧៩។ *សូមមើល* របាយការណ៍របស់គណៈកម្មការនីតិកម្មអន្តរជាតិថ្លែងទៅកាន់មហាសន្និបាត A/1316 ចុះថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ១៩៥០ កថាខណ្ឌ១២៣។

[87] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ២១។

[88] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ៣១០ *លើកឡើងពី* សេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ 897(IX) ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ១៩៥៤។

[89] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ២៣។

[90] កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី២៦៧នៃគណៈកម្មការនីតិកម្មអន្តរជាតិ A/CN.4/SR.267 ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៥៤ កថាខណ្ឌ ៤២, ៤៦, ៥២-៥៤, ៥៧។ ពិសេស សំណើសុំលុបភាសាដែលតម្រូវឲ្យមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានអនុម័តដោយសំឡេងគាំទ្រ៦ទល់នឹង៥ និងអនុប្បវាទ ១ (ដូចឯកសារខាងលើ ទំព័រ១៣៣ កថាខណ្ឌ៥៩)។ *សូមមើល* កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី៩០នៃគណៈកម្មការនីតិកម្មអន្តរជាតិ A/CN.4/SR.90 ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៥១ ទំព័រ៧០-៧១ កថាខណ្ឌ១៣៨-១៣៩។ របាយការណ៍ទីពីរ

ច្បាប់អន្តរជាតិជាធរមាន និង ខ. ការអភិវឌ្ឍច្បាប់អន្តរជាតិ[91]។ ការរៀបចំសេចក្តីព្រាងក្រមថ្មីមួយស្តីពីបទល្មើស ជាឧទាហរណ៍នៃការរួមចំណែករបស់គណៈកម្មការនីតិកម្មអន្តរជាតិចំពោះការវិវឌ្ឍរីកចម្រើនទៅមុខនៃច្បាប់អន្តរជាតិ[92]។ ដូច្នេះ បើទោះជា គេអាចគិតថា ពង្រាងច្បាប់ដែលមិនត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិក្តី បង្កើតបានជា "ភស្តុតាងអំពីមតិយោបល់អ្នកជំនាញច្បាប់ព្រហ្មទណ្ឌអន្តរជាតិមកពីបណ្តាប្រទេសដែលមានការពាក់ព័ន្ធដែលបានពិចារណាលើបញ្ហានេះ"[93] ក៏ការពិភាក្សាវែកញែកក្នុងចំណោមប្រតិភូរដ្ឋបង្ហាញថា ក្នុងឆ្នាំ១៩៥៤ ស្ថានភាពនៃលក្ខខណ្ឌ ទំនាក់ទំនងនេះ មិនត្រូវបានដោះស្រាយចប់ឡើយ។

**ឃ. អង្គជំនុំជម្រះសាលាដំបូង មានកំហុសដោយយល់ឃើញថា អនុសញ្ញាស្តី ពី ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឆ្នាំ ១៩៤៨ គឺជាភស្តុតាងនៃការអនុវត្តរបស់រដ្ឋ និង *សច្ចធារណ៍ធម្មានុរូប* (*opinio juris*) ពាក់ព័ន្ធនឹង លក្ខខណ្ឌតម្រូវ ទំនាក់ទំនង** [សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ២៤-២៥]

៤៣. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងប្រវត្តិចរចារលើអនុសញ្ញានេះ បង្ហាញឲ្យឃើញថា លក្ខខណ្ឌតម្រូវទំនាក់ទំនងណាមួយដែលមាន

---

ស្តី ពីសេចក្តីព្រាងស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ អ្នករាយការណ៍ពិសេស A/CN.4/44 ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៥១ ទំព័រ៥៥-៥៦។ *សូមមើលផងដែរ* Matthew Lippman *ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ* ១៧ B.C. THIRD WORLD L. J. ១៧១, ២៣២ (១៩៩៧)។ Stuart Ford *ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុង តុលាការកម្ពុជា ៖ តើទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធត្រូវបានតម្រូវទេ? ២៤* UCLA PAC. BASIN L. J. ១២៥, ១៥៧ (ឆ្នាំ ២០០៧) ("Ford"); Van Schaack, នៅទំព័រ៨២២។

[91] លក្ខន្តិកៈនៃគណៈកម្មការនីតិកម្មអន្តរជាតិ មាត្រា១៥។

[92] *សូមមើល* សេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ é របាយការណ៍របស់លោក J. Spiropoulos អ្នករាយការណ៍ពិសេស A/CN.4/25 (1950) ទំព័រ២៥៥ កថាខណ្ឌ២ កត់សម្គាល់ថា អ្នករាយការណ៍រូបនេះពុំបានរៀបចំចងក្រងនូវច្បាប់អន្តរជាតិជាធរមានឡើយ ផ្ទុយទៅវិញ បានចូលរួមក្នុងការងារដែលមាន "លក្ខណៈបែបស្នាទៗ" ទៅវិញ"។ *សូមមើលផងដែរ ឯកសារខាងលើ* ទំព័រ២៥៧ កថាខណ្ឌ២០ កត់សម្គាល់ថា គណៈកម្មការនីតិកម្មអន្តរជាតិបានពិភាក្សាបញ្ហា និងបានសន្និដ្ឋានថា សេចក្តីព្រាងក្រមឆ្នាំ១៩៥៤ស្តីពីបទល្មើស តំណាងឲ្យ"ការវិវឌ្ឍរីកចម្រើនទៅមុខនៃច្បាប់អន្តរជាតិ"។

[93] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ២៣។

អត្ថិភាពក្រោយធម្មនុញ្ញ Nuremberg "មានភាពទន់ខ្សោយ និងកំពុងបាត់បង់យ៉ាងលឿន"[៥៤]។ សហមេធាវីការពារក្តីសូមលើកឡើងថា អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឆ្នាំ១៩៤៨ មិនបង្ហាញឱ្យឃើញពីការអនុវត្តរបស់រដ្ឋជាភាគី និងពី*សច្ចធារណ៍ធម្មានុរូប* ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ។ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាឧក្រិដ្ឋកម្មដោយឡែកពីគ្នាតាមផ្លូវច្បាប់។ អង្គបុរេជំនុំជម្រះយល់ស្របដោយលើកឡើងថា ៖ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បាន "ដាកចេញយ៉ាងច្បាស់លាស់ពីនិយមន័យដើមរបស់វា ដែលមានចែងនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"[៥៥]។

៤៤. ទីមួយ ទាំងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មាន*ធាតុផ្សំអត្តនោម័ត (mens rea)* ខុសគ្នា[៥៦]។ ទីពីរ ផ្ទុយពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និយមន័យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មិនមានលក្ខខណ្ឌតម្រូវឱ្យអំពើទាំងនោះ ប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារដែលមានលក្ខណៈរាលដាល ឬជាប្រព័ន្ធសំដៅប្រឆាំងទៅនឹងប្រជាពលរដ្ឋស៊ីវិលឡើយ[៥៧]។ ចុងក្រោយ ការដកលក្ខខណ្ឌតម្រូវទំនាក់ទំនងចេញពីនិយមន័យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មិនមានផលប៉ះពាល់ដល់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ[៥៨]។ ភស្តុតាងនៃការ

---

[៥៤] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ២៤។

[៥៥] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៣០៩។

[៥៦] *សូមមើល* អនុសញ្ញាស្តីពីទប់ស្កាត់ និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, U.N.G.A. Res. 260(III), ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៤៨ ("អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជាសាសន៍ឆ្នាំ១៩៤៨") មាត្រា២៖ "ក្នុងអនុសញ្ញានាពេលបច្ចុប្បន្ននេះ អំពើប្រល័យពូជសាសន៍ សំដៅលើអំពើណាមួយក្នុងចំណោមអំពើទាំងឡាយនេះ ដែលបានប្រព្រឹត្តឡើងជាមួយនឹងចេតនាដើម្បីបំផ្លិចបំផ្លាញ ទាំងស្រុង ឬដោយផ្នែក ទៅលើជាតិសាសន៍ ជាតិពន្ធ ក្រុមពូជសាសន៍ ឬសាសនាជាដើម"។

[៥៧] *សូមមើល* លក្ខន្តិកៈ ICC មាត្រា ៧, *C.f.* អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជាសាសន៍ឆ្នាំ១៩៤៨ មាត្រា២។

[៥៨] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៣០៩។ *សូមមើលផងដែរ* Orentlicher ត្រង់ទំព័រ ២៥៨៥ កំណត់សម្គាល់ជើងទំព័រ ២១៦៖ "និយមន័យឧក្រិដ្ឋកម្ម[អំពើប្រល័យពូជសាសន៍] នៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ... មិនមានការកំហិតដូចគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានផ្តន្ទាទោសនៅតុលាការ Nuremberg នោះទេ"។

លើកឡើងនេះ មានបង្ហាញនៅក្នុងគោលការណ៍ Nuremberg ដែលរក្សាទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ នៅក្នុងនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៥០ ដែលជារយៈពេលបីឆ្នាំបន្ទាប់ពីការចាប់ផ្តើមធ្វើពង្រាងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ឆ្នាំ១៩៤៨[៩៩]។

**ង. អង្គជំនុំជម្រះសាលាដំបូង មានកំហុសដោយយល់ឃើញថា អនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីអាជ្ញាយុកាល គឺជាភស្តុតាងដ៏សំខាន់នៃការអនុវត្តរបស់រដ្ឋជាភាគី និងជា *សច្ចធារណ៍ធម្មានុរូប (opinio juris)* នៅក្នុងឆ្នាំ ១៩៦៨** [សេចក្តីសម្រេចដែល ត្រូវបានជំទាស់ កថាខណ្ឌ ២៦-២៩]

៤៥. អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថា មតិយោបល់នានារបស់រដ្ឋទាំងឡាយនៅក្នុងអំឡុងពេលចរចាអំពីអនុសញ្ញាឆ្នាំ១៩៦៨ ស្តីពីអាជ្ញាយុកាល គឺជា "មតិយោបល់សំខាន់នៅក្នុងការបញ្ជាក់អំពី *សច្ចធារណ៍ធម្មានុរូប (opinio juris)* អំពីលក្ខខណ្ឌស្តីពីទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធមកត្រឹមឆ្នាំ១៩៦៨"[១០០]។ អង្គជំនុំជម្រះសាលាដំបូងក៏បានយល់ឃើញផងដែរថា មានការគាំទ្រយ៉ាង ខ្លាំងក្លាចំពោះការមិនដាក់បញ្ចូលលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនៅក្នុងនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[១០១]។ សហមេធាវីការពារក្តីសូមស្នើថា គេមិនអាចនិយាយបានទេថា អនុសញ្ញាឆ្នាំ១៩៦៨ ស្តីពីអាជ្ញាយុកាល បង្ហាញពីការអនុវត្តជាទូទៅបានទេ។ អង្គបុរេជំនុំជម្រះក៏បានយល់ព្រមចំពោះការយល់ឃើញនេះដែរ[១០២]។

៤៦. អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយយល់ឃើញថា មានការគាំទ្រយ៉ាងខ្លាំងក្លាចំពោះការមិនដាក់បញ្ចូលលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធទៅក្នុងអនុសញ្ញា ឆ្នាំ១៩៦៨

---

[៩៩] *សូមមើល* Ford ត្រង់កថាខណ្ឌ ១៥២-១៥៣។

[១០០] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ២៩។

[១០១] *ដូចជើងទំព័រមុន* កថាខណ្ឌ ២៦។

[១០២] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៣០៩៖ "ទោះបីជាអង្គបុរេជំនុំជម្រះទទួលស្គាល់ថា ការអនុវត្តរបស់រដ្ឋមិនចាំបាច់មានលក្ខណៈដូចៗគ្នា ដែលអាចចាត់ទុកជាការអនុវត្តទូទៅក៏ដោយ ក៏គេមិនអាចនិយាយបានថា អនុសញ្ញាស្តីពីអាជ្ញាយុកាលឆ្នាំ១៩៦៨ ស្របទៅនឹងកម្រិតនៃការទទួលយកមួយ ដើម្បីក្លាយជាការអនុវត្តជាទូទៅបានទេ"។

ស្តីពីអាជ្ញាយុកាល។ នៅពេលដែលពង្រាងនិយមន័យត្រូវបានដាក់ជាសំណើ ដោយផ្អែកលើនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងសេចក្តីព្រាងក្រមស្តីពីបទល្មើសឆ្នាំ ១៩៥៤ នោះ រដ្ឋចំនួនប្រាំមួយ ដែលរួមមានបណ្តារដ្ឋស្ថិតនៅក្នុងប្លុកសូវៀត បានគាំទ្រការប្រើប្រាស់ពាក្យពេចន៍ ប៉ុន្តែមិនបានលើកឡើងឱ្យបានច្បាស់ពីលក្ខខណ្ឌទំនាក់ទំនងទេ[១០៣] ហើយមានរដ្ឋមួយបានធ្វើការកត់សម្គាល់ ព្រមទាំងយល់ស្របចំពោះការមិនដាក់បញ្ចូលលក្ខខណ្ឌទំនាក់ទំនង[១០៤]។ រដ្ឋមួយចំនួនធំបានធ្វើការរិះគន់ពង្រាងនិយមន័យ ដោយលើកឡើងថានិយមន័យនេះមានភាព "ស្រពេចស្រពិលមិនច្បាស់លាស់ ឬពន្លាតអត្ថន័យទូលាយពេក"[១០៥]។ មហាសន្និបាតអង្គការសហប្រជាជាតិមិនធ្លាប់បានបោះឆ្នោតអនុម័តលើពង្រាងនិយមន័យទេ[១០៦]។

៤៧. អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយយល់ឃើញថា ការខកខានរបស់អនុសញ្ញាឆ្នាំ១៩៦៨ ស្តីពីអាជ្ញាយុកាល ក្នុងការប្រមូលផ្តុំការគាំទ្រយ៉ាងខ្លាំងក្លាពីសំណាក់រដ្ឋជាសមាជិកអង្គការសហប្រជាជាតិនោះ គឺដោយសារតែការដាក់បញ្ចូលឧក្រិដ្ឋកម្មនៃការប្រកាន់ពូជសាសន៍ និងការជម្លៀស

---

[១០៣] Ford, ត្រង់កថាខណ្ឌ ១៦៥, *ដកស្រង់* កម្រងសំណួរស្តីអំពីការផ្តន្ទាទោស ឧក្រិដ្ឋជនសង្គ្រាម និងបុគ្គលដែលបានប្រព្រឹត្ត អំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ, A/71774, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៦៨, ទំព័រ ៦, ៨, ៣៦, ៤១, ៤៣, ៤៥។

[១០៤] Ford, ត្រង់កថាខណ្ឌ ១៦៤-១៦៥, *ដកស្រង់* កម្រងសំណួរស្តីអំពីការផ្តន្ទាទោស ឧក្រិដ្ឋជនសង្គ្រាម និងបុគ្គលដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ, A/71774, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៦៨, ទំព័រ ១៥។

[១០៥] Ford, ត្រង់កថាខណ្ឌ ១៦៥, *ដកស្រង់* កម្រងសំណួរស្តីអំពីការផ្តន្ទាទោស ឧក្រិដ្ឋជនសង្គ្រាម និងបុគ្គលដែលបានប្រព្រឹត្ត អំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ, A/71774, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៦៨, ទំព័រ ៩, ១៤, ១៧, ២០, ២២-២៣, ២៦, ៤៧។ កម្រងសំណួរស្តីអំពីការផ្តន្ទាទោស ឧក្រិដ្ឋជនសង្គ្រាម និងបុគ្គលដែលបានប្រព្រឹត្ត អំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, កំណត់ហេតុរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ, A/7174/Add.2, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៦៨, ទំព័រ ២។ កម្រងសំណួរស្តីអំពីការផ្តន្ទាទោស ឧក្រិដ្ឋជនសង្គ្រាម និងបុគ្គលដែលបានប្រព្រឹត្ត អំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, កំណត់ហេតុរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ, A/7174/Add.3, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៦៨, ទំព័រ ៤។

[១០៦] Ford, ត្រង់កថាខណ្ឌ ១៦៦។

ដោយការវាយប្រហារដោយអាវុធ ឬការកាន់កាប់នៅក្នុងអនុសញ្ញានេះ[១០៧]។ យោងតាមមតិរបស់អ្នកជំនាញម្នាក់ ដែលអង្គជំនុំជម្រះសាលាដំបូងបានដកស្រង់ រដ្ឋទាំងឡាយបានបោះឆ្នោតជំទាស់នឹងអនុសញ្ញាឆ្នាំ១៩៦៨ ស្តីពីអាជ្ញាយុកាល ដោយសារតែរដ្ឋទាំងនោះ "បានចាត់ទុកការខ្វះចន្លោះរបស់អនុសញ្ញានោះ ថាមានលក្ខណៈជាសារវ័ន្ត និងមានចំនួនច្រើន ដែលធ្វើឱ្យរដ្ឋទាំងនោះមិនអាចធ្វើការគាំទ្របាន" ជាពិសេសដោយសារតែអនុសញ្ញា ឆ្នាំ១៩៦៨ ស្តីពីអាជ្ញាយុកាល បានរំលោភបំពានទៅលើគោលការណ៍នៃអានុភាពមិនប្រតិសកម្ម[១០៨]។

៤៨. វាមិនមែនជារឿងតូចតាចនោះទេ ដែលអនុសញ្ញាឆ្នាំ១៩៦៨ ស្តីពីអាជ្ញាយុកាល មិនមានការគាំទ្រឱ្យបានខ្លាំងក្លានោះ។ អនុសញ្ញានេះគឺជា "ឯកសារនយោបាយមូលដ្ឋានដ៏សំខាន់មួយ"[១០៩] ដែលបានទទួលការគាំទ្រចំនួនតិចជាងពាក់កណ្តាលនៃរដ្ឋជាសមាជិកអង្គការសហប្រជាជាតិ ដែលមានចំនួន ១២៦ នាពេលនោះ នៅពេលដែលឯកសារមួយនេះត្រូវបានអនុម័ត និងបើកឱ្យចុះហត្ថលេខា[១១០]។

---

[១០៧] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ២៩ *ដកស្រង់* Robert H. Miller, *អនុសញ្ញាស្តីអំពីការមិនអនុវត្តទៅបាននៃអាជ្ញាយុកាល ចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិ* ("Miller"), 65 AM. J. INT"L L. 477, 500 (ឆ្នាំ១៩៧១), គណៈកម្មាធិការ ស្តីពីសិទ្ធមនុស្ស របាយការណ៍អង្គប្រជុំលើកទីម្ភៃបី ថ្ងៃទី២០ ខែ កុម្ភៈ ឆ្នាំ១៩៦៧ ដល់ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៦៧ កថាខណ្ឌ ១៤៤-១៤៥។

[១០៨] Miller, ត្រង់ទំព័រ ៥០០។

[១០៩] Ford, ត្រង់ទំព័រ ១៦០។ *សូមមើលផងដែរ* Yoram Dinstein *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ*, 20 ISR. L. REV. 206, 232 (1985) ("Dinstein"): "អនុសញ្ញា ត្រូវបានទទួលស្គាល់ថាមានលក្ខណៈចម្រូងចម្រាសយ៉ាងខ្លាំង ដោយសារ [មាត្រា I] មិនចាំបាច់ត្រូវកំណត់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងប្រព្រឹត្តទៅតាមវិធីសាស្ត្រមួយដែលតាមតែអំពើចិត្ត និងលំអៀង, គោលដៅរបស់អនុសញ្ញានេះ គឺមិនសូវផ្តោតលើឧក្រិដ្ឋជននៃសង្គ្រាមលោកលើកទីពីរ និងផ្តោតសំខាន់ទៅលើឧក្រិដ្ឋជននៅប្រទេសអាហ្វ្រិកខាងត្បូង និងប្រទេសអ៊ីស្រាអែល"; Natan Lerner, *អនុសញ្ញា ស្តីអំពី ការមិនអនុវត្តអាជ្ញាយុកាល ចំពោះឧក្រិដ្ឋកម្មសង្គ្រាម*, 4 ISR. L. REV. 512, 525 (1969): "ការដែលមាត្រា I [ដែលកំណត់និយមន័យឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ] ត្រូវបានអនុម័តដោយគណៈកម្មាធិការទីបី ដោយសម្លេងបោះឆ្នោតចំនួន ៥៩ សម្លេងទល់នឹង ១២ សម្លេង និងអនុប្បវាទចំនួន ២៧ សម្លេង ហើយក៏ត្រូវបានអនុម័តដោយក្រុមការងាររួម ដោយសម្លេងបោះឆ្នោត ៨ សម្លេងទល់នឹង ២ សម្លេង និងអនុប្បវាទចំនួន ៥ សម្លេងនោះ បង្ហាញឱ្យឃើញពីកម្រិតនៃភាពចម្រូងចម្រាសនៃបញ្ហានេះដែលជាប់ពាក់ព័ន្ធទៅនឹងនយោបាយ"។

[១១០] Miller, ត្រង់កថាខណ្ឌ ៤៧៧-៤៧៨។ *សូមមើលផងដែរ* Goldenberg, ត្រង់កថាខណ្ឌ ៥០; Orentlicher, ត្រង់កថាខណ្ឌ ២៥៩១, កំណត់សម្គាល់ជើងទំព័រ ២៤០។

គិតមកត្រឹមថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មានតែរដ្ឋជាសមាជិកអង្គការសហប្រជាជាតិចំនួន ១៨ប៉ុណ្ណោះ នៃចំនួនរដ្ឋជាសមាជិកសរុបចំនួន ១៣៤ បានចុះហត្ថលេខា ផ្តល់សច្ចាប័ន ឬ ចូលជាភាគីលើអនុសញ្ញាឆ្នាំ១៩៦៨ ស្តីពីអាជ្ញាយុកាល[១១១]។ មានរដ្ឋជាសមាជិកមួយទៀត បានផ្តល់សច្ចាប័នបន្ថែមទៅលើអនុសញ្ញាឆ្នាំ១៩៦៨ ស្តីពីអាជ្ញាយុកាល ក្នុងអំឡុងពេលយុត្តាធិការពេលវេលារបស់ អ.វ.ត.ក[១១២]។ ចំនួនដ៏តិចតួចនៃរដ្ឋជាសមាជិកដែលបានចុះហត្ថលេខា ផ្តល់សច្ចាប័ន ឬ ចូលជាភាគីនៃអនុសញ្ញាក្នុងអំឡុងពេលយុត្តាធិការពេលវេលារបស់ អ.វ.ត.ក នេះ មិនមែនជាភស្តុតាងបង្ហាញឲ្យឃើញពីការអនុវត្តរបស់រដ្ឋ ដែលមាន "ទម្រង់យ៉ាងទូលំទូលាយ និងមានឯកភាពគ្នាជាក់ស្តែង" ឬឲ្យឃើញពីការជឿជាក់ជាអត្តនោម័តរបស់បណ្តារដ្ឋ ថាពួកគេបានអនុវត្តតាមកាតព្វកិច្ចផ្លូវច្បាប់មួយនេះ[១១៣]។

**ច. អង្គជំនុំជម្រះមានកំហុស ដោយយល់ឃើញថា អនុសញ្ញាឆ្នាំ ១៩៧៣ ស្តីពីការប្រកាន់ពូជសាសន៍ គឺជាការបង្ហាញពីការអនុវត្តរបស់រដ្ឋ និង*សច្ចធារណ៍ធម្មានុរូប* *(opinior juris)* លើលក្ខខណ្ឌស្តីពីទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ** [សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣០]

៤៩. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា អនុសញ្ញាឆ្នាំ១៩៧៣ ស្តីពីការប្រកាន់ពូជសាសន៍ គឺជាភស្តុតាងបង្ហាញពីស្ថានភាពទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[១១៤]។ សហមេធាវីការពារក្តីសូមលើកឡើងថា អនុសញ្ញាឆ្នាំ១៩៧៣ ស្តីពីការប្រកាន់ពូជសាសន៍ មិនមែនជាការបង្ហាញពីការអនុវត្តរបស់រដ្ឋ និង*សច្ចធារណ៍ធម្មានុរូប (opinior juris)* ស្តីពីបញ្ហានេះនោះទេ។ អង្គបុរេជំនុំជម្រះក៏បានយល់ស្របចំពោះការលើកឡើងនេះដែរ[១១៥]។

---

[១១១] *សូមមើល* សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៣០៩។ *សូមមើលផងដែរ* ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ២៨។ ការឆ្លើយតបរបស់ អៀង សារី កថាខណ្ឌ ៩០។

[១១២] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៣០៩។

[១១៣] *សូមមើល រឿងក្តី North Sea Continental Shelf* ទំព័រ ៤៣ កថាខណ្ឌ ៧៤; ទំព័រ ៤៥ កថាខណ្ឌ ៧៧។

[១១៤] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣០។

[១១៥] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៣០៩។

៥០. អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការវិភាគ និងយល់ឃើញរបស់ខ្លួនចំពោះអនុសញ្ញាឆ្នាំ១៩៧៣ ស្តីពីការប្រកាន់ពូជសាសន៍។ ពាក់ព័ន្ធនឹងការធ្វើសេចក្តីព្រាងអនុសញ្ញាឆ្នាំ១៩៧៣ ស្តីពីការប្រកាន់ពូជសាសន៍ អង្គជំនុំជម្រះសាលាដំបូងបានលើកពីការថ្លែងមតិរបស់សមាជិកប្រតិភូមួយរូប ដែលបានលើកឡើងថា និយមន័យរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងធម្មនុញ្ញ Nuremberg និងគោលការណ៍ Nuremberg ពុំមានការពង្រីកអត្ថន័យបន្ថែមនោះទេ ហេតុដូច្នេះហើយការប្រកាន់ពូជសាសន៍ មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ យោងតាមន័យរបស់ច្បាប់។ អង្គជំនុំជម្រះសាលាដំបូងមិនបានរៀបរាប់ឲ្យបានលម្អិតបន្ថែមទៀតនោះទេពីខ្លឹមសារនៃការចរចារដែលឈានទៅដល់ការអនុម័តអនុសញ្ញាឆ្នាំ១៩៧៣ ស្តីពីការប្រកាន់ពូជសាសន៍នោះទេ។ អង្គជំនុំជម្រះសាលាដំបូង *គ្រាន់តែបានលើកឡើង ដោយមិនបានដកស្រង់សេចក្តីសំអាងផ្លូវច្បាប់ ឬឯកសារមកធ្វើជាអំណះអំណាង* ថា មតិយោបល់របស់សមាជិកប្រតិភូរូបនោះ "ត្រូវបានបដិសេធភ្លាមៗ នៅពេលដែលអនុសញ្ញាឆ្នាំ១៩៧៣ ស្តីពីការប្រកាន់ពូជសាសន៍ ត្រូវបានអនុម័តនៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៣"[១១៦]។

៥១. ដូចអនុសញ្ញាឆ្នាំ១៩៦៨ ស្តីពីអាជ្ញាយុកាលដែរ អនុសញ្ញាឆ្នាំ១៩៧៣ ស្តីពីការប្រកាន់ពូជសាសន៍គឺជាឯកសារនយោបាយមួយ[១១៧]។ ឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍គឺជាអំពើជាមូលដ្ឋានមួយ ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ឧក្រិដ្ឋកម្មនេះតម្រូវឲ្យមានចេតនាពីសំណាក់ក្រុមពូជសាសន៍មួយក្នុងការបង្កើត និងរក្សាការគ្របដណ្តប់ទៅលើក្រុមពូជសាសន៍ផ្សេងៗទៀត ព្រមទាំងកៀបសង្កត់ជាលក្ខណៈប្រព័ន្ធទៅលើក្រុមនោះ[១១៨]។ ដោយសារតែការប៉ុនប៉ងសំដៅ "អនុវត្តការរើសអើង និងបែងចែកពូជសាសន៍ ដូចដែលអនុវត្តនៅប្រទេសអាហ្វ្រិកខាងត្បូង"[១១៩] នោះ

---

[១១៦] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣០។

[១១៧] Ford, ត្រង់កថាខណ្ឌ ១៦៨-១៦៩ ។ *សូមមើលផងដែរ* Dinstein, ត្រង់កថាខណ្ឌ ២១៧។

[១១៨] អនុសញ្ញាអន្តរជាតិ ស្តីអំពី ការកៀបសង្កត់ និងផ្តន្ទាទោសទៅលើឧក្រិដ្ឋកម្មនៃការប្រកាន់ពូជសាសន៍, U.N.G.A. Res. 3068(XXVII), ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៣ មាត្រា II, Art. II ("អនុសញ្ញាឆ្នាំ ១៩៧៣ ស្តីពីការប្រកាន់ពូជសាសន៍")។ *សូមមើលផងដែរ* ធាតុផ្សំរបស់ ICC នៃឧក្រិដ្ឋកម្ម (ត្រូវបានអនុម័តនៅថ្ងៃ ៩ ខែ កញ្ញា ឆ្នាំ ២០០២, ចូលជាធរមាននៅថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០០២), មាត្រា ៧(១)(ញ)។

[១១៩] អនុសញ្ញាឆ្នាំ១៩៧៣ ស្តីពីការប្រកាន់ពូជសាសន៍ មាត្រា II។

ក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក អនុសញ្ញានេះមិនត្រូវបានចុះហត្ថលេខា ផ្តល់សច្ចាប័ន ឬចូលជាភាគីពីសំណាក់រដ្ឋជាសមាជិកអង្គការសហប្រជាជាតិជាច្រើន[១២០]។ អង្គបុរេជំនុំជម្រះយល់ឃើញថា នៅត្រឹមថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ក្នុងចំណោមរដ្ឋជាសមាជិកទាំង ១៣៤ គឺមានតែរដ្ឋជាសមាជិកចំនួន ២៥ ប្រទេសប៉ុណ្ណោះ ដែលបានចុះហត្ថលេខា ផ្តល់សច្ចាប័ន ឬចូលជាភាគីអនុសញ្ញាឆ្នាំ ១៩៧៣ ស្តីពីការប្រកាន់ពូជសាសន៍[១២១]។ គិតត្រឹមកាលបរិច្ឆេទដែលអនុសញ្ញាឆ្នាំ១៩៧៣ ស្តីពីការប្រកាន់ពូជសាសន៍ បានចូលជាធរមាន គឺនៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៦ គ្មានប្រទេសណាមួយនៃបណ្តាប្រទេសលោកខាងលិច បានចុះហត្ថលេខាលើអនុសញ្ញានេះឡើយ[១២២]។ ការលើកឡើងនេះចង្អុលបង្ហាញយ៉ាងច្បាស់ និងប្រាកដនូវកង្វះ "ទម្រង់យ៉ាងទូលំទូលាយ និងមានឯកភាពគ្នាជាក់ស្តែង" នៃការអនុវត្តរបស់រដ្ឋ និង*សច្ចធារណ៍ធម្មានុរូប (opinior juris)*[១២៣] ក្នុងការវាយតម្លៃស្ថានភាពរបស់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[១២៤] នៅចន្លោះពីឆ្នាំ១៩៧៥-១៩៧៩ ស្ថិតក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ត្រឹមថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ មានរដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិចំនួនតែ ៤៨ ប្រទេសប៉ុណ្ណោះ បានចុះហត្ថលេខា ផ្តល់សច្ចាប័ន ឬចូលជាភាគីអនុសញ្ញា ឆ្នាំ១៩៧៣ ស្តីពីការប្រកាន់ពូជសាសន៍[១២៥]។ ក្រោយមក កម្ពុជាប្រជាធិបតេយ្យបានចូលជាភាគីនៃអនុសញ្ញាស្តីពីការប្រកាន់ពូជ

---

១២០ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៣០៩។

១២១ *ដូចជើងទំព័រមុន*។

១២២ ការឆ្លើយតបរបស់ អៀង សារី កថាខណ្ឌ ៨៨។

១២៣ *សូមមើលរឿងក្តី* North Sea Continental Shelf, ទំព័រ ៤៣ កថាខណ្ឌ ៧៤។

១២៤ ការឆ្លើយតបរបស់ អៀង សារី កថាខណ្ឌ ៨៨។ *សូមមើលផងដែរ* Ford, ត្រង់ ១៦៩; Orentlicher, ត្រង់ ២៥៩១, កំណត់សម្គាល់ជើងទំព័រ ២៤០។

១២៥ អង្គការសហប្រជាជាតិ, *សន្ធិសញ្ញា Multilateral Treaties Deposited with the Secretary-General Treaty Series* Database, "Status of Treaties" វគ្គ IV, ៧។ គួរកត់សម្គាល់ដែរថា សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើកឡើងថា រដ្ឋជាសមាជិកអង្គការសហប្រជាជាតិ បានចុះហត្ថលេខា ផ្តល់សច្ចាប័ន ឬចូលជាភាគី នៃអនុសញ្ញាស្តីពីការប្រកាន់ពូជសាសន៍ក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។ *សូមមើល* សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៣០៩។ នេះអាចជាកំហុសដ៏សំខាន់មួយ។ ក្នុងគោលបំណងនៃការដាក់បណ្តឹងសាទុក្ខនេះ សហមេធាវីការពារក្តី អៀង សារី បានធ្វើការស្ទង់មតិដោយផ្ទាល់ពីស្ថានភាពរបស់បណ្តាភាគីចំពោះអនុសញ្ញាស្តីពីការប្រកាន់ពូជសាសន៍ នៅ

សាសន៍នៅក្នុង ឆ្នាំ១៩៨២ ដែលអង្គជំនុំជម្រះសាលាដំបូង បានយោងនោះ មិនមានសារសំខាន់ទាល់តែសោះជាមួយនឹងបញ្ហានៃស្ថានភាពច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងចន្លោះពេលពីឆ្នាំ ១៩៧៥-១៩៧៩ នោះ[១២៦]។

ជ. **អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការចាត់ទុកការវិវឌ្ឍន៍នៅក្រោយឆ្នាំ ១៩៧៩ ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ថាមានជាប់ពាក់ព័ន្ធទៅនឹងស្ថានភាពនៃទំនាក់ទំនងជម្លោះប្រដាប់អាវុធ ក្នុងចន្លោះពេលពីឆ្នាំ ១៩៧៥-១៩៧៩** [សេចក្តីសម្រេចដែលត្រូវបាន ជំទាស់ កថាខណ្ឌ ៣១-៣២]

៥២. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា លក្ខន្តិកៈរបស់តុលាការ ICTY លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដាឆ្នាំ១៩៩៤ ("ICTR") និងលក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ("SCSL")ឆ្នាំ២០០០ បង្ហាញឲ្យឃើញថា ទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ "លែងជាផ្នែកមួយនៃនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទៀតហើយ"[១២៧]។ សហមេធាវីការពារក្តីសូមលើកឡើងថា សំអាងផ្លូវច្បាប់ទាំងនេះមិនបានផ្តល់ភស្តុតាងប្រាកដប្រជាសម្រាប់បង្ហាញថា ក្នុងរយៈពេលចន្លោះពីឆ្នាំ១៩៧៥-១៩៧៩ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនបានទាមទារឲ្យមានទំនាក់ទំនងជម្លោះប្រដាប់អាវុធនៅក្នុងនិយមន័យនៃ

---

ចន្លោះរយៈពេលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ព្រមទាំងបានគណនាចំនួនរដ្ឋបន្ថែមទៀតដែលបាន ចុះហត្ថលេខា ផ្តល់សច្ចាប័ន ឬចូលជាភាគី នៃអនុសញ្ញាស្តីពីការប្រកាន់ពូជសាសន៍ ក្នុងអំឡុងពេលពាក់ព័ន្ធ ដែលមានចំនួន ២៣ រដ្ឋ មិនមែន ៣២ រដ្ឋនោះទេ។ ចំណុចដែលសំខាន់ ចំនួននេះធ្វើឲ្យអនុសញ្ញាស្តីពីការប្រកាន់ពូជសាសន៍មានលក្ខណៈ សម្បត្តិមិនគ្រប់គ្រាន់ក្នុងការបង្ហាញពីស្ថានភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងរយៈពេលចន្លោះពីឆ្នាំ ១៩៧៥-១៩៧៩ ស្តីពីលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធឡើយ។

[១២៦] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣០។

[១២៧] *ដូចជើងទំព័រមុន* កថាខណ្ឌ ៣១។

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ។ អង្គបុរេជំនុំជម្រះយល់ស្រប[១២៨] ចំពោះការលើកឡើងនេះ។

៩៣. អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយយល់ឃើញថា និយមន័យរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចែងនៅក្នុងលក្ខន្តិកៈរបស់តុលាការ ICTY មិនបានឆ្លុះបញ្ចាំងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ។ និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងលក្ខន្តិកៈតុលាការ ICTY មានចែងពីទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ[១២៩]។ អង្គជំនុំជម្រះឧទ្ធរណ៍ជំនុំជម្រះរឿងក្តី *Tadić* បានសម្រេចថា លក្ខខណ្ឌទំនាក់ទំនងគឺជាការកម្រិតផ្នែកយុត្តាធិការជាក់លាក់ចំពោះតុលាការ ICTY ហើយថា អ្នករៀបចំពង្រាងលក្ខន្តិកៈនេះ បានកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឲ្យមានខ្លឹមសារចង្អៀតជាងខ្លឹមសារដែលមានបង្ហាញនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[១៣០]។ យ៉ាងណាក៏ដោយ តុលាការ ICTY មានចេតនាមិនអើពើចំពោះការអនុវត្តយុត្តាធិការរបស់ខ្លួនទេ ដោយអនុម័ត "វិធីសាស្ត្រពន្លាតន័យឲ្យទូលាយ"[១៣១] ដែលធ្វើឲ្យនិយមន័យ

---

[១២៨] សេចក្តីសម្រេចអង្គបុរេជំនុំជម្រះ កថាខណ្ឌ ៣០៧។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ករណី នួន ជា កថាខណ្ឌ ១៤៣។

[១២៩] លក្ខន្តិកៈរបស់តុលាការ ICTY មាត្រា ៥។

[១៣០] សូមមើល *Tadić* បណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ កថាខណ្ឌ ១៤០-១៤១។

[១៣១] *សូមមើលជាឧទាហរណ៍, រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić,* IT-94-1-A, សាលដីកា ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៨៥-២៣៤ ដោយនៅក្នុងសាលដីកានោះ អង្គជំនុំជម្រះឧទ្ធរណ៍ បានបង្កើតទ្រឹស្តីស្តីពីសហកម្មឧក្រិដ្ឋកម្មរួម ("JCE") ជាទម្រង់មួយនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ JCE បានក្លាយជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌមួយ ដែលចម្រូងចម្រាសបំផុត ត្រូវបានយកមកអនុវត្តនៅសាលាក្តី *ពិសេស* មួយចំនួន ដោយសារទម្រង់នេះត្រូវបានគេយល់ឃើញថា ជាច្បាប់ដែលចៅក្រមបានធ្វើ មិនផ្អែកលើមូលដ្ឋាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ *សូមមើល* William A. Schabas, ធាតុផ្សំអត្តនោម័ត *និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី,* 37 NEW ENGLAND L. REV. 1015, 1033-34 (2002-2003): "បានទទួលយកវិធីសាស្ត្រទាំងពីរនេះ [JCE និង ការទទួលខុសត្រូវរបស់ថ្នាក់លើ] សម្រួលដល់ការចោទប្រកាន់ទៅលើបុគ្គលដែលបានចូលរួមជាក់ស្តែងក្នុងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធមនុស្ស។ ប៉ុន្តែវិធីសាស្ត្រទាំងនេះធ្វើឲ្យបន្ថយការផ្តន្ទាទោសដែលចៀសមិនផុតពីការប៉ះពាល់ដល់តម្លៃនៃសាលក្រមតុលាការនោះ និងប៉ះពាល់ដល់កេរ្តិ៍ដំណែលជាប្រវត្តិសាស្ត្ររបស់សាលាក្តីផងដែរ"; សូមមើល Ciara Damgaard, *ទ្រឹស្តីសហឧក្រិដ្ឋកម្មរួម (The Joint Criminal Enterprise Doctrine): A "Monster Theory of Liability" or a Legitimate and Satisfactory Tool in the Prosecution of the Perpetrators of Core International Crimes?, in* INDIVIDUAL CRIMINAL RESPONSIBILITY FOR CORE INTERNATIONAL CRIMES 129 (Springer, 2008): ទ្រឹស្តីបទនេះបានបង្កើតជាបញ្ហា ព្រួយបារម្ភធ្ងន់ធ្ងរមួយចំនួន។ *ក្នុងចំណោមនោះ* គេអាចលើកឡើងបានផងដែរថា

ឧក្រិដ្ឋកម្មអន្តរជាតិមាន "លក្ខណៈជាអារម្មណ៍ និង*ជាអ្វីដែលជាការយល់ឃើញ ជាជាងអ្វីជាច្បាប់នោះ* (*de lege ferenda*)[១៣២]។ ការយល់ឃើញរបស់អង្គជំនុំជម្រះឧទ្ធរណ៍ស្តីពីបញ្ហាទំនាក់ទំនង មិនមែនជា ភស្តុតាងប្រាកដប្រជាដែលបញ្ជាក់ថា កង្វះលក្ខខណ្ឌទំនាក់ទំនងនៅក្នុងនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺ "លើសពីវិមតិសង្ស័យ" នៅក្នុងឆ្នាំ១៩៩៣។

៥៤. តុលាការ ICTY ត្រូវបានបង្កើតឡើង ដើម្បីជំនុំជម្រះបុគ្គលមួយចំនួនពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានប្រព្រឹត្តឡើងចាប់តាំងពីឆ្នាំ១៩៩១ នៅលើដែនដីនៃអតីតប្រទេសយូហ្គោស្លាវី[១៣៣]។ អ្នករៀបចំពង្រាងលក្ខន្តិកៈរបស់តុលាការ ICTY មានបំណងធានាឲ្យបានថា គោលការណ៍នីត្យានុកូលភាពត្រូវបានគោរព ហេតុដូច្នេះហើយ ទើបមានការសម្រេចថា លក្ខន្តិកៈអាចមានយុត្តាធិការតែលើផ្នែកមួយចំនួននៃច្បាប់មនុស្សធម៌អន្តរជាតិ ដែល

វាមានភាពមិនប្រាកដប្រជា ធ្វើឲ្យប៉ះពាល់ដល់បទដ្ឋានភស្តុតាងនានា ធ្វើឲ្យប៉ះពាល់ដល់គោលការណ៍ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គល ដោយគាំទ្រការទទួលខុសត្រូវជារួម រំលោភបំពានគោលការណ៍ គ្មានបទល្មើស បើគ្មានច្បាប់ចែង ព្រមទាំងរំលោភបំពាន លើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌មួយផងដែរ"។

[១៣២] Susan Lamb, គោលការណ៍នីត្យានុកូលភាព (Nullum Crimen, Nulla Poena Sine Lege) *នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ*, *in* 1 THE ROME STATUTE OF THE INTERNATIONAL CRIMINAL COURT: A COMMENTARY 743, 746 (Cassese, Gaeta, Jones, eds., 2002) ។ នៅក្នុងការពិភាក្សារបស់ខ្លួន ស្តីពីវិធីសាស្ត្រពន្យាតន័យរបស់សាលាក្តី*ពិសេស* អ្នកនាង Lamb បានដកស្រង់ប្រសាសន៍របស់ចៅក្រម Meron, ពាក់ព័ន្ធនឹងការបកស្រាយច្បាប់មនុស្សធម៌អន្តរជាតិរបស់សាលាក្តីនានា: ចៅក្រម Meron បានលើកឡើងថា "យោងលើនិន្នាការមិនយកចិត្តទុកដាក់ លើផ្នែកមួយចំនួនធំ នោះភស្តុតាងដែលអាចរកបានស្តីពីការអនុវត្តរបស់រដ្ឋ (ពិបាកនឹងរកបាន) ... ជាក់ស្តែង គេអាចនឹងយល់បានថា សាលាក្តីបានគិតគូរ ឬទំនងជាបន្តគិតគូរទៅលើកម្រិតនៃការវាយលុកទៅលើអំពើចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។ បើអំពើកាន់តែសាហាវយង់ឃ្នង នោះសាលាក្តីកាន់តែអាចនឹងធ្វើការសន្មតថា អំពើនោះរំលោភបំពានមិនត្រឹមតែលើគោលការណ៍មនសិការរបស់មនុស្សជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទៅលើច្បាប់ទំនៀមទម្លាប់ផងដែរ"។ Theodor Meron, *អនុសញ្ញាផ្សេងៗនៅទីក្រុងហ្សឺណែវ ជាច្បាប់ទំនៀមទម្លាប់* (*The Geneva Conventions as Customary Law)*, 81 Am. J. Int'l L. 348, 361 (1987)។

[១៣៣] លក្ខន្តិកៈរបស់តុលាការ ICTY មាត្រា ១។

"លើសពីវិមតិសង្ស័យ" ជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ[១៣៤]។ ប្រភពពាក់ព័ន្ធទាំងបួននៃច្បាប់មនុស្សធម៌អន្តរជាតិនោះគឺ អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ អនុសញ្ញាទីក្រុងឡាអេឆ្នាំ១៩០៧ អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងធម្មនុញ្ញ Nuremberg[១៣៥]។ អ្នករៀបចំពង្រាងលក្ខន្តិកៈរបស់តុលាការ ICTY បានចាត់ទុកថា វា "លើសពីវិមតិសង្ស័យ" ដែលថានិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមបញ្ចូលទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ[១៣៦] ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះ។

៩៥. អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយយល់ឃើញថា លក្ខន្តិកៈរបស់តុលាការ ICTR ឆ្នាំ១៩៩៤ ដែលនៅក្នុងលក្ខន្តិកៈនោះបានលុបបំបាត់ចោលទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ បង្កើតជាភស្តុតាង ដែលបញ្ជាក់ថា ទំនាក់ទំនងនេះលែងជាផ្នែកមួយនៃនិយមន័យរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៀតហើយ[១៣៧]។ លោកសាស្ត្រាចារ្យ Schabas បានលើកហេតុផលថា ពាក្យពេចន៍ដែលប្រើនៅក្នុងលក្ខន្តិកៈ ត្រូវបានអគ្គលេខាធិការអង្គការសហប្រជាជាតិ ចាត់ទុកថា "ឃ្លាតចាកចេញពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[១៣៨]។ ខុសគ្នាពីលក្ខន្តិកៈរបស់តុលាការ ICTY ដែល ពង្រាងលក្ខន្តិកៈមួយនេះត្រូវបានរៀបរៀងដោយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ

---

[១៣៤] របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ អនុលោមតាមកថាខណ្ឌ ២ នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ៨០៨ (ឆ្នាំ១៩៩៣), S/25704, ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ១៩៩៣ កថាខណ្ឌ ៣៣។

[១៣៥] *ដូចជើងទំព័រមុន* កថាខណ្ឌ ៣៥។

[១៣៦] *សូមមើល* WILLIAM A. SCHABAS, THE INTERNATIONAL CRIMINAL COURT: A COMMENTARY ON THE ROME STATUTE (Oxford University Press, 2010) ទំព័រ ១៤៥ ("SCHABAS"): "ដោយមិនចាំបាច់មានមន្ទិលសង្ស័យច្រើន អ្នកដែលបម្រើការងារនៅក្នុងលេខាធិការដ្ឋានអង្គការសហប្រជាជាតិ ដែលបានធ្វើពង្រាង [មាត្រា៥ នៃលក្ខន្តិកៈរបស់តុលាការ ICTY] ជឿថា [ទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ] ត្រូវបានប្រើប្រាស់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយថា ការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយមិនមានជម្លោះប្រដាប់អាវុធនោះ គឺជាការរំលោភបំពានទៅលើគោលការណ៍ *គ្មានទោស បើគ្មានច្បាប់ចែង'* ។ *សូមមើលផងដែរ* Ford, ត្រង់ទំព័រ ១៧៥។

[១៣៧] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣១។

[១៣៨] SCHABAS, ត្រង់ទំព័រ ១៤៥, *ដកស្រង់* របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ អនុលោមតាមកថាខណ្ឌ ៥ នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ៩៥៥ (ឆ្នាំ១៩៩៤), S/1995/134, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ("របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ"), កថាខណ្ឌ ១២។

រួច បញ្ជូនទៅក្រុមប្រឹក្សាសន្តិសុខ ជាមួយនឹងមូលដ្ឋានច្បាប់មួយចំនួនសម្រាប់លក្ខន្តិកៈនោះ ពង្រាងលក្ខន្តិកៈ ICTR ត្រូវបានរៀបរៀងឡើងដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិតែឯងប៉ុណ្ណោះ[១៣៩]។ មានការមិនយល់ស្របមួយចំនួនចំពោះវិធីសាស្ត្ររបស់ក្រុមប្រឹក្សាសន្តិសុខពិសេសពាក់ព័ន្ធនឹងកង្វះការចូលរួមចំណែកពីសំណាក់អង្គចៅក្រម នៅក្នុងដំណើរការធ្វើសេចក្តីព្រាង[១៤០] និងការរួមបញ្ចូលលិខិតុបករណ៍អន្តរជាតិមួយចំនួនទៅក្នុងយុត្តាធិការរបស់តុលាការ ICTR ដោយមិនបានគិតទេថាតើលិខិតុបករណ៍ទាំងនោះ ជាផ្នែកមួយរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរឬយ៉ាងណានោះ[១៤១]។ ដោយយោងលើប្រវត្តិនៃការធ្វើសេចក្តីព្រាងលក្ខន្តិកៈរបស់តុលាការ ICTR មិនអាចចាត់ទុកជាការបង្ហាញពីច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងឆ្នាំ១៩៩៤ នោះទេ។

៥៦. អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយយល់ឃើញថា ការចរចារអំពីលក្ខន្តិកៈរបស់តុលាការ ICC និងពាក្យពេចន៍យកជាផ្លូវការប្រើប្រាស់នៅក្នុងលក្ខន្តិកៈរបស់តុលាការ ICC បង្ហាញពីភាព "លើសពីវិមតិសង្ស័យ"ថា នៅត្រឹមឆ្នាំ១៩៩៨ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលែងតម្រូវឱ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធទៀតហើយ[១៤២]។ ការជជែកពិភាក្សាដែលនាំឱ្យមានការអនុម័តលក្ខន្តិកៈរបស់តុលាការ ICC ផ្ទុយទៅនឹងការអះអាងរបស់អង្គជំនុំជម្រះសាលាដំបូង។ ការជជែកពិភាក្សាបង្ហាញថា សំណួរនោះនៅតែមិនទាន់បានដោះស្រាយនៅឡើយទេ នៅមុនពេលអនុម័តលក្ខន្តិកៈរបស់តុលាការ ICC[១៤៣]នោះ។ នៅក្នុងរបាយការណ៍របស់ខ្លួនផ្ញើទៅជូនមហាសន្និបាតអង្គការសហប្រជាជាតិ គណៈកម្មការ*ពិសេស* ទទួលបន្ទុកបង្កើតតុលាការព្រហ្មទណ្ឌអន្តរ

[១៣៩] របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ កថាខណ្ឌ ៩។

[១៤០] *សូមមើល* អង្គប្រជុំលើកទី៣៤៥៣ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ, S/PV.3453, ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤, ទំព័រ ៩។ *សូមមើលផងដែរ* Ford, ត្រង់ទំព័រ ១៧៩ កំណត់សម្គាល់ជើងទំព័រលេខ ២៩៩។

[១៤១] *សូមមើល*របាយការណ៍របស់អគ្គលេខាធិការ កថាខណ្ឌ ១២។

[១៤២] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣២។

[១៤៣] *សូមមើលផងដែរ* កំណត់ហេតុសង្ខេបរបស់កិច្ចប្រជុំលើកទីបី សន្និសីទអង្គទូតវិសាមញ្ញ នៃអង្គការសហប្រជាជាតិ ស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ (UN Diplomatic Conference of Plenipotentiaries on the Establishment of an International Criminal Court) A/CONF.183/C.1/SR.3, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨។

ជាតិ បានកត់សម្គាល់ពីភាពខុសគ្នារវាងមតិយោបល់នានា ដែលត្រូវបានលើកឡើងនៅក្នុងចំណោមសមាជិកពាក់ព័ន្ធនឹងលក្ខខណ្ឌទំនាក់ទំនង[១៤៤]។ នៅក្នុងពេលសន្និសិទនាទីក្រុងរ៉ូម "សមាជិកប្រតិភូមួយចំនួន" បានធ្វើការជជែកពិភាក្សាយ៉ាងខ្លាំងក្លាថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តម្រូវឱ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ[១៤៥]។ ទោះបីជា លក្ខន្តិកៈរបស់តុលាការ ICC ត្រូវបានអនុម័តនៅពេលចុងក្រោយ ដោយគ្មានទំនងទំនងជាមួយជម្លោះប្រដាប់អាវុធក៏ដោយ ការជជែកពិភាក្សាបានបន្តរហូតដល់ខណៈពេលដែលធ្វើការអនុម័តលើលក្ខន្តិកៈនោះ។

៥៧. ជាចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយបានដកស្រង់សេចក្តីថ្លែងការណ៍សារព័ត៌មានរបស់អង្គការសហប្រជាជាតិ ដើម្បីធ្វើជាអំណះអំណាងគាំទ្រដល់ការយល់ឃើញរបស់ខ្លួន[១៤៦]។ សេចក្តីថ្លែងការណ៍សារព័ត៌មាន មិនអាចចាត់ទុកជាប្រភពឯកសារសំអាងផ្លូវច្បាប់នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ[១៤៧]។

## ឈ. អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយខកខានមិនបានពិចារណាចំពោះការទទួល

---

[១៤៤] របាយការណ៍ របស់គណៈកម្មាធិការពិសេស ស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ, A/50/22 (1995), ទំព័រ ១៦ កថាខណ្ឌ ៧៩។

[១៤៥] សូមមើល Herman von Hebel និង Darryl Robinson, "*Crimes Within the Jurisdiction of the Court*," in THE INTERNATIONAL CRIMINAL COURT: THE MAKING OF THE ROME STATUTE: ISSUES, NEGOTIATIONS, RESULTS 92, Roy S. Lee, ed.,1999: "គណៈប្រតិភូនៃក្រុមប្រទេសអារ៉ាប់មួយចំនួន គាំទ្រទស្សនៈ [ដែលតម្រូវឱ្យមានទំនាក់ទំនង] ដូចគ្នានេះដែរចំពោះគណៈប្រតិភូមកពីបណ្តាប្រទេសអាហ្វ្រិក និងអាស៊ី"។ *សូមមើលផងដែរ* SCHABAS, ត្រង់ទំព័រ ១៤៦, សូមកត់សម្គាល់ថា សមាជិកអចិន្ត្រៃយ៍ចំនួនពីរក្នុងចំណោមសមាជិកអចិន្ត្រៃយ៍ចំនួន៥រូប នៃក្រុមប្រឹក្សា សន្តិសុខ (ប្រទេសចិន និងប្រទេសរុស្ស៊ី) បានគាំទ្រឱ្យរក្សាទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ។; Van Schaack, ត្រង់ទំព័រ ៨៤៤: "និយមន័យជាឯកច្ឆន្ទ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានគេចផុតពីអ្នកធ្វើសេចក្តីព្រាងយ៉ាងប៉ិនប្រសព្វរហូតដល់រយៈពេលចុងក្រោយនៃសន្និបាតលើផ្នែកការទូត។ ប្រទេសចិន ប្រទេសឥណ្ឌា និងសហភាពរុស្ស៊ី ព្រមទាំងរដ្ឋមួយចំនួន មកពីមជ្ឈិមបូព៌ា បានបន្តគាំទ្រឱ្យរក្សាទុកលក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងនេះ..."។

[១៤៦] *សូមមើល* សេចក្តីសម្រេចដែលត្រូវបានជំទាស់ កំណត់សម្គាល់ជើងទំព័រ ៧២-៧៤។

[១៤៧] *សូមមើលរឿងក្តីពាក់ព័ន្ធនឹងសកម្មភាពយោធា និងកងជីវពលនៅក្នុងប្រទេសនីការ៉ាហ្គ័រ,* I.C.J. *របាយការណ៍ឆ្នាំ ១៩៨៦* ទំព័រ ៩៨ កថាខណ្ឌ ១៨៥, ១៨៨-១៩១។ SHAW ត្រង់ទំព័រ ៨២។

**ខុសត្រូវលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអង្គជំនុំជម្រះបានអះអាងថាត្រូវបាន កំណត់ក្នុងពេលវេលាជាប់ពាក់ព័ន្ធនោះ ថាតើ លោក អៀង សារី អាចនឹងប្រមើលមើល ដឹងថាជាបទឧក្រិដ្ឋ ព្រមទាំងអាចដឹងថាមានច្បាប់ចែងដែរឬយ៉ាងណានោះ ក្នុងរយៈពេលចន្លោះពីឆ្នាំ១៩៧៥-១៩៧៩**

៥៨. អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយខកខានមិនបានធ្វើការវិភាគអំពីភាពអាចប្រមើលដឹងថាជាបទឧក្រិដ្ឋ និងភាពអាចដឹងបានថាមានច្បាប់ចែង។ ទោះបីជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាក៏ដោយ ក៏ឧក្រិដ្ឋកម្មនេះមិនមានចែងនៅក្នុងច្បាប់កម្ពុជាក្នុងរយៈពេលចន្លោះពី ឆ្នាំ១៩៧៥-១៩៧៩ នោះទេ។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងនេះមានចែងនៅក្នុងច្បាប់អន្តរជាតិ ប៉ុន្តែ ដូចបានពន្យល់*ពីខាងលើ* រួចមកហើយ និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលអាចយកមកអនុវត្តបាននៅក្នុងរយៈពេលចន្លោះពីឆ្នាំ១៩៧៥-១៩៧៩ តម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ។ ទោះបីជា *ដោយគ្រាន់តែ* សន្មត (assuming *arguendo*) ថាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងរយៈពេលចន្លោះពីឆ្នាំ១៩៧៥-១៩៧៩ មិនតម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធក៏ដោយ ក៏និយមន័យនេះត្រូវតែអាចប្រមើលដឹងមុនបានថាជាបទឧក្រិដ្ឋ និងអាចដឹងបានថាមានច្បាប់ចែង សម្រាប់លោក អៀង សារី នៅក្នុងរយៈពេលចន្លោះពីឆ្នាំ១៩៧៥-១៩៧៩ នៅមុនពេលការអនុវត្តការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនោះដែរ។ ប្រសិនបើការទទួលខុសត្រូវ មិនអាចត្រូវបានប្រមើលមើលដឹងមុន និងមិនអាចដឹងបានថាមានច្បាប់ចែងនោះនឹងមានការរំលោភបំពានទៅលើគោលការណ៍នីត្យានុកូលភាព ប្រសិនបើនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលយកមកអនុវត្តនៅពេលនេះ ចំពោះលោក អៀង សារី មិនរួមបញ្ចូលទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធទេនោះ។

៥៩. ចំពោះលក្ខខណ្ឌតម្រូវនៃភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ នឹងត្រូវបំពេញ នៅពេលដែលជនជាប់ចោទអាចដឹងថា អំពើនោះគឺជាអំពើឧក្រិដ្ឋ នៅក្នុងន័យដែលមានការយល់ដឹងជាទូទៅ[១៤៨]។

---

[១៤៨] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ២៣៥; សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ អំពី សហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៤៥។

ទោះបីជាដំណោះស្រាយតាមតាមផ្លូវតុលាការ អាចនឹងមានសារៈសំខាន់ក្នុងការដកចេញនូវភាពមិនច្បាស់លាស់ ព្រមទាំងផ្តល់នូវភាពអាចប្រមើលដឹងមុនថាជាបទឧក្រិដ្ឋក៏ដោយ[១៤៩] ក៏ការសម្រេចនេះមិនមែនជាដំណោះស្រាយសម្រាប់ករណីពាក់ព័ន្ធ បញ្ហាលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងក្នុងរយៈពេលពីឆ្នាំ ១៩៧៥-១៩៧៩ នេះដែរ។ លើកលែងតែចំពោះករណីរឿងក្តីនានារបស់ CCL 10 ដូចបានបង្ហាញ*ពីខាងលើ*រួចមកហើយ បានលើកឡើងពីភាពមិនច្បាស់លាស់ច្រើនជាងភាពច្បាស់លាស់ យើងគ្មានករណីយុត្តិសាស្ត្រ ដែលអាចប្រើប្រាស់សម្រាប់ទាញយកសេចក្តីសន្និដ្ឋានថា កង្វះលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងក្នុងរយៈពេលចន្លោះពីឆ្នាំ១៩៧៥-១៩៧៩ អាចនឹងត្រូវប្រមើលមើលដឹងថាជាបទឧក្រិដ្ឋនោះទេ។ លើសពីនេះទៀត ភាពមិនអាចជៀសរួចនៃដំណោះស្រាយអំពីភាពមិនច្បាស់លាស់នៅក្នុងច្បាប់ គឺមិនដូចគ្នានឹងភាពអាចប្រមើលមើលដឹងមុនទេ។ ការប៉ាន់ស្មានយ៉ាងច្រើនបំផុតអាចសន្និដ្ឋានថា ដំណោះស្រាយចុងក្រោយចំពោះភាពមិនច្បាស់លាស់នៅក្នុងច្បាប់ ប្រសិនបើមិនមែនមិនអាចជៀសផុត ទំនងជាធ្វើឲ្យមានការដកចេញនូវធាតុផ្សំមួយរបស់បទឧក្រិដ្ឋ។ ទាំង លោក អៀង សារី និងអ្នកសង្កេតការណ៍ដោយមិនលម្អៀងអាចនឹង ឬមាន លទ្ធភាពប្រមើលដឹងជាមុនពីរបៀបដែលភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងនេះ អាចនឹងត្រូវបានដោះស្រាយ ជាពិសេសនៅពេលធ្វើការពិចារណាអំពីទស្សនៈ និងជំហរផ្សេងៗគ្នា ដែលអ្នកប្រាជ្ញ ស្ថាប័ន និងបណ្តារដ្ឋឈានមុខនានា បានប្រកាន់ខ្ជាប់ ដូចមាន បង្ហាញជូននៅក្នុងឧបសម្ព័ន្ធ ២ និងឧបសម្ព័ន្ធ ៣ ដែលមានភ្ជាប់ជូនមកជាមួយ[១៥០]។ ទោះបីជា អង្គជំនុំជម្រះតុលាការកំពូលមិនយល់ស្របតាមគោលជំហររបស់សហមេធាវីការពារក្តីដែលថា ទំនាក់ទំនងនៅតែជាធាតុមួយរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងរយៈពេលចន្លោះពីឆ្នាំ ១៩៧៥-១៩៧៩ និងផ្អែកទាំងស្រុងទៅលើឯកសារដែលអង្គជំនុំជម្រះបានដកស្រង់សម្រាប់ជាអំណះអំណាងសម្រាប់ការវិភាគរបស់ខ្លួន ក៏ឯកសារនោះបង្ហាញថា យ៉ាងហោចណាស់ នៅមាន

---

[១៤៩] សំណើ កថាខណ្ឌ ២៥ *ដកស្រង់ចេញពីរឿងក្តី S.W. តទល់នឹង United Kingdom* តុលាការ Eur. Ct. H.R. 20166/92 សាលក្រមចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ១៩៩៥ កថាខណ្ឌ ៣២-៤៣។

[១៥០] *សូមមើល* ឧបសម្ព័ន្ធ ២៖ ឯកសារសំអាងផ្នែកច្បាប់ ស្តីពីការអនុវត្តរបស់រដ្ឋ ពាក់ព័ន្ធទៅនឹងទំនាក់ទំនងជម្លោះប្រដាប់អាវុធនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ឆ្នាំ១៨០៨ រហូតមកទល់ពេលបច្ចុប្បន្ន); ឧបសម្ព័ន្ធ ៣៖ អត្ថាធិប្បាយ ស្តីពីទំនាក់ទំនងជម្លោះប្រដាប់អាវុធ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សម្រាប់ការអត្ថាធិប្បាយរបស់អ្នកប្រាជ្ញ លើបញ្ហានេះ។

ចម្ងល់ថាតើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តម្រូវឱ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ ក្នុងរយៈពេលចន្លោះពីឆ្នាំ ១៩៧៥-១៩៧៩ ដែរឬយ៉ាងណានោះ។ ចម្ងល់នេះនៅមិនទាន់បាន ដោះស្រាយនៅឡើយទេ រហូតដល់ពេលដែលលក្ខន្តិកៈរបស់តុលាការ ICC ត្រូវបានអនុម័តនៅ ក្នុងឆ្នាំ១៩៩៨។ វាជាការមិនសមហេតុសមផលនោះទេក្នុងការយល់ឃើញថា នាពេលនោះ លោក អៀង សារី ឬអ្នកសង្កេតការណ៍មិនលម្អៀង អាចយល់ដឹងជាទូទៅ ថាខ្លួនគាត់អាចនឹងត្រូវរងការ ចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានប្រព្រឹត្តឡើងនៅក្រៅជម្លោះប្រដាប់ អាវុធមួយនោះ។

៦០. លក្ខខណ្ឌតម្រូវនៃការដឹងថាមានច្បាប់ចែង នឹងត្រូវបានបំពេញ ក្នុងករណីដែលជនជាប់ចោទបាន ដឹងពីច្បាប់ជាធរមាន ទោះបីជាច្បាប់នោះគ្រាន់តែជាច្បាប់ដែលផ្អែកលើទំនៀមទម្លាប់ក៏ដោយ[១៥១]។ ការទទួលខុសត្រូវព្រហ្មទណ្ឌដោយសារតែនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានលុប បំបាត់លក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ អាចនឹងត្រូវមិនត្រូវបានដឹង នៅក្នុងរយៈពេលចន្លោះពីឆ្នាំ១៩៧៥-១៩៧៩។ វានៅមិនទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយទេ សម្រាប់លក្ខខណ្ឌតម្រូវនៃការដឹងថាមានច្បាប់ចែង ដែលជនជាប់ចោទគ្រាន់តែមានព័ត៌មានថា អំពើមួយចំនួន អាចជាបទល្មើសព្រហ្មទណ្ឌ ក្នុងន័យដែលគេយល់ជាទូទៅនោះ។ និយមន័យ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលអាចដឹងបានក្នុងរយៈពេល ចន្លោះពីឆ្នាំ១៩៧៥-១៩៧៩ រួមបញ្ចូលទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ ដែលជាធាតុផ្សំ ចាំបាច់ត្រូវតែមានសម្រាប់ការប្រព្រឹត្តិបទឧក្រិដ្ឋនេះ។ យ៉ាងហោចណាស់ ស្ថានភាពនៃលក្ខខណ្ឌ តម្រូវឱ្យមានទំនាក់ទំនងនាពេលនោះ មិនមានភាពប្រាកដប្រជាទេ ហេតុដូច្នេះហើយ លក្ខខណ្ឌនេះ មិនអាចចាត់ទុកថា ជនជាប់ចោទបានដឹងនោះទេ។

៦១. ភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងភាពអាចដឹងបានថាមានច្បាប់ចែង មិនអាចត្រូវ កំណត់ឡើង ដោយគ្រាន់តែជនជាប់ចោទអាចស្វែងរក "យោបល់ផ្លូវច្បាប់ដែលសមស្រប ដែល

---

[១៥១] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ២៣៥; សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ អំពី សហកម្មឧក្រិដ្ឋកម្ម រួម កថាខណ្ឌ ៤៥។

វាយតម្លៃពីទិសដៅរបស់ច្បាប់ ដូចដែលការិយាល័យសហព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់[១៥២] នោះទេ។ ប៉ុន្តែ ចាំបាច់ត្រូវតែធ្វើការកំណត់ថាតើមាន "ចំនួនស៊ីសង្វាក់គ្នា និងរយៈពេលយូរ" នៃលិខិតុបករណ៍ជាតិ និងអន្តរជាតិ និងសេចក្តីសម្រេចពាក់ព័ន្ធនឹងស្ថានភាពទំនាក់ទំនងជម្លោះប្រដាប់អាវុធនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពីឆ្នាំ១៩៧៥-១៩៧៩ ដែរឬយ៉ាងណានោះ[១៥៣]។ ការអនុវត្តរបស់រដ្ឋ និង*សច្ចធារណ៍ធម្មានុរូប (opinio juris)* បង្ហាញថា ទំនាក់ទំនងគឺតម្រូវឱ្យមានជាចាំបាច់ នៅក្នុងរយៈពេលចន្លោះពីឆ្នាំ១៩៧៥-១៩៧៩ ឬមិនលើសពីអ្វីដែលអង្គបុរេជំនុំជម្រះបានសម្រេច គឺស្ថានភាពនៃទំនាក់ទំនងស្ថិតនៅក្នុងមន្ទិលសង្ស័យ។ ដូចដែលអង្គបុរេជំនុំជម្រះយល់ឃើញ "ទោះបីលិខិតុបករណ៍ទាំងនេះត្រូវបានវិនិច្ឆ័យទៅលើផលប៉ះពាល់រួមរបស់វាក្តី ហើយនៅពេលគេវិនិច្ឆ័យលិខិតុបករណ៍មួយៗដោយឡែក ភាពមិនពេញលេញរបស់វាត្រូវបានបន្ថយក៏មិនទាន់មានភាពច្បាស់លាស់ដែរថាការមិនកាត់ផ្តាច់លក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងបានកើតមាននៅពេលណានៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ[១៥៤]។ ប្រសិនបើមានមន្ទិលពាក់ព័ន្ធទៅនឹងធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិនៅចន្លោះពីឆ្នាំ១៩៧៥-១៩៧៩ នោះគោលការណ៍ជាមូលដ្ឋាន *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ (in dubi pro reo)* ត្រូវតែយកមកអនុវត្ត។

៦២. អង្គបុរេជំនុំជម្រះ បន្ទាប់ពីកំណត់ថា ស្ថានភាពលក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងមិនមានភាពច្បាស់លាស់ បានយកគោលការណ៍*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* មក

---

[១៥២] *C.f. S.W. v. United Kingdom,* Eur. Ct. H.R. 20166/92, សាលក្រមចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ កថាខណ្ឌ ៣៥-៣៦; *Miloslavsky v. United Kingdom*, Eur. Ct. H.R. 18139/91, សាលក្រមចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥ កថាខណ្ឌ ៣៧; *Kokkinakis v. Greece*, Eur. Ct. H.R. 14307/88, សាលក្រម ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៣ កថាខណ្ឌ ៣៥។

[១៥៣] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Milutinović *និងជនឯទៀត,* សេចក្តីសម្រេចលើញត្តិជំទាស់ទៅនឹងយុត្តាធិការរបស់ Dragoljub Ojdanić – *សហកម្មឧក្រិដ្ឋកម្មរួម,* IT-99-37-AR.72, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៤១។

[១៥៤] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៣១០។

អនុវត្តដោយត្រឹមត្រូវ[១៥៥]។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងខកខាន មិនបានយោងទៅគោលការណ៍នេះទាល់តែសោះ នៅក្នុងសំអាងហេតុរបស់ខ្លួន ទោះបីជាភាគីបាន លើកបញ្ហានេះឡើងរួចហើយក៏ដោយ[១៥៦]។ គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ ជនជាប់ចោទ* គឺជាគោលការណ៍ជាមូលដ្ឋាននៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលត្រូវបានទទួល ស្គាល់ដោយធម្មនុញ្ញរបស់ប្រទេសកម្ពុជា[១៥៧] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងច្បាប់អន្តរជាតិ។ គោលការណ៍នេះ មិនត្រឹមតែអនុវត្តតែចំពោះសំអាងហេតុ[១៥៨]ប៉ុណ្ណោះទេ ប៉ុន្តែ ដូចអង្គជំនុំជម្រះ តុលាការកំពូលយល់ឃើញ គោលការណ៍នេះក៏អនុវត្តចំពោះសំអាងហេតុផ្នែកច្បាប់ដែលជាកម្មវត្ថុ នៃការបកស្រាយច្បាប់ស៊ីវិលផងដែរ[១៥៩]។ មាត្រា ២២ នៃលក្ខន្តិកៈរបស់តុលាការ ICC ដែលជា

---

១៥៥ *ដូចឯកសារយោងមុន* កថាខណ្ឌ ៣១០៖ “ដោយសារមិនមានទម្លាប់អនុវត្តរបស់រដ្ឋច្បាស់លាស់ និង*ទស្សនៈច្បាប់*នោះ អង្គបុរេជំនុំជម្រះ នៅតែមិនអាចកំណត់បានពីដំណាក់កាលដែលមានបញ្ហាចន្លោះពីឆ្នាំ ១៩៦៨ រហូតដល់ឆ្នាំ១៩៨៤ នៅពេលដែលដំណាក់កាលអន្តរកាលបានកើតឡើង។ បើតាមគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ(in dubio pro reo)* ភាពមិនច្បាស់លាស់បែបនេះ នឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ”។

១៥៦ *សូមមើល* សំណើ កថាខណ្ឌ ២៧-៣២; ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ៣២-៣៤; ចម្លើយតបរបស់ នួន ជា ទៅនឹង សំណើរបស់សហព្រះរាជអាជ្ញា ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង ដកលក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារលេខ E95/5 កថាខណ្ឌ ៣, ៧-១៤; ចម្លើយតបរបស់ អៀង ធីរិទ្ធ ចំពោះសំណើរបស់សហព្រះរាជអាជ្ញា ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងឱ្យធ្វើវិសោធនកម្ម លើនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារលេខ E95/2 កថាខណ្ឌ ១៨-២៤។

១៥៧ ធម្មនុញ្ញ មាត្រា ៣៨ (សូមបញ្ជាក់បន្ថែម)៖ “វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ”។

១៥៨ ការិយាល័យសហព្រះរាជអាជ្ញា បានលើកទឡ្ហីករណ៍នេះដោយមានការភ័ន្តច្រលំ នៅក្នុងការដាក់ឯកសារនៅពេលមុន។ *សូមមើល* សំណើ កថាខណ្ឌ ២៧-៣២។

១៥៩ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E50/3/1/4 កថាខណ្ឌ ៣១៖ “ចំពោះ*គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* អាចអនុវត្តបានចំពោះស្ថានភាពលំបាកនៃអត្ថន័យច្បាប់ គោលការណ៍នេះ ត្រូវកម្រិតត្រឹមតែភាពមន្ទិលសង្ស័យដែលនៅតែមានក្រោយការបកស្រាយ។ ហេតុដូច្នេះ *គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ត្រូវតែអនុវត្តយ៉ាងត្រឹមត្រូវចំពោះភាពមន្ទិលសង្ស័យ អំពីខ្លឹមសារនៃបទដ្ឋានគតិយុត្តិ ដែលនៅតែមានក្រោយការអនុវត្ត នូវវិធាននៃការបកស្រាយតាមប្រព័ន្ធច្បាប់ស៊ីវិល ដោយធ្វើការពិចារណាទៅលើពាក្យពេចន៍នៃបទប្បញ្ញត្តិ ការដាក់បញ្ចូលក្នុង

ប្រភពឯកសារសំអាងផ្នែកច្បាប់របស់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ បញ្ជាក់ពីការអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ចំពោះសំអាងហេតុផ្នែកច្បាប់ថា៖ "ចំពោះករណីដែលមានភាពមិនច្បាស់លាស់ [ចំពោះនិយមន័យរបស់បទឧក្រិដ្ឋ] និយមន័យគួរត្រូវបានបកស្រាយដោយផ្តល់ប្រយោជន៍ចំពោះបុគ្គលដែលកំពុងស្ថិតក្នុងការស៊ើបអង្កេត រងការចោទប្រកាន់ ឬត្រូវបានផ្តន្ទាទោស"[១៦០]។ សហមេធាវីការពារក្តីសូមលើកឡើងថា ទោះបីជាលក្ខន្តិកៈរបស់តុលាការ ICC គឺជាច្បាប់ដែលផ្អែកលើសន្ធិសញ្ញាជាគោល មិនមែនជាច្បាប់ទំនៀមទម្លាប់ក៏ដោយ ក៏មាត្រា ២២ បញ្ជាក់ពីការទទួលស្គាល់ និងទទួលយកជាលក្ខណៈអន្តរជាតិចំពោះគោលការណ៍ជាមូលដ្ឋាននៃនីត្យានុកូលភាព និងគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*។ លើសពីនេះទៀត មាត្រា ២២ ក៏បានបញ្ជាក់ពីការអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ចំពោះសំអាងហេតុផ្នែកច្បាប់ផងដែរ។ ដូចមានចែងនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ រាល់ការសង្ស័យចំពោះអត្ថិភាពនៃលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងរយៈពេលចន្លោះពីឆ្នាំ១៩៧៥-១៩៧៩ ជាចុងក្រោយ *ចាំបាច់ត្រូវតែ* ដោះស្រាយដោយផ្តល់ប្រយោជន៍ទៅលោក អៀង សារី។ ផ្ទុយទៅនឹងការសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលបានធ្វើការពិចារណារាល់ប្រភពឯកសារសំអាងផ្នែកច្បាប់ទាំងអស់ មុននឹងឈានដល់ការធ្វើសេចក្តីសម្រេចរបស់ខ្លួន និងបានកំណត់ថាមានភាពមិនច្បាស់លាស់នៃប្រភពដែលតម្រូវឲ្យមានការអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* នោះ អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានវិភាគឲ្យគ្រប់ជ្រុងជ្រោយទៅលើរាល់ប្រភពឯកសារសំអាងផ្នែកច្បាប់ នៅមុនពេលចេញសេចក្តីសម្រេចដែល

---

ប្រព័ន្ធ រួមមានការជាប់ទាក់ទិនទៅនឹងគោលការណ៍សំខាន់ៗ ដែលជាមូលដ្ឋានគ្រឹះ និងគោលបំណងនៃគោលការណ៍នេះ"។ *សូមមើលផងដែរ* ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ៣៣។

[១៦០] លក្ខន្តិកៈរបស់តុលាការ ICC មាត្រា ២២៖ "១. បុគ្គលម្នាក់មិនត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ក្រោមលក្ខន្តិកៈនេះទេ លុះត្រាតែអំពើដែលចោទឡើងនោះ នៅខណៈដែលអំពើនោះកើតមាន បង្កឲ្យមានជាបទឧក្រិដ្ឋស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ។ ២. និយមន័យនៃអំពើឧក្រិដ្ឋកម្ម គួរតែបកស្រាយឲ្យបានតឹងរ៉ឹង និងមិនត្រូវពន្លាតអត្ថន័យទៅតាមសទិសភាព (analogy) នោះទេ។ ចំពោះករណីដែលមិនមានន័យច្បាស់លាស់ និយមន័យគួរត្រូវគេបកស្រាយដោយផ្តល់ប្រយោជន៍ទៅបុគ្គលដែលកំពុងស្ថិតក្រោមការស៊ើបអង្កេត រងការចោទប្រកាន់ ឬត្រូវបានផ្តន្ទាទោស។ ៣. មាត្រានេះមិនមានផលប៉ះពាល់ដល់លក្ខណៈវិនិច្ឆ័យទៅលើរាល់ការប្រព្រឹត្តដែលត្រូវចាត់ទុកជាអំពើព្រហ្មទណ្ឌ នៅក្រោមច្បាប់អន្តរជាតិ ដែលមានលក្ខណៈឯករាជ្យពីលក្ខន្តិកៈនេះ"។

ត្រូវបានជំទាស់នេះ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានធ្វើការពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយនោះ អង្គជំនុំជម្រះសាលាដំបូងគួរបានធ្វើការសម្រេចថា ទំនាក់ទំនងមានអត្ថិភាពនៅក្នុងរយៈពេលចន្លោះពីឆ្នាំ១៩៧៥-១៩៧៩ ឬ យ៉ាងហោចណាស់ ថា ស្ថានភាពមិនមានភាពច្បាស់លាស់ ករណីនេះគួរតែអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ចំពោះសំអាងហេតុផ្នែកច្បាប់របស់ខ្លួន។

## VI. សេចក្តីសន្និដ្ឋាន និងសំណូមពរ

៦៣. កំហុសរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបកស្រាយលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធទៅនឹងបញ្ហាលក្ខខណ្ឌទំនាក់ទំនង និងក្នុងការខកខានវិភាគទៅលើភាពអាចប្រមើលដឹងជាមុនថាមានបទឧក្រិដ្ឋ និងភាពដឹងថាមានច្បាប់ចែង ឬអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ (in dubio pro reo)* ធ្វើឲ្យសេចក្តីសម្រេចដែលត្រូវបានជំទាស់នេះមានមោឃភាព។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានដាក់ លោក អៀង សារី ក្លាយជាកម្មវត្ថុនៃការចោទប្រកាន់ ដែលខ្វះធាតុផ្សំដែលមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទំលាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ដែលជាការរំលោភទៅនឹងគោលការណ៍នីត្យានុកូលភាព។ ក្នុងករណីមានមន្ទិលសង្ស័យ អង្គជំនុំជម្រះសាលាដំបូងគួរតែបានអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ (in dubio pro reo)* និងដោះស្រាយបញ្ហានេះ ដោយផ្តល់ប្រយោជន៍ទៅលោក អៀង សារី។ នៅក្នុងការវាយតម្លៃទៅលើ អ.វ.ត.ក អ្វីដែលត្រូវពិនិត្យមើលនោះគឺភាពយុត្តិធម៌នៃការកាត់សេចក្តីរបស់ខ្លួន មិនមែនមើលទៅលើចំនួននៃការចោទប្រកាន់ដែលអង្គជំនុំជម្រះនេះទទួលមកចាត់ការនោះទេ[១៦១]។ វិធីសាស្ត្រសម្រេចយកលទ្ធផលរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការសម្រេចទៅលើបញ្ហាលក្ខខណ្ឌទំនាក់ទំនង បង្កើតបានជាការ "បោះបង់វិធានច្បាប់" និងជាការរំលោភបំពានទៅលើកាតព្វកិច្ចរបស់អង្គជំនុំជម្រះ ដែលមានចែងក្នុងច្បាប់

---

[១៦១] *សូមមើល* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Milošević*, IT-02-54-AR73.4, គំនិតជំទាស់របស់ចៅក្រម David Hunt ស្តីពីភាពអាចទទួលយកបាននៃភស្តុតាងសំខាន់ៗ នៅក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៣ កថាខណ្ឌ ២២: "តុលាការនេះ នឹងមិនធ្វើការជំនុំជម្រះ ទៅលើចំនួនរឿងក្តីដែលខ្លួននឹងទទួលចាត់ការ ឬទៅលើល្បឿនរបស់តុលាការ ក្នុងការបំពេញយុទ្ធសាស្ត្របញ្ចប់ ដែលក្រុមប្រឹក្សាសន្តិសុខ បានគាំទ្រនោះទេ គឺផ្តោតតែម្យ៉ាងទៅលើភាពយុត្តិធម៌ ដែលតុលាការមាននៅក្នុងសវនាការរបស់ខ្លួនតែប៉ុណ្ណោះ" ។

ស្តីពីការបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង និង ICCPR[១៦២] ក្នុងការធានានូវយុត្តិធម៌ ភាពត្រឹមត្រូវ និងនីតិវិធីត្រឹមត្រូវស្របច្បាប់ សម្រាប់ជនជាប់ចោទ។

**ហេតុដូច្នេះ** យោងតាមសំអាងហេតុដូចបានរៀបរាប់ខាងលើ សហមេធាវីការពារក្តីសូមស្នើដោយគោរពដល់អង្គជំនុំជម្រះតុលាការកំពូល មេត្តា៖

ក. **បង្គាប់ឲ្យ** មានសវនាការជាសាធារណៈ និងដោយផ្ទាល់មាត់ ដើម្បីដោះស្រាយបញ្ហាដែលមាននៅក្នុងបណ្តឹងឧទ្ធរណ៍នេះ

ខ. **សម្រេច និងប្រកាសថា** បណ្តឹងឧទ្ធរណ៍ធ្វើឡើងនាពេលនេះ អាចទទួលយកបានអនុលោមតាម វិធាន ១០៤(១), ១០៤(៤)(ក) វិធាន ១០៥(២) និងវិធាន២១ នៃវិធានផ្ទៃក្នុង

គ. **យល់ព្រមតាម** មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ និង

ឃ. **ទុកជាមោឃៈ** សេចក្តីសម្រេចដែលត្រូវបានជំទាស់ ដែលមិនដាក់បញ្ចូលលក្ខខណ្ឌទំនាក់ទំនងជម្លោះប្រដាប់អាវុធ ទៅក្នុងនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលនឹងត្រូវយកមកអនុវត្តនៅក្នុងសំណុំរឿង ០០២។

សូមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

---

[១៦២] Susan Lamb, Nullum Crimen, Nulla Poena Sine Lege *in International Criminal Law, in 1* The ROME STATUTE OF THE INTERNATIONAL CRIMINAL COURT: A COMMENTARY 743 (Cassese, Gaeta, Jones, eds., 2002), *ដកស្រង់ចេញពី* Bruce Broomhall, *មាត្រា ២២៖* Nullum Crimen Sine Lege, in COMMENTARY ON THE ROME STATUTE OF THE INTERNATIONAL CRIMINAL COURT 451 (Triffterer, ed., 1999)។

________________ ________________

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីការពារក្តី លោក អៀង សារី

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១